# វគ្គទី ៤
# ជីវិតនៅទីក្រុងប៉ារីស
# (ទសវត្សរ៍ឆ្នាំ ១៩៨០)

## ដំណើរគ្រាដំបូងតាមយន្តហោះ

គ្រាន់តែចូលក្នុងយន្តហោះភ្លាម បន្ទាប់ពីបានលើកដៃធ្វើសញ្ញាលាគ្នាជាច្រើនរយដងមកនោះ ខ្ញុំក៏លែងបានឃើញមុខឪពុកខ្ញុំ បងៗខ្ញុំទាំងពីរ ប្អូនខ្ញុំពីរនាក់ទៀត តាំងពីពេលនោះជារៀងរហូតមក ។ នារីជនជាតិបារាំងដ៏ស្រស់ក្មេងម្នាក់បានចង្អុលបង្ហាញកន្លែងអង្គុយរបស់ខ្ញុំនៅក្នុងយន្តហោះ ។ នារីនោះជាអ្នកបំរើសេវាតាមយន្តហោះម្នាក់ ក្នុងចំណោមពីរនាក់ ដែលនៅឈរអមមាត់ទ្វារយន្តហោះ ចាំទទួលស្វាគមន៍អ្នកដំណើរ ។ ជាការគួរឲ្យភ្ញាក់ផ្អើល ខ្ញុំត្រូវទៅអង្គុយនៅកន្លែងមួយជិតកន្លែងកូនលោកថៅហ្វាយស្រុកម្នាក់ ដែលធ្លាប់ធ្វើការនៅស្រុកកំណើតរបស់ខ្ញុំ ។ ដោយសារនេះជាលើកទីមួយដែលខ្ញុំមានភ័ព្វសំណាងបានជិះយន្តហោះ ខ្ញុំពុំដឹងថាតើគេពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពយ៉ាងដូចម្តេចទេ ។ ក៏ប៉ុន្តែកូនលោកថៅហ្វាយស្រុកក៏មានការគួរសមចំពោះខ្ញុំ ដោយជួយពាក់ខ្សែក្រវ៉ាត់នោះឲ្យ ។ ពួកយើងគឺ ជាក្រុមអ្នកដំណើរដែលត្រូវចេញដំណើរតាមជើងយន្តហោះ អ៊ុយ តេ អា (UTA) ពីភ្នំពេញ ទៅទីក្រុងប៉ារីសតាំងពីមួយថ្ងៃកន្លងរួចទៅហើយឯណោះ ។ ក៏ប៉ុន្តែពុំដឹងមានមូលហេតុអ្វីទើបជើងយន្តហោះរបស់ពួកយើងត្រូវលើកមកថ្ងៃនេះវិញ ។ ដូច្នេះការធ្វើដំណើររបស់ពួកយើង ត្រូវទៅឈប់សំរាកនៅទីក្រុងបាងកកមួយយប់ មុន

នឹងបន្តដំណើរតទៅទៀត ។ យន្តហោះដែលយើងជិះពីភ្នំពេញ ទៅបាងកកនៅថ្ងៃនោះគឺជាយន្តហោះធុនប៊ូអ៊ីង ៧០៧ ។ កូនលោកថៅហ្វាយស្រុកដែលអង្គុយជិតខ្ញុំនោះ គេមិនចាំបាច់ឈប់សំរាកនៅទីក្រុងបាងកកទេ ។ ពួកគេត្រូវបន្តដំណើរដោយត្រង់ឆ្ពោះទៅទីក្រុងប៉ារីសតែម្តង ។ ពួកយើងមកដល់រាជធានីនៃប្រទេសថៃនៅវេលាល្ងាចថ្ងៃដដែល ។

បន្ទាប់ពីបានបំពេញបែបបទខាងអន្តោប្រវេសន៍រួចមក ពួកយើងត្រូវជិះមីនីប៊ុស (Minibus) ចេញពីអាកាសយានដ្ឋានដនមឿង ទៅកាន់សណ្ឋាគារមួយឋិតនៅកណ្តាលក្រុងបាងកក ។ នៅសម័យនោះ ព្រលានយន្តហោះដនមឿងនៃទីក្រុងបាងកកនៅមានទំហំតូចនៅឡើយ ហើយក៏ពុំទាន់មានភាពទំនើបដូចបច្ចុប្បន្ននេះទេ ។ ការធ្វើដំណើរពីព្រលានយន្តហោះទៅទីក្រុង ហាក់ដូចជាវែងឆ្ងាយណាស់ព្រោះផ្លូវក៏ពុំទាន់ល្អ ហើយក៏ពុំទាន់មានអគារធំៗដូចសព្វថ្ងៃនេះដែរ ។ នៅតាមផ្លូវខ្ញុំសង្កេតឃើញផ្ទះឈើខ្លះ និង វត្តអារាមខ្លះមិនខុសគ្នាប៉ុន្មានពីទិដ្ឋភាពនៅប្រទេសខ្មែរយើងឡើយ ។

ពួកយើងត្រូវស្នាក់នៅក្នុងសណ្ឋាគារមួយឈ្មោះ ម៉ង់ដារីន (Mandarin) ដែលផ្តល់ឲ្យយើងនូវសេវាស្នាក់នៅ និង ម្ហូបអាហារគ្រប់យ៉ាង ។ សណ្ឋាគារនោះឋិតនៅក្បែរតំបន់នៃសាកលវិទ្យាល័យជូឡាឡុងកន ។ នៅក្នុងសណ្ឋាគារនេះ ខ្ញុំជួបជាលើកដំបូងនូវប្រណិតភាពសម្រាប់ជីវិតខ្ញុំ ។ តាំងពីដើមមក ខ្ញុំពុំដែលមានគ្រែពូកអ្វីពិតប្រាកដទេគឺ ធ្លាប់តែទទួលទានដំណេកលើកន្ទេល ក្រាលលើក្តារតែប៉ុណ្ណោះ ហើយខ្ញុំក៏ពុំដែលមានបន្ទប់ទឹកអ្វីស្រួលបួលដែរ ។ ខ្ញុំធ្លាប់តែងូតទឹកពាងដែលមានរបាំងបន្តិចបន្តួច ។

បន្ទាប់ពីទទួលទានបាយល្ងាចរួច អ្នកដំណើរមួយចំនួនមិនចូលសំរាកភ្លាម

ទេ គេនាំគ្នាចេញទៅដើរលេងខាងក្រៅ មើលភ្លើងក្នុងទីក្រុង ឬ ដើរកំសាន្តតាមវង្គសាលដែលនៅក្បែរសណ្ឋាគារនោះ ។ ផ្ទុយពីអ្នកឯទៀត ខ្ញុំដើរតម្រង់ទៅបន្ទប់ខ្ញុំតែម្តង ។ ខ្ញុំចង់ឆ្លៀតឱកាសឲ្យបានយូរ ដើម្បីក្រេបជញ្ជក់នូវភាពប្រណិត និង ប្រើឲ្យឆ្អែតនូវគ្រឿងសង្ហារឹមទំនើបៗទាំងឡាយដូចជា សាឡុង គ្រែពូក ម៉ាស៊ីនត្រជាក់ ទូរទស្សន៍ និង គ្រឿងសង្ហារឹម ឬ អសង្ហារឹមឯទៀត ដែលខ្ញុំមិនធ្លាប់បានប្រើសោះ ។ នោះគឺ ជាលើកទីមួយ ដែលខ្ញុំទៅងូតទឹក សំអាតរាងកាយនៅក្នុងបន្ទប់ទឹកដ៏ទំនើប ។ ខ្ញុំហាក់ដូចជាមានការអៀនខ្មាស់ខ្លះចំពោះខ្លួនឯង ។ នៅប្រទេសយើង ឬ នៅឯផ្ទះយើងៗមានទម្លាប់យ៉ាងហោចណាស់ក៏ស្លៀកក្រមាដែរ ដើម្បីងូតទឹក មិនដូចជាទម្លាប់របស់អ្នកបស្ចឹមប្រទេស ដែលគេតែងលែងខ្លួនទទេនៅពេលជំរះកាយក្នុងបន្ទប់ទឹកនោះទេ ។ ពេលនោះក៏ជាលើកទីមួយដែរ ដែលខ្ញុំអាចទទួលទានដំណេក លើគ្រែដ៏មានពូកក្រាស់ ប្រកបដោយភួយ និង កម្រាលដ៏សស្អាត ។ កាលនោះ ខ្ញុំមិនទាន់ស្គាល់របៀបរបបនៃការទទួលទានដំណេកឲ្យបានត្រឹមត្រូវនោះទេ ។ តាមធម្មតា គេចូលទៅសម្រាកក្នុងភួយ ដែលគេក្រាលជាស្រេចនៅលើពូក ។ ចំពោះខ្ញុំនៅពេលនោះ ខ្ញុំស្មានតែភួយនោះជាកម្រាលពូក ដូច្នេះខ្ញុំក៏ទទួលទានដំណេកនៅពីលើ ឬ នៅក្រៅភួយទៅវិញ ។ ដោយសារខ្ញុំរកភួយមិនឃើញ និង ដោយសារតែម៉ាស៊ីនត្រជាក់ ដែលខ្ញុំមិនទាន់ចេះបន្ថយ ឬ បន្ថែមកម្លាំង ខ្ញុំទទួលរងរងាអស់មួយយប់ ។

ព្រឹកឡើង ខ្ញុំក៏ដឹងថាមិនមែនមានតែខ្ញុំទេ ដែលមិនធ្លាប់រស់នៅក្នុងសណ្ឋាគារដ៏ធំបែបនេះ ។ អ្នកដំណើរមួយចំនួនធំ នាំគ្នានិយាយកំប្លែងអំពីការភ័ន្តច្រឡំក្នុងការប្រើប្រាស់កំរាលគ្រែ ជំនួសភួយដូចខ្ញុំដែរ ។ តាមពិត អ្នករួមដំណើរជាមួយខ្ញុំមួយចំនួនធំ សុទ្ធតែចេញមកពីក្រុមគ្រួសារអ្នកស្រុកសាមញ្ញ មិនមែនសុទ្ធតែជាគ្រួសារអ្នកមានទេ ។ ដូច្នេះការស្នាក់អាស្រ័យរបស់យើង នៅក្នុងសណ្ឋាគារនោះ

ជាគំហើញដំបូងបង្អស់នូវអ្វីដែលហៅថាប្រណិតភាព ។ ក្នុងចំណោមអ្នករួមដំណើរ មាននារីម្នាក់អមដំណើរដោយកូនតូចៗពីរនាក់ផង ទំនងជាមានស្វាមីធ្វើការជាអ្នកការទូត ។ គាត់ប្រាកដជាធ្លាប់ធ្វើដំណើរចេញចូល ទៅក្រៅប្រទេសញឹកញាប់ណាស់ ។ នារីនោះបានណែនាំពន្យល់ពួកយើង អំពីរបៀបរបបទទួលទានអាហាររបៀបកាន់សមស្លាបព្រា ឬ ទទួលទានដំណោកតាមបែបស៊ីវិល័យ ។ គាត់តែងតែសើចកក្អាកក្អាយជាញឹកញាប់ នៅពេលដែលគាត់ឮពាក្យកំប្លែងរបស់ពួកយើងអំពីការភ័ន្តច្រឡំ ក្នុងការប្រើប្រាស់ឧបករណ៍ផ្សេងៗនៅក្នុងបន្ទប់ ។

ស្អែកឡើង នៅពេលដែលពួកយើងត្រឡប់ទៅព្រលានយន្តហោះវិញនោះ នារីនោះក៏បានជួយណែនាំពន្យល់យើង ឲ្យចេះបំពេញបែបបទអន្តោប្រវេសន៍ ក្នុងការបន្តដំណើរតទៅទៀត ។ តាមធម្មតាក្នុងការធ្វើដំណើរ យើងតែងមាននារីជនជាតិថៃអមដំណើរ និង ជួយពន្យល់យើងយ៉ាងលំអិតអំពីបែបបទដែលយើងត្រូវបំពេញ ។ ក៏ប៉ុន្តែ ចំពោះពួកយើង ដែលចេះដឹងភាសាបន្តិចបន្តួច យើងមិនអាចយល់ច្បាស់លាស់អំពីក្រឹត្យក្រមនៃការធ្វើដំណើរនោះបានឡើយ ។ ដូច្នេះនារីខ្មែរដែលមានកូនពីរនាក់នោះ បានជួយពន្យល់បន្ថែមជាលំអិត ។ ការណែនាំរបស់គាត់មានប្រយោជន៍ខ្លាំងណាស់ចំពោះយើង ។ លើសពីនេះទៅទៀត ពួកយើងត្រូវបង់ពន្ធអាករព្រលានយន្តហោះផង ។ ខ្ញុំពុំបានត្រៀមប្រាក់សំរាប់បង់ពន្ធអាករនេះទេ ។ ដូច្នេះ នារីខ្មែរនោះក៏មានចិត្តល្អ ជួយចេញប្រាក់បង់ថ្លៃអាករជំនួសខ្ញុំ ។ ខ្ញុំជំពាក់គុណនារីខ្មែរនោះច្រើនណាស់ ចំពោះការជួយណែនាំរបស់គាត់ និង ចំពោះតំលៃពន្ធអាករព្រលានយន្តហោះ ដែលគាត់ជួយចេញឲ្យខ្ញុំដោយសប្បុរស ។ តែគួរឲ្យស្ដាយជាពន់ពេក ដែលខ្ញុំមិនបានសួរឈ្មោះ និង អាស័យដ្ឋានរបស់គាត់ ។ ដូច្នេះខ្ញុំក៏មិនស្គាល់គាត់ រហូតដល់បច្ចុប្បន្នកាលនេះ ។ ខ្ញុំមិនដឹងថានារីនោះនៅរស់ ឬស្លាប់ទៅហើយនៅសម័យ ប៉ុល ពត ។

នៅក្នុងយន្តហោះ ខ្ញុំសប្បាយនឹងសេវាកម្មនៅលើអាកាសនេះណាស់ ដែលមានទាំងសេវាបំរើម្ហូបអាហារ ភេសជ្ជៈ និង ការឈប់សំចតនៅជាច្រើនដំណាក់នៅក្នុងប្រទេសមួយចំនួន នៅពេលយើងឆ្លងកាត់ទម្រាំទៅដល់ប្រទេសបារាំង ។ ខ្ញុំសប្បាយនឹងសេវាកម្មទាំងអស់នោះ ដោយភ្លេចខ្លួនថាការធ្វើដំណើរតាមផ្លូវអាកាសលើកនេះ នឹងនាំខ្ញុំទៅពិភពមួយថ្មីអស់រយៈពេលមួយដ៏យូរអង្វែង ។ ការផ្សងព្រេងពិតប្រាកដរបស់ខ្ញុំចាប់ផ្តើមឡើង នៅពេលដែលនារីបំរើតាមយន្តហោះប្រកាសតាមឧឃោសនស័ព្ទថា បន្តិចទៀតនេះយន្តហោះនឹងចុះចតនៅប្រទេសបារាំង ។ នារីនោះនិយាយថា "អស់លោកអ្នកកំពុងឆ្លងកាត់ទីក្រុងស៊ូរិកនៃប្រទេសស្វីស ក្នុងរយៈពេលបន្តិចទៀតលោកអ្នក នឹងទៅដល់ទីក្រុងប៉ារីស" ។ គឺនៅពេលនោះ ទើបខ្ញុំចាប់អារម្មណ៍ចំពោះទីដៅចុងក្រោយនៃការធ្វើដំណើររបស់ខ្ញុំ ។ ថ្ងៃនោះគឺ ថ្ងៃទី ៨ ខែ ៨ ឆ្នាំ ១៩៧៣ ជាតួលេខមួយដែលស្រួលចាំជាទីបំផុត ។ នៅថ្ងៃនោះ យន្តហោះបានចុះចតនៅអាកាសយានដ្ឋានទីក្រុងប៉ារីស ឈ្មោះអកលី (Orly) ព្រោះអាកាសយានដ្ឋានស្ហាលដឺហ្គោល (Charles de Gaulle) មិនទាន់កើតនៅឡើយទេ ។

# ជីវិតផ្សងព្រេងនៅទីក្រុងប៉ារីស

តាមពិត ខ្លួនខ្ញុំមិនបានដឹងថា តើខ្ញុំត្រូវចេញទៅទីកន្លែងណាទេ នៅពេលចេញពីអាកាសយានដ្ឋានអកលីនោះ ។ នៅច្រកចេញចូលនៃក្រុមប៉ូលីសអន្តោប្រវេសន៍ ខ្ញុំបានបំពេញបែបបទ ដោយចុះនូវអាស័យដ្ឋានមួយ ដែលខ្ញុំមិនធ្លាប់ស្គាល់ទាល់តែសោះ ដោយខ្ញុំគ្រាន់តែចម្លងតគ្នា ពីអ្នករួមដំណើរជាជនជាតិខ្មែរដូចគ្នាឯទៀត ដែលគេហុចពីមួយទៅមួយជាហូរហែ ។ ក្រោយពីបានបំពេញបែបបទរួច

ហើយ ខ្ញុំក៏ដើរចេញទៅក្រៅនៃអគារអាកាសយានដ្ឋាន តាមពីក្រោយនិស្សិតខ្មែរម្នាក់ ដែលទំនងជាមានអាយុប្រហាក់ប្រហែលខ្ញុំដែរ ។ និស្សិតខ្មែរនោះ ហាក់ដូចជាធ្លាប់ធ្វើដំណើរចេញចូលទីក្រុងប៉ារីសយ៉ាងញឹកញាប់ណាស់ ព្រោះគេដូចជាស្គាល់ទីកន្លែងយ៉ាងច្បាស់លាស់ ។ គេបាននិយាយប្រាប់ខ្ញុំថា នេះមិនមែនជាការធ្វើដំណើរលើកទីមួយរបស់គេនោះទេ ។ និស្សិតនោះ មានបងប្អូន និង មិត្តភក្តិពីរ ឬ បីនាក់មកទទួលនៅអាកាសយានដ្ឋាន ។

នៅពេលដែលនិស្សិតនោះ កំពុងរង់ចាំរថយន្តរបស់បងប្អូន ដែលត្រូវជូនចេញពីអាកាសយានដ្ឋានទៅទីក្រុងប៉ារីសនោះ ខ្ញុំក៏ដាច់ចិត្តសុំឲ្យជួយដោះស្រាយបញ្ហាបន្ទាន់របស់ខ្ញុំ ។ បញ្ហាដ៏ធំគឺ ខ្ញុំមិនស្គាល់ទិសតំបន់អ្វីទាំងអស់ ជាពិសេស ខ្ញុំមិនដឹងថាតើខ្ញុំត្រូវទៅទីណាឲ្យពិតប្រាកដទេ ។ ខ្ញុំលូកក្នុងហោប៉ៅទាញយកក្រដាសមួយសន្លឹក ដែលខ្ញុំបានកត់អាស័យដ្ឋាននៃទីកន្លែង ដែលខ្ញុំអាចទៅរក ។ ខ្ញុំក៏បង្ហាញនិស្សិតនោះ នូវអាស័យដ្ឋានរបស់គ្រួសារខ្មែរមួយ ដែលធ្លាប់រស់នៅទីក្រុងភ្នំពេញ ជាអ្នកជិតខាងគ្នា ឈ្មោះគ្រួសារលោកវេជ្ជបណ្ឌិត ស៊ូ ណែម ។

លោកវេជ្ជបណ្ឌិត ស៊ូ ណែម បានទទួលអាហារូបករណ៍មកបន្តវិជ្ជាឯកទេសខាងវិជ្ជាពេទ្យនៅទីក្រុងប៉ារីស កាលពីពីរឆ្នាំមុន ។ អាស័យដ្ឋាននោះគឺ លេខ ២ វីឡា ដឺ បែលឡែរ ( 2 Villa de Bel Air ) នៅសង្កាត់ ១២ ទីក្រុងប៉ារីស ។ ខ្ញុំសួរនិស្សិតនោះថា ស្គាល់អាស័យដ្ឋាននោះឬទេ? តើត្រូវធ្វើដូចម្ដេច ទើបអាចទៅដល់ទីនោះ? យុវជននោះ និង បងប្អូនរបស់គេ មិនគ្រាន់តែស្គាល់អាស័យដ្ឋាននោះច្បាស់លាស់ប៉ុណ្ណោះទេ ថែមទាំងមានចិត្តសប្បុរស ជានាជូនខ្ញុំទៅជួបលោកវេជ្ជបណ្ឌិត ស៊ូ ណែម តាមរថយន្តរបស់ពួកគេផង ។ ខ្ញុំមានសេចក្ដីត្រេកអរណាស់ចំពោះកាយវិការដ៏ប្រពៃរបស់ក្រុមយុវជននេះ ហើយក៏ប្រញាប់ប្រញាល់រត់ចូលទៅក្នុងរថយន្តភ្លាម ។ ក្រុមយុវជនទាំងនោះ បានខិតខំលើកទឹកចិត្ត កុំឲ្យខ្ញុំមានការ

ព្រួយបារម្ភអ្វី ក៏ប៉ុន្តែខ្ញុំនៅតែខ្វល់ខ្វាយក្នុងចិត្ត ព្រោះខ្ញុំមិនដឹងនិយាយប្រាប់លោកវេជ្ជបណ្ឌិត ស៊ូ ណៃម ដោយរបៀបណា ។ ពួកយើងមិនដែលស្គាល់ ឬ មិនដែលបាននិយាយរកគ្នា កាលយើងនៅឯប្រទេសខ្មែរនៅឡើយទេ ។ ក្រុមយុវជនទាំងនោះ បានជួយសំរួលខ្ញុំយ៉ាងខ្លាំង ដោយបាននាំខ្ញុំចូលមកដល់ផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណៃម ។ គួរឲ្យស្តាយ ខ្ញុំមិនបានសួរឈ្មោះ ឬ អាស័យដ្ឋានរបស់យុវជនទាំងនោះ ។ រហូតមកដល់ពេលនេះ ខ្ញុំក៏ពុំបានស្គាល់អ្នកដែលបានធ្វើអំពើល្អ ចំពោះខ្ញុំនេះជារៀងដរាប ។

នៅពេលដែលគាត់បើកទ្វារភ្លាម លោកវេជ្ជបណ្ឌិត ស៊ូ ណៃម ប្រហែលមិនបាននឹកគិតពីការមកដល់របស់ខ្ញុំ នៅក្នុងផ្ទះរបស់គាត់នោះឡើយ ។ ក៏ប៉ុន្តែជាកុសលល្អ ភរិយារបស់គាត់បាននឹកដល់កិច្ចសន្ទនា ដែលគាត់បានធ្វើជាមួយឪពុកខ្ញុំកាលពីមួយខែមុន ។ ឪពុកខ្ញុំធ្លាប់បានប្រាប់ភរិយាលោកវេជ្ជបណ្ឌិត ស៊ូ ណៃម ថាខ្ញុំមានគំរោងធ្វើដំណើរមកប្រទេសបារាំងនៅពេលខាងមុខ ។ ខ្ញុំមិនប្រាកដថាលោកវេជ្ជបណ្ឌិតមានការភ្ញាក់ផ្អើល ដោយសប្បាយចិត្ត ឬ មិនសប្បាយចិត្តចំពោះភាពចៃដន្យនៃវត្តមានរបស់ខ្ញុំនេះឡើយ ។ ក៏ប៉ុន្តែ លោកស្រីជាភរិយារបស់គាត់បានបង្ហាញភាពស្និទ្ធស្នាលរាក់ទាក់ ។ លោកស្រីចេញមកឈរក្បែរស្វាមី ដោយមានទឹកមុខញញឹម រួចហៅខ្ញុំចំឈ្មោះ ហាក់ដូចជាយើងធ្លាប់ស្គាល់គ្នាជាយូរយារណាស់មកហើយ ។ លោកស្រីធ្វើឲ្យខ្ញុំមានការកក់ក្តៅក្នុងចិត្ត ទោះបីជាយើងមិនធ្លាប់ជិតស្និទ្ធពីមុនយ៉ាងណាក៏ដោយ ។ គាត់នាំខ្ញុំចូលក្នុងផ្ទះ ដោយក្តីរីករាយ ។

ផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណៃម មានបន្ទប់ទទួលភ្ញៀវមួយ បន្ទប់ទទួលទានដំណេកបី បន្ទប់ទឹកពីរ និង ផ្ទះបាយតូចមួយ ។ នៅក្នុងបន្ទប់ទទួលភ្ញៀវ មានមនុស្ស ៥ ឬ ៦ នាក់ នៅក្នុងវ័យអាយុ ៣០ ប្លាយឆ្នាំ កំពុងនាំគ្នាលេងបៀ ។ ពួកគេសុទ្ធតែជាអ្នកមានសំណាង បានទទួលអាហារូបករណ៍ពីរដ្ឋាភិបាលបារាំង

ឲ្យមកធ្វើកម្មសិក្សា ឬ បន្តវិជ្ជាបន្ថែមនៅទីក្រុងប៉ារីស ។ ពួកគេច្រើនជាវេជ្ជបណ្ឌិត ដូចលោក ស៊ូ ណៃម ដែរ ដែលត្រូវសិក្សាផ្នែកមុខជំនាញឯកទេសនៃវិជ្ជាពេទ្យ ។ លោកស្រី ស៊ូ ណៃម បានណែនាំខ្ញុំឲ្យស្គាល់មនុស្សទាំងនោះ ដែលហាក់ដូចជាមិនសូវយកចិត្តទុកដាក់ចំពោះវត្តមានរបស់ខ្ញុំ ដោយពួកគេកំពុងតែជក់អារម្មណ៍ក្នុងល្បែងរបស់គេ ។ ក្រោយពីបាននិយាយមួយម៉ាត់ពីរម៉ាត់ជាមួយខ្ញុំ លោកវេជ្ជបណ្ឌិត ស៊ូ ណៃម ក៏ត្រឡប់ទៅចូលរួមលេងល្បែងជាមួយក្រុមមិត្តភក្តិរបស់គាត់ ដោយទុកឲ្យភរិយានៅសំណេះសំណាលជាមួយខ្ញុំ ។

ខ្ញុំដើរត្រង់ឆ្ពោះទៅផ្ទះបាយដែលនៅទីនោះ ខ្ញុំទម្លាក់វ៉ាលីសទុក ។ នៅក្នុងវ៉ាលីសនោះ មានអង្ករ ១៥ គីឡូក្រាម និង សាច់ងៀតមួយចំនួន ។ ខ្ញុំនិយាយលេងសាសងពាក្យសំដីមួយរយៈជាមួយលោកស្រី ស៊ូ ណៃម ដោយនាំព័ត៌មានថ្មីៗពីប្រទេសកម្ពុជា ។ នៅពេលទទួលទានបាយថ្ងៃត្រង់មកដល់ ខ្ញុំក៏ជួយរៀបចំទីកន្លែងសំរាប់ទទួលទានបាយទាំងអស់គ្នា ។ តាមពិត យើងទទួលទានបាយផ្ទាល់លើកំរាលក្រដាសកាសែត ដែលយើងក្រាលលើឥដ្ឋ ។ យើងទាំងអស់គ្នាចូលរួមបាយជុំគ្នាដំកង់ជារង្វង់ដ៏ធំមួយ ។ នៅពេលបាយរួច អ្នកខ្លះបន្តលេងបៀតទៅទៀត អ្នកខ្លះសំរាកដេកថ្ងៃ អ្នកខ្លះត្រឡប់ទៅផ្ទះពួកគេវិញ ។ ដោយខ្ញុំជាមនុស្សថ្មី និងក្មេងជាងគេ ខ្ញុំក៏ជួយលាងចានលោកស្រី ស៊ូ ណៃម ផងដែរ ។

លោកវេជ្ជបណ្ឌិត ស៊ូ ណៃម មានវ័យ ៣០ ប្លាយឆ្នាំ ។ គាត់មានសម្បុរខ្មៅដូចលោក លន់ នល់ មាឌគាត់ធំមាំលើសពីជនជាតិខ្មែរធម្មតា ។ គាត់ជាមនុស្សមានសុខភាពល្អ រាងក្រអាញ សមរម្យ មិនធាត់កំប៉េងកំប៉ោង ។ លោកវេជ្ជបណ្ឌិតនេះ មានប្រជាប្រិយភាពណាស់ ក្នុងចំណោមសហគមន៍ខ្មែរនិយមរបបសាធារណរដ្ឋនៅប្រទេសបារាំង ។ គាត់មានទំនាក់ល្អជាមួយរដ្ឋាភិបាលខ្មែរលោក លន់ នល់ ។ គាត់ជាអ្នកគាំទ្រយ៉ាងខ្លាំងក្លាចំពោះរបបសាធារណរដ្ឋ និង ប្រឆាំង

យ៉ាងចេញមុខចំពោះរបបរាជានិយម ។

ខ្ញុំមិនបានដឹងថាគាត់មានវិជ្ជាឯកទេសអ្វីច្បាស់លាស់នោះទេ ក៏ប៉ុន្តែខ្ញុំឃើញគាត់ឧស្សាហ៍ព្យាយាមធ្វើកិច្ចការ ដែលគាត់យកពីមហាវិទ្យាល័យពេទ្យមកធ្វើនៅផ្ទះ ។ នៅពេលទំនេរ គាត់ឆ្លៀតលេងបៀម្នាក់ឯង ឬ លេងបៀជាមួយមិត្តភក្តិ ។ លោក ស៊ូ ណែម ចូលចិត្តលេងភ្នាល់ក្នុងល្បែងប្រណាំងសេះ ដែលគេហៅថា ជាក់សេ (Tiercé) ។ ក្នុងល្បែងនេះ គាត់មានវិធីសាស្ត្រត្រឹមត្រូវ ដោយសិក្សាតាមកាសែតជំនាញខាងកីឡាប្រណាំងសេះនេះ ។ គាត់ចាំឈ្មោះសេះល្បីៗស្ទើរតែទាំងអស់ ។ ក្រៅពីការសិក្សារៀនសូត្រផ្នែកវិជ្ជាពេទ្យនេះ លោកវេជ្ជបណ្ឌិត ស៊ូ ណែម ក៏ជាប់រវល់ក្នុងភារកិច្ចផ្សេងទៀតខ្លាំងណាស់ដែរ ។ នៅក្នុងផ្ទះគាត់ សម្លេងទូរស័ព្ទរោទ៍មិនចេះឈប់ ដោយសារមូលហេតុជាច្រើនដូចជា ដំណើរមកដល់ប្រទេសបារាំងនៃក្រុមមិត្តភក្តិ ដែលគាត់ត្រូវទៅទទួល ការរៀបចំលេងល្បែងនានា ឬ បុណ្យទាននៅស្ថានទូតខ្មែរ ឬ ការហៅរកឲ្យគាត់ជួយបំពេញឯកសារបែបបទផ្សេងៗ ។ មិត្តភក្តិរបស់គាត់ចេញចូលផ្ទះគាត់មិនដាច់ ទាំងថ្ងៃទាំងយប់ អ្នកខ្លះពីរ ឬ បីដងក្នុងមួយថ្ងៃ ។ លោកវេជ្ជបណ្ឌិត ស៊ូ ណែម មានទំនាក់ទំនងល្អជាមួយអ្នកជិតខាងរបស់គាត់ ។ ពួកគេមិនដែលមកតវ៉ាអំពីការរំខានណាមួយឡើយ ។

លោកស្រី ស៊ូ ណែម មានអាយុប្រហែលជា ៣០ ឆ្នាំបន្តិចបន្តួច ហើយមានមាឌតូចជាងស្វាមីរបស់គាត់ ។ លោកស្រីមិនមែនជានារីដែលមានរូបសម្រស់ខ្លាំងក្លានោះទេ ក៏ប៉ុន្តែគាត់មានមុខមាត់ជាស្ត្រីខ្មែរ ដែលមានទឹកមុខស្រស់ញញឹមជានិច្ច ។ លោកស្រីជាមេផ្ទះដ៏ប្រពៃ ដែលយកចិត្តទុកដាក់ថែរក្សាគ្រួសារយ៉ាងខ្ជាប់ខ្ជួន ។ លោកស្រីជាអ្នកពូកែនិយាយ គាត់មានរឿងនិយាយមិនចេះចប់ ។ មួយថ្ងៃៗគាត់ចំណាយពេលជាច្រើននិយាយតាមទូរស័ព្ទ ។

លោកស្រីទទួលរាប់អានខ្ញុំភ្លាមៗ ហើយមិនយូរប៉ុន្មាន យើងក៏ក្លាយទៅជាមិត្តជិតស្និទ្ធ ឬ ជាដៃគូក្នុងការងារផ្ទះទាំងមូល ។ លោកស្រីទើបមកដល់ប្រទេសបារាំងប្រមាណបីខែ មុនខ្ញុំតែប៉ុណ្ណោះ ។ គាត់មានកូនតូចៗពីរនាក់ ប្រុសម្នាក់ ស្រីម្នាក់ ។ គាត់មិនបានយកកូនស្រីតូចរបស់គាត់ មកនៅជាមួយឯប្រទេសបារាំងនោះទេ ។ គាត់យកតែកូនប្រុសច្បងអាយុប្រាំឆ្នាំ មកនៅជាមួយ ។

នៅក្នុងផ្ទះបាយនៅថ្ងៃទីមួយដែលខ្ញុំមកដល់ប្រទេសបារាំងនោះ ខ្ញុំព្យាយាមរៀនជិះម៉េត្រូគឺ រទេះភ្លើងរត់ក្រោមដី ដោយខិតខំមើលផែនទី ព្រោះខ្ញុំចង់ចេះធ្វើដំណើរដោយខ្លួនឯង ដោយមិនចាំបាច់ឲ្យមានគេជូនទៅណាមកណាឡើយ ។ កាលខ្ញុំនៅស្រុកខ្មែរ ខ្ញុំគ្រោងថានៅថ្ងៃទីមួយ ពេលមកដល់ភ្លាម ខ្ញុំត្រូវធ្វើដំណើរទៅការិយាល័យអន្តោប្រវេសន៍នៅទីក្រុងប៉ារីស ដើម្បីសុំលិខិតអនុញ្ញាតស្នាក់នៅភ្លាម ។ ក៏ប៉ុន្តែតាមពិត បែបបទនៃការសុំលិខិតអនុញ្ញាតស្នាក់នៅនោះមានសភាពស្មុគស្មាញ មិនមែនងាយស្រួលដូចខ្ញុំស្មាននោះទេ ។ ខ្ញុំត្រូវធ្វើដំណើរដោយខ្លួនឯងដោយត្រូវនាំយកទៅជាមួយនូវឯកសារមួយចំនួនដូចជា លិខិតបញ្ជាក់ធនធានលិខិតស្នាក់នៅ និង វិញ្ញាបនប័ត្ររបស់សាលារៀន ដែលខ្ញុំមានបំណងចូលរៀន ។ ដូច្នេះគំរោងផែនការដែលខ្ញុំគិតនៅស្រុកខ្មែរនោះ មិនបានសំរេចភ្លាមៗទេ ។

ម្យ៉ាងទៀត បញ្ហាសំខាន់មួយទៀតនោះគឺ ខ្ញុំត្រូវដោះស្រាយរកទីកន្លែងស្នាក់នៅជាអចិន្ត្រៃយ៍រយៈពេលវែងផង ។ លោក និង លោកស្រីវេជ្ជបណ្ឌិត ស៊ូណែម មានចិត្តល្អ ដោយបានទទួលស្វាគមន៍ខ្ញុំ ក៏ប៉ុន្តែនៅផ្ទះរបស់គាត់នោះ ពុំមានបន្ទប់ ឬ គ្រែណាមួយដែលនៅទំនេរឡើយ ។ ក្នុងរយៈពេលបីថ្ងៃខាងមុខ ប្រសិនបើខ្ញុំអាចរង់ចាំ បន្ទប់មួយអាចនៅទំនេរ ដោយហេតុថានិស្សិតម្នាក់ដែលកំពុងស្នាក់នៅនោះ នឹងរើទៅនៅទីកន្លែងផ្សេងនាពេលខាងមុខ ។ មនុស្សម្នាក់ទៀតដែលនៅក្នុងបន្ទប់នោះដែរ ជាមន្ត្រីជាន់ខ្ពស់នៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ នៅពេលដែល

ខ្ញុំទៅដល់ និស្សិតដែលត្រូវរើទៅនៅកន្លែងផ្សេងនោះ មិនបាននៅក្នុងបន្ទប់នោះទេ គេកំពុងតែទៅដើរលេងនៅក្រៅក្រុង តែគេនឹងត្រឡប់មកវិញនៅថ្ងៃស្អែក ដើម្បីរៀបចំខោអាវអីវ៉ែអីវ៉ាន់ទៅនៅកន្លែងថ្មីរបស់គេ ។ ដូច្នេះយប់ទីមួយនៅប្រទេសបារាំងនេះ ខ្ញុំអាចសំរាកនៅក្នុងបន្ទប់ទំនេរនោះបានមួយយប់ ក៏ប៉ុន្តែស្អែកឡើង ខ្ញុំត្រូវចេញទៅរកសណ្ឋាគារ ដើម្បីសំរាកយ៉ាងហោចក៏បីថ្ងៃដែរ ទើបអាចវិលត្រឡប់មកនៅផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណៃម វិញ ។

បន្ទាប់ពីពេលបាយថ្ងៃត្រង់រួចមក លោកវេជ្ជបណ្ឌិត ស៊ូ ណៃម បានជូនដំណើរខ្ញុំទៅចែកចាយសំបុត្រ និង វត្ថុអនុស្សាវរីយ៍ដែលខ្ញុំនាំយកមកពីប្រទេសខ្មែរ ទៅចែកជូនញាតិមិត្តខ្មែរៗ ដែលស្នាក់នៅក្នុងសង្កាត់នានាក្នុងទីក្រុងប៉ារីស ។ លោកវេជ្ជបណ្ឌិត ស៊ូ ណៃម ហាក់ដូចជាស្គាល់អ្នកទទួលលិខិត និង អ្នកទទួលវត្ថុអនុស្សាវរីយ៍ទាំងនោះស្ទើរតែទាំងអស់ ។ លោកវេជ្ជបណ្ឌិតបររថយន្តចំណាស់បន្តិចទៅហើយនោះ ឆ្លងកាត់សង្កាត់នានាតាមផ្លូវដ៏ធំទូលាយ តែពោរពេញទៅដោយរថយន្តយ៉ាងណែនណាន់តាន់តាប់ ។ ដោយសារការធ្វើដំណើរតាមរថយន្តដែលត្រូវឈប់ញឹកញាប់ដោយសារភ្លើងសញ្ញាចរាចរ ក្រហម ខៀវ បិទបើកជាច្រើនកន្លែងនោះ បានធ្វើឲ្យខ្ញុំកើតជម្ងឺពុលរថយន្តស្ទើរទ្រាំពុំបាន ។ នៅពេលនោះ ខ្ញុំគិតតែខំបិទភ្នែក ដោយមិនបានឆ្លៀតឱកាសមើលទិដ្ឋភាពដ៏ស្រស់បំព្រងនៃទីក្រុងប៉ារីសឡើយ ។

លោកវេជ្ជបណ្ឌិត ស៊ូ ណៃម ហាក់ដូចជាសប្បាយរីករាយក្នុងចិត្ត ក្នុងការជួយបំរើសេវានានា ជូនដល់សមាគមខ្មែរនៅប្រទេសបារាំងនោះណាស់ ។ ចំពោះខ្ញុំ គាត់ធ្វើហាក់ដូចជាគាត់ និង ខ្ញុំ ជាបងប្អូនបង្កើតនឹងគ្នាដូច្នោះដែរ ។ នៅពេលយើងត្រឡប់ដល់ផ្ទះវិញ ម្ហូបអាហារពេលល្ងាចត្រូវបានរៀបចំហើយជាស្រេច ។ ជាថ្មីម្តងទៀត ខ្ញុំជួយធ្វើការប្រពន្ធលោក ស៊ូ ណៃម ក្នុងការរៀបចំទីកន្លែងបរិភោគអា

ហារពេលល្ងាច ដូចពីពេលព្រឹកដែរ ។ ដោយសារតែមានការខុសពេលវេលារវាង ប្រទេសខ្មែរ និង ប្រទេសបារាំង នៅពេលទទួលទានអាហារពេលល្ងាចរួចហើយ ខ្ញុំហាក់ដូចជាមានភាពងោកងុយយ៉ាងខ្លាំងស្ទើរតែបើកភ្នែកពុំរួច ហើយបន្ទាប់មក ខ្ញុំក៏លង់លក់ទទួលទានដំណេកយ៉ាងស្កប់ស្កល់រហូតទល់ភ្លឺ ។

ពេលព្រឹកឡើងខ្ញុំភ្ញាក់មុនគេ នៅពេលដែលអ្នកឯទៀតកំពុងតែនៅលង់ លក់នៅឡើយ ។ ពេលងូតទឹកជំរះខ្លួនរួចហើយ ខ្ញុំក៏សំរេចចិត្តដើរចេញទៅក្រៅផ្ទះ តែម្នាក់ឯង ។ ខ្ញុំមានបំណងដើរជុំវិញតំបន់ជិតៗផ្ទះនោះ ដែលកំពុងបិតនៅក្នុង សភាពស្ងាត់ជ្រងំនាពេលព្រឹកព្រហាមនៅឡើយ ។ ខ្ញុំដើរតាមផ្លូវ វីឡា ដឺ បែលឡែរ (Villa de Bel Air) រួចបត់ឆ្វេងឆ្ពោះទៅមហាវិថី ដឺវ៉ាំងសែន (de Vincennes) ។ ខ្ញុំមិនហ៊ានទៅឆ្ងាយទេ ព្រោះខ្លាចវង្វេងផ្លូវ ។ ខ្ញុំពុំឃើញមានសកម្មភាពអ្វីជាធំដុំនៅ ឡើយទេ ព្រោះធម្មតាជីវភាពប្រចាំថ្ងៃដ៏ប្រញឹករបស់ប្រជាជននៅទីក្រុងប៉ារីសនឹង ត្រូវចាប់ផ្តើមក្នុងពេលមួយទៅពីរម៉ោងទៀតឯណោះ ។ នៅចម្ងាយប្រហែលជាម្ភៃ ម៉ែត្រពីផ្ទះ ខ្ញុំសង្កេតឃើញផ្ទះលក់នំប៉័ងចាប់ផ្តើមបើកលក់ហើយ ក៏ប៉ុន្តែនៅមិន ទាន់មានអតិថិជនចេញចូលច្រើននៅឡើយទេ ។ ហាងឯទៀតដែលនៅតាមមហា វិថីក៏នៅមិនទាន់បើកទ្វារដែរ ។

នៅតាមចិញ្ចើមផ្លូវ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ដោយសង្កេតឃើញមាន ទឹកហូរផតផាយប់ឈរ ។ តាមពិត គេបង្ហូរទឹកនេះ ដើម្បីលាងសំអាតចង្អូរផ្លូវ ។ ខ្ញុំ មានអារម្មណ៍ដូចជាមនុស្សចម្លែក មករស់នៅក្នុងទីក្រុងធំ ដូចពាក្យនិយាយទូទៅ ថាអ្នកស្រែចូលក្រុងដូច្នោះដែរ ។ មែន ខ្ញុំជាជនបរទេសមករស់នៅក្នុងប្រទេសដទៃ ដែលអ្វីៗខុសប្លែកពីស្រុកខ្មែរទាំងអស់ សូម្បីតែក្លិនដែលហើរចេញពីធុងសំរាម ឬ ពី ផ្ទះបាយក៏ជាការចម្លែកសំរាប់ខ្ញុំដែរ ។ ខ្ញុំត្រូវប្រើពេលវេលាពីពីរទៅបីថ្ងៃទើបស៊ាំនឹង ក្លិននោះ ។ អ្វីដែលខ្ញុំចាប់អារម្មណ៍ទីមួយនោះគឺ ទំហំដ៏ធំធេងនៃហេដ្ឋារចនាសម្ព័ន្ធ

ដែលខ្ញុំពុំធ្លាប់ជួបប្រទះសោះដូចជា៖ វិថី វុក្ខវិថី មហាវិថី ស្ពាន ផ្លូវក្រោមដី និង ប្រព័ន្ធទូរគមនាគមន៍ អគ្គិសនី ឬ ប្រព័ន្ធទឹកស្អាតជាដើម ។ ភាពផ្ទុយស្រឡះគ្នារវាងប្រទេសខ្មែរដ៏តូច ដែលមានភាពក្រីក្រ ហើយដែលស្ថិតនៅក្នុងសង្គ្រាមផង និង ប្រទេសបារាំងនាពេលនោះមានកម្រិតខុសគ្នាដូចមេឃ និង ដី ។ ខ្ញុំគិតក្នុងចិត្តថាគឺហេដ្ឋារចនាសម្ព័ន្ធនេះហើយ ដែលជាមូលដ្ឋាននៃការអភិវឌ្ឍ ។

នៅពេលខ្ញុំត្រឡប់មកផ្ទះវិញ លោកវេជ្ជបណ្ឌិត ស៊ូ ណែម និង ភរិយាគាត់ កំពុងទទួលទានអាហារពេលព្រឹក ។ ខ្ញុំក៏ចូលរួមតុជាមួយពួកគាត់ ដោយនាំយកនូវនំប៉័ងក្ដៅស្រួយបួនដើមមកជាមួយ ដែលខ្ញុំបានទិញពីហាងលក់នំប៉័ងក្បែរផ្ទះ ។ នំប៉័ងបារាំងមានរសជាតិឆ្ងាញ់ពិសារណាស់ ខ្ញុំចូលចិត្ត ហើយខ្ញុំនឹកថាខ្ញុំអាចទទួលទាននំប៉័ងនេះទទេមួយដើមម្នាក់ឯងក៏បាន ។ បន្ទាប់ពីទទួលទានអាហារពេលព្រឹករួច លោក និង លោកស្រីវេជ្ជបណ្ឌិត ស៊ូ ណែម បានបបួលខ្ញុំជិះរថយន្ត ទៅលេងមិត្តភក្ដិរបស់គាត់ និង ទៅផ្សារមេឃមួយនៅក្នុងសង្កាត់ ១២ ទៀត ។ ដូច្នេះ ខ្ញុំក៏ត្រូវបានចេញក្រៅម្ដងទៀត រួចយើងវិលត្រឡប់មកផ្ទះវិញ នៅពេលថ្ងៃត្រង់ ។

នៅពេលរសៀល និស្សិតខាងកុំព្យូទ័រដែលបំរុងគ្រែទុកឲ្យខ្ញុំនោះ បានត្រឡប់ពីដំណើរកំសាន្តរបស់គេមកវិញ ។ និស្សិតនោះឈ្មោះ បែល គេត្រឡប់មកផ្ទះវិញ ដើម្បីរៀបចំខោអាវ និង ប្រដាប់ប្រដារ ដើម្បីរើទៅនៅទីក្រុងកុមព្យែង (Compiègne) ។ បែល មានអាយុច្រើនជាងខ្ញុំ ហើយគេក៏ជួយបង្រៀនខ្ញុំឲ្យចេះជិះម៉េត្រូ ។ ពួកយើងទិញសំបុត្រម៉េត្រូ និង ផែនទីក្រុងប៉ារីសមួយច្បាប់ ។ យើងទាំងពីរនាក់ធ្វើដំណើរតាមរទេះភ្លើងក្រោមដី តាមខ្សែបន្ទាត់នៃដំណើរក្រោមដីនោះ ទៅតាមស្ថានីយជាច្រើន ។ ក្នុងឱកាសនោះ ខ្ញុំក៏ឆ្លៀតទៅរកជួលសណ្ឋាគារដើម្បីស្នាក់នៅបណ្ដោះអាសន្ន ។ យើងរកបានសណ្ឋាគារមួយដែលមានឈ្មោះថា តេមីនុស ដឺ ឡា ប៉ក ដកឡេអង់ (Terminus de la Porte d'Orléans) ។

បន្ទប់សណ្ឋាគារដែលខ្ញុំជួលនោះ ជាបន្ទប់តូចដែលមានតែគ្រែដេកមួយ និង កន្លែងងូតទឹកមួយតែប៉ុណ្ណោះ ។ ដូច្នេះ នៅយប់ទីពីរនៅប្រទេសបារាំង ខ្ញុំសំរាកនៅសណ្ឋាគារ ។ ព្រឹកឡើង ខ្ញុំទៅផ្ទះលោក ស៊ូ ណៃម រហូតទទួលទានបាយរួច ទើបត្រឡប់មកសណ្ឋាគារនេះវិញ ។ តាំងពីពេលដែលខ្ញុំបានជួប បែល នៅលើកទីមួយនោះ ខ្ញុំក៏បែកពីយុវជននេះរហូតមក ។ នៅទីបំផុត ខ្ញុំក៏ចេញពីសណ្ឋាគារមកនៅជាមួយលោក ស៊ូ ណៃម វិញ នៅពេល បែល លែងស្នាក់នៅទីនោះជាស្ថាពរ ។

ក៏ប៉ុន្តែ ថ្វីបើខ្ញុំរកបានកន្លែងស្នាក់នៅជាប់លាប់យ៉ាងណាក៏ដោយ ក៏ខ្ញុំនៅមានការខ្វល់ខ្វាយអំពីរឿងមួយទៀតគឺ មធ្យោបាយរស់នៅៗប្រទេសបារាំង ។ បញ្ហាចោទឡើងថា តើខ្ញុំអាចរស់នៅ និង ចិញ្ចឹមខ្លួនឯងបានតាមវិធីណា? ពីប្រទេសកម្ពុជា ខ្ញុំបានទទួលទិដ្ឋាការបារាំងឲ្យមកស្នាក់នៅមិនលើសពីបីខែឡើយ ។ ខ្ញុំយល់ថារឿងទិដ្ឋាការនេះ អាស្រ័យលើស្ថានភាពហិរញ្ញវត្ថុ ។ ខ្ញុំគិតថា ប្រសិនបើខ្ញុំមានការធ្វើ ខ្ញុំអាចរកប្រាក់កាសខ្លះ ហើយខ្ញុំច្បាស់ជានឹងទទួលការអនុញ្ញាតឲ្យស្នាក់នៅដ៏យូរមិនខានឡើយ ។ ដូច្នេះខ្ញុំត្រូវធ្វើយ៉ាងណារកការធ្វើជាបន្ទាន់ ។ បើសិនជាខ្ញុំមានការធ្វើ ខ្ញុំអាចបញ្ជាក់អំពីប្រាក់ចំណូលរបស់ខ្ញុំ នៅពេលទៅដាក់ពាក្យសុំបន្តច្បាប់ស្នាក់នៅក្នុងប្រទេសបារាំងតទៅទៀត ។ ម្យ៉ាងទៀត ជាការជាក់ស្តែង ខ្ញុំត្រូវទៅរកការធ្វើឲ្យបាន ព្រោះថាប្រាក់បន្តិចបន្តួចដែលខ្ញុំបានយកពីប្រទេសខ្មែរមកនោះ ខ្ញុំបានចាយវាយស្ទើរតែទាំងអស់ ។ គ្រាន់តែមកដល់ប្រទេសបារាំងមួយអាទិត្យ ខ្ញុំបានចាយអស់ជាងពាក់កណ្តាលទៅហើយ ។ ម្យ៉ាង ខ្ញុំចំណាយបង់ថ្លៃសណ្ឋាគារ និង ទិញរបស់របរជាវត្ថុអនុស្សាវរីយ៍ ផ្ញើទៅប្រទេសខ្មែរជូនឪពុកម្តាយ បងប្អូនខ្ញុំ ដែលខ្ញុំមានការនឹករលឹកជាខ្លាំង ។ ម្យ៉ាងទៀត ពេលមកដល់ភ្លាមខ្ញុំសង្កេតឃើញរបស់របរអ្វីក៏ល្អខុសប្លែកពីនៅប្រទេសខ្មែរ ហើយដែលចេះតែទាក់

ទាញចិត្តខ្ញុំឲ្យចេះតែចង់បានចង់ទិញ ដើម្បីផ្ញើទៅឪពុកម្ដាយ បងប្អូនឯទីបឆ្ងាយ ។ ដូច្នេះ ខ្ញុំត្រូវការរកការងារជាបន្ទាន់ជៀសមិនរួច ។

# ជាដំបូងខ្ញុំខំរកការធ្វើ

ដំណាក់កាលទីមួយ ខ្ញុំគិតថាខ្ញុំត្រូវតែទាក់ទងជាមួយសមាគមវិជ្ជាជីវៈខាងផ្នែកគណនេយ្យ អេស សេ អេហ្វ (SCF) ជាដាច់ខាត ។ កាលពីនៅស្រុកខ្មែរ ខ្ញុំធ្លាប់បានសរសេរសំបុត្រទាក់ទងទៅសមាគម អេស សេ អេហ្វ ដើម្បីឲ្យ សមាគមនោះជួយរកការងារឲ្យធ្វើម្ដងរួចហើយ ។ សមាគមនោះឲ្យយោបល់ថា ខ្ញុំត្រូវមកបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខនិយោជក ដែលគេត្រូវការធ្វើសម្ភាសន៍ មុននឹងរើសឲ្យធ្វើការ ។ ដូច្នេះ ខ្ញុំក៏សំរេចចិត្តទៅជួបសមាគមនេះ នៅឯទីស្នាក់ការដោយសង្ឃឹមថា គេនឹងជួយរកការងារឲ្យខ្ញុំធ្វើ ។ នៅពេលខ្ញុំទៅដល់ទីស្នាក់ការមន្ត្រីសមាគមទទួលខ្ញុំយ៉ាងរាក់ទាក់ ។ ក៏ប៉ុន្តែសមាគមមិនអាចជួយខ្ញុំបានទេ នៅពេលនោះ ព្រោះខែ សីហា ជាខែនៃវិស្សមកាលដែលក្រុមហ៊ុននានាត្រូវបិទទ្វារឈប់សំរាកស្ទើរតែទាំងអស់ ។ ខ្ញុំក៏ពុំបាននឹកដល់ពេលវេលានៃការឈប់សំរាករបស់ប្រជាជនបារាំងនោះឡើយ ។ តែមន្ត្រីសមាគមបានផ្ដល់យោបល់ឲ្យខ្ញុំរង់ចាំដល់ខែ កញ្ញា ដើម្បីទាក់ទងគ្នាជាថ្មីម្ដងទៀត ព្រោះពេលនោះក្រុមហ៊ុនបារាំងនឹងចាប់បើកធ្វើការឡើងវិញ ។ ដូច្នេះខ្ញុំក៏គ្មានជំរើសអ្វី ក្រៅពីរង់ចាំមួយខែទៀតតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែសេចក្ដីត្រូវការខាងលុយកាក់របស់ខ្ញុំ ចេះតែកើនឡើងហូរហែឥតឈប់ឈរ ។ ដូច្នេះទំរាំនឹងទៅរកជំនួយពីសមាគម អេស សេ អេហ្វ ទៀតនោះខ្ញុំក៏ចាប់ផ្ដើមដើរគោះទ្វារការិយាល័យជំនាញការគណនេយ្យ ដែលខ្ញុំប្រទះ ឃើញតាមផ្លូវ និង ដែលមិនទាន់បិទទ្វារសំរាក ។ ខ្ញុំចាប់ផ្ដើមដើររកនៅក្បែរៗផ្ទះ ។

និយោជកជាច្រើនឆ្លើយប្រាប់ខ្ញុំថា គេមិនត្រូវការបុគ្គលិកបន្ថែមទៀតទេ ឯអ្នកឯទៀតនិយាយថាអ្នកឯងគួរតែទៅរកការធ្វើឯស្ថានទូតអ្នកឯងទៅ ។

នៅពាក់កណ្តាលខែ កញ្ញា ខ្ញុំត្រឡប់ទៅជួបមន្ត្រីសមាគម អេស សេ អេហ្វ ម្តងទៀត ។ លើកនេះខ្ញុំមានភ័ព្វសំណាងល្អ ដោយបានជួបនារីចំណាស់ម្នាក់អាយុប្រមាណជាង ៥០ ឆ្នាំ ឈ្មោះលោកស្រី ស្លាកឡូ (Charlot) ដែលជាប្រធានផ្នែករកការងារឲ្យធ្វើរបស់សមាគម ។ លោកស្រីរើរកឃើញសំបុត្រដែលខ្ញុំ ផ្ញើពីប្រទេសកម្ពុជា និង សំណុំលិខិតផ្ទាល់ខ្លួនរបស់ខ្ញុំ ។ គាត់ពិនិត្យមើលបញ្ជីជ្រើសរើសបុគ្គលិកដែលពួកនយោជកផ្ញើមកសមាគម រួចគាត់និយាយមកខ្ញុំថា "អ្នកគួរតែធ្វើការក្នុងទីក្រុងប៉ារីសនៅជិតៗផ្ទះរបស់អ្នក" ។ ដើម្បីបានការធ្វើភ្លាមៗ ខ្ញុំនិយាយជំរាបលោកស្រី ស្លាកឡូ ថា ខ្ញុំត្រៀមខ្លួនទទួលធ្វើការងារអ្វីក៏បាន ការងារទាបតូចក៏បាន ។ តាមពិតបើពិនិត្យបទពិសោធន៍នៅកម្ពុជា ខ្ញុំជាគណនេយ្យករពេញសិទ្ធិ ក៏ប៉ុន្តែនៅទីនេះ ខ្ញុំត្រៀមទទួលការងារតូចទាបឋានៈត្រឹមជំនួយការក៏អាចទទួលបាន ។ លោកស្រី ស្លាកឡូ ទូរស័ព្ទទៅនិយោជកបីនាក់ ដើម្បីរៀបចំសំរួលណាត់ពេលវេលាឲ្យខ្ញុំទៅជួប ។ លោកស្រី ស្លាកឡូ ហាក់ដូចជាមាននិស្ស័យជាមួយខ្ញុំ ។ គាត់ហៅខ្ញុំថា "អ្នកប្រុសតូច" "Mon petit" និង និយាយពន្យល់យ៉ាងលំអិតអំពីអាស័យដ្ឋាន ជាទីដែលខ្ញុំត្រូវទៅជួបនិយោជក ដើម្បីធ្វើសម្ភាសន៍ចូលធ្វើការ ។

សូមបញ្ជាក់ថា នៅសម័យនោះ ការងារផ្នែកគណនេយ្យនៅប្រទេសបារាំងសម្បូណ៌ណាស់ យើងមិនពិបាករង់ចាំអស់ពេលដ៏យូរនោះឡើយ ។ ម្យ៉ាងទៀតខ្ញុំក៏គ្មានបំណងដាក់លក្ខខណ្ឌអ្វីចំពោះការងារនោះទេ ។ ការណាត់ជួបលើកទីមួយ ជាការណាត់ធ្វើសម្ភាសន៍ដើម្បីតំណែងជំនួយការគណនេយ្យករ នៅក្នុងឧទ្ទកាល័យជំនាញការគណនេយ្យឯករាជ្យមួយ ។ នៅពេលចប់សម្ភាសន៍គេប្រាប់ឲ្យខ្ញុំរង់ចាំចម្លើយដែលនឹងផ្តល់នៅពេលក្រោយ ។ ការណាត់លើកទីពីរ ក៏សំរាប់មុខតំ

ណែងជំនួយការគណនេយ្យករដែរ ក៏ប៉ុន្តែគឺ ជាការងារមួយ ដែលស្ថិតនៅក្នុងក្រុមហ៊ុនទេសចរណ៍ស្ថិតនៅក្នុងតំបន់ប៉ាឡេរ៉ូយ៉ាល់ (Palais Royal) ក្នុងសង្កាត់ទីមួយនៃទីក្រុងប៉ារីស ។ ក្រុមហ៊ុននោះ ស្ថិតនៅក្បែរសារមន្ទីរលូវ្រ (Louvre) និងសួនទ្វីលីរី (Tuillerie) ។

ធ្វើដំណើរតាមម៉េត្រូ ខ្ញុំឈប់នៅស្ថានីយប៉ាឡេរ៉ូយ៉ាល់ ។ ពីស្ថានីយប៉ាឡេរ៉ូយ៉ាល់ ខ្ញុំដើរសសៀរតាមវិថីលូវ្រ (Louvre) ។ បន្ទាប់ពីបានឆ្លងផ្លូវ ពីមួយទៅមួយ រហូតដល់ផ្លូវឈ្មោះវិថី ដឺ ឡេស្ហែល (de l'Echelle) ។ នៅកាច់ជ្រុងវិថីនេះ មានធនាគារមួយដាក់សញ្ញាភ្លើងពណ៌ជាអក្សរ បារាំងថា Change (ប្តូរប្រាក់) ។ មកដល់កាច់ជ្រុងធនាគារនេះបត់ស្តាំបន្តិច ខ្ញុំក៏ទៅដល់មុខអាគារនៃក្រុមហ៊ុនទេសចរណ៍មួយមានដាក់សញ្ញាថា ហ្វារ៉ូសហ្វ្រង់ (Pharos France) ដែលមានអាសយដ្ឋានលេខ ២ វិថី ដឺ ឡេស្ហែល (de l'Echelle) ។ ជាការគួរឲ្យឆ្ងល់ដែរចំពោះតួលេខ ២ នេះ ព្រោះនៅក្នុងបញ្ជីជាតិ ខ្ញុំកើតនៅថ្ងៃទី ២ ខែ វិច្ឆិកា ហើយខ្ញុំកំពុងតែស្នាក់នៅផ្ទះលេខ ២ វីឡា ដឺ បែល ឡែរ ( 2 Villa de Bel Air ) ។ ម្យ៉ាងទៀត នេះជាការណាត់ជួបសម្ភាសន៍លើក ទី ២ របស់ខ្ញុំដែរ ។

ក្រុមហ៊ុនទេសចរណ៍នោះជាក្រុមហ៊ុនតូច និង គ្រប់គ្រងបែបគ្រួសារ ។ គឺជាសហគ្រាសដែលមានបុគ្គលិកចំនួនតិចជាង ១០ នាក់ ក៏ប៉ុន្តែមានសកម្មភាពការងារជាប់រវល់មិនចេះឈប់ឈរ ។ តាមទ្វារកញ្ចក់ ខ្ញុំអាចមើលពីក្រៅឃើញនារីក្មេងៗពីរនាក់កំពុងឈរជជែកគ្នាដែលម្នាក់ទំនងជាអតិថិជន ។ នៅក្បែរនោះមានបុរសវ័យក្មេងម្នាក់ទៀត កំពុងនិយាយទូរស័ព្ទ ។ នៅបន្ទប់ឯក្រោយ ខ្ញុំឃើញបុរសវ័យចំណាស់បន្តិច កំពុងពិនិត្យសំណុំលិខិតទាំងឡាយក្រោមចង្កៀងបំភ្លឺដ៏តូចមួយដែលដាក់នៅលើតុការិយាល័យរបស់គាត់ ។ នៅពេលខ្ញុំចូលទៅដល់ខាងក្នុង នារីក្មេងម្នាក់ដែលមានពាក់វ៉ែនតាសផង បានបញ្ឈប់ការសន្ទនារបស់គាត់ ដើម្បីសួរ

នាំខ្ញុំ រួចចង្អុលបង្ហាញឲ្យខ្ញុំដើរតាមគាត់ឡើងជណ្ដើរតូចមួយទៅជាន់ខាងលើ ។ ប៉ុន្មាននាទីក្រោយមក ខ្ញុំបានដឹងថា នារីក្មេងនោះឈ្មោះ អង់ទាន់ណែត (Antoinette) ដែលជាបុត្រីរបស់ម្ចាស់ហាងទេសចរណ៍នោះ ។

អង់ទាន់ណែត ជាកូនស្រីច្បងក្នុងចំណោមកូនស្រីពីរនាក់ របស់ថៅកែធំនៃហាងនោះ ។ ចំណែកឯបុរសក្មេង ដែលឈរនិយាយទូរស័ព្ទនោះ ឈ្មោះ រីស្ហា (Richard) ជាប្ដីរបស់នាង អង់ទាន់ណែត ។ បុរសចាស់ដែលកំពុងអានសំណុំលិខិតនោះ ឈ្មោះលោក ម៉េឡាតូ (Mélatos) ជាឪពុកមានាង ។ លោក ម៉េឡាតូ ធ្លាប់ធ្វើជាមេធាវីនៅប្រទេសក្រិក គាត់មានសញ្ញាប័ត្រថ្នាក់បណ្ឌិតខាងច្បាប់ ។

នៅឯជាន់ខាងលើនោះនាង អង់ទាន់ណែត បានប្រញាប់ ប្រញាល់បង្ហាញរូបខ្ញុំចំពោះស្ត្រីបីនាក់ បន្ទាប់មកនាងក៏ត្រឡប់ទៅធ្វើការវិញ ។ ក្នុងចំណោមស្ត្រីបីនាក់នោះ មានម្នាក់ឈ្មោះ ហេឡែន អាមីញែល (Helène Amielle) ដែល ជាម្ដាយរបស់ អង់ទាន់ណែត ឯនារីម្នាក់ទៀតគឺ ជាម្ដាយមីងរបស់នាង ។ ស្ត្រីទីបីឈ្មោះ អ្នកស្រី ដឺបែហ្ស (Debaize) ជានារីដែលមាន អាយុតិចជាងគេ ។ អ្នកស្រី ដឺបែហ្ស មានអាយុ ៤០ ឆ្នាំបន្តិចបន្តួច ។ គាត់ជាប្រធានក្រុមគណនេយ្យនៃក្រុមហ៊ុននេះ ។ គឺអ្នកស្រី ដឺបែហ្ស នោះហើយ ដែលជាអ្នកសម្ភាសន៍ និង ជាអ្នកសំរេចជ្រើសរើសរូបខ្ញុំ ឬ អត់ ។ ក៏ប៉ុន្តែ ជាការគួរឲ្យឆ្ងល់អ្នកស្រី ដឺបែហ្ស មិនគ្រាន់តែមិនធ្វើសម្ភាសន៍ខ្ញុំប៉ុណ្ណោះទេ គាត់បែរជាមកធ្វើការរៀបរាប់ដោយត្រួសៗ អំពីការងារដែលខ្ញុំត្រូវធ្វើ ប្រសិនបើខ្ញុំសុខចិត្តចូលធ្វើការក្នុងក្រុមហ៊ុនជាមួយគាត់ ។ អ្នកស្រីក៏បានឲ្យខ្ញុំដឹងពីសកម្មភាពការងាររបស់ក្រុមហ៊ុនទាំងមូលដែរ ។

អ្នកស្រី ដឺបែហ្ស គ្រប់គ្រងការងារគណនេយ្យ ដោយមានជំនួយការពីរនាក់ ម្នាក់គឺ លោកស្រី ម៉េឡាតូ ដែលត្រូវជាប្អូនថ្លៃរបស់ អ្នកស្រី ហេឡែន អាមីញែល និង ម្នាក់ទៀតឈ្មោះ ហ្សេសួអា (Jesua) ដែលមានអាយុជិតចូលនិវត្តន៍ទៅ

ហើយ តែប៉ុន្មានខែខាងមុខទៀតប៉ុណ្ណោះ ។ លោកស្រី ម៉េឡាតូ បំពេញការងារផ្នែកគណនេយ្យទូទៅ និង គណនេយ្យចំណូល ។ លោក ហ្សេស្ហួអា បំពេញការងារដូចជា អ្នកទទួលខុសត្រូវបេឡា និង ទំនាក់ទំនងធនាគារ ។ នៅពេលដែលខ្ញុំទៅធ្វើសម្ភាសន៍នោះ លោក ហ្សេស្ហួអា ពុំមានវត្តមាននៅទីនោះទេ ។ លោក ស្រី អាមីញ៉ែល ដែលជាភរិយាលោកថៅកែធំមានដើមកំណើត ជាជនជាតិក្រិក គាត់មិនមែនជាបុគ្គលិកប្រចាំថ្ងៃក្រុមគណនេយ្យនេះទេ ក៏ប៉ុន្តែគាត់មកជួយធ្វើការម្តងម្កាលដើម្បីត្រួតពិនិត្យការទារប្រាក់ជំពាក់ពីអតិថិជន ។ ជួនកាល លោកស្រី អាមីញ៉ែល និង លោកស្រី ម៉េឡាតូ សន្ទនាគ្នាជាភាសាក្រិក ដោយសារអ្នកស្រីទាំងពីរចេះនិយាយភាសានេះយ៉ាងស្ទាត់ជំនាញ ។

ការងារដែលខ្ញុំត្រូវធ្វើនាពេលខាងមុខ ជាការងារជំនួយការផ្ទាល់របស់អ្នកស្រី ដឺបែហ្ស គឺ រាល់កិច្ចការរបស់គាត់ទាំងអស់រាប់តាំងពីការចុះបញ្ជីការ ការកែតម្រូវគណនេយ្យ និង ការត្រៀមលិខិតបង់ពន្ធដារ ការងារផ្នែកសង្គមកិច្ច ការទារប្រាក់ជំពាក់ រហូតដល់ការធ្វើបញ្ជី ឬ តុល្យការប្រចាំឆ្នាំ ។ បើនិយាយឲ្យខ្លី ការងារអ្វីដែលអ្នកស្រីប្រធានធ្វើ ខ្ញុំត្រូវចេះធ្វើទាំងអស់ ។ ដូច្នេះខ្ញុំត្រូវធ្វើការក្រោមបង្គាប់ផ្ទាល់របស់គាត់ ។ ខ្ញុំនឹកក្នុងចិត្តថាការងារទាំងអស់នេះ ខ្ញុំអាចធ្វើបានទាំងអស់លើកលែងតែការងារខាងពន្ធដារ និង ខាងសង្គមកិច្ច ដែលមានលក្ខណៈ ខុសគ្នាពីការងារនៅឯស្រុកខ្មែរ ។ អ្នកស្រី ដឺបែហ្ស ឲ្យយោបល់ថា រឿងនេះគ្មានបញ្ហាអ្វីទេព្រោះជាដំបូងយើងអាចរៀនធ្វើការក្នុងផ្នែកនេះបាន ។ ក្រុមហ៊ុននេះបានស្នើផ្តល់ដល់ខ្ញុំនូវប្រាក់បៀវត្សប្រចាំខែចំនួន ១៤០០ ហ្វ្រង់ ។ នេះគឺ ជាប្រាក់បៀវត្សសំរាប់តួនាទីទាបបង្អស់ខាងផ្នែកវិជ្ជាជីវៈគណនេយ្យ ក៏ប៉ុន្តែ ចំពោះខ្ញុំ ខ្ញុំគិតថាសមល្មមសំរាប់កសាងជីវិតថ្មី នៅក្នុងប្រទេសបារាំងនេះហើយ ។ ដូច្នេះ ខ្ញុំក៏ប្រញាប់ប្រញាល់ទទួលយកការងារនេះភ្លាម ដោយគ្មានបង្អែបង្អង់ឡើយ ។ ឃើញដូច្នេះ

អ្នកស្រី ដឺបែហ្ស ចង់ឲ្យខ្ញុំចូលធ្វើការភ្លាមនៅរំពេចនោះតែម្តង ក៏ប៉ុន្តែខ្ញុំស្នើថាសូមរង់ចាំដល់ថ្ងៃស្អែក ព្រោះខ្ញុំត្រូវការរៀបចំខ្លួនប្រាណឲ្យសមរម្យមុននឹងចូលធ្វើការ ។ មុននឹងបញ្ចប់កិច្ចសម្ភាសន៍របស់យើង អ្នកស្រី ដឺបែហ្ស បាននាំខ្ញុំទៅជួបលោកហ្សក អាមីញែល (Georges Amielle) នៅក្នុងការិយាល័យរបស់គាត់ ។ លោកហ្សក អាមីញែល ជាថៅកែធំក្នុងក្រុមហ៊ុននេះ គាត់មានអាយុជាង ៥០ ឆ្នាំទៅហើយ ។ គាត់មានលក្ខណៈជាជនជាតិមកពីខាង មេឌីទែរ៉ាណេ (Méditerranée) ។ គាត់ពាក់វ៉ែនតា មាឌទាបក្រអាញ និយាយភាសាពីរ ឬ បីថែមពីលើភាសាបារាំង និង ក្រិក ។ លោកថៅកែធំចាប់ដៃខ្ញុំរលាក់ ហើយសរសើរអ្នកស្រីដឺបែហ្ស ដែលបានជ្រើសរើសបុគ្គលិកបានយ៉ាងឆាប់រហ័សយ៉ាងនេះ ។ លោកថៅកែធំទទួលស្វាគមន៍ខ្ញុំជាសមាជិកថ្មីនៃបុគ្គលិករបស់គាត់ ។

## អ្នកប្រុសតូច

ខ្ញុំចាកចេញពីក្រុមហ៊ុនហ្វារ៉ូសហ្វ្រង់ (Pharos France) ដោយសេចក្តីត្រេកអរ និង ក្តីរំភើបឥតឧបមា ។ ខ្ញុំសប្បាយចិត្តណាស់ ។ ខ្ញុំដើរផង លោតផងម្តងៗ ។ នៅពេលជិតទៅដល់ក្បែរស្ថានីយម៉េត្រូ ខ្ញុំឆ្លៀតទិញក្រវ៉ាត់កមួយដែលមានតម្លៃដប់ហ្វ្រង់ (10 Francs)[51] ព្រោះក្រវ៉ាត់កដែលខ្ញុំយកមកពីស្រុកខ្មែរនោះមិនត្រូវនឹងម៉ូតទំនើបនៅប្រទេសបារាំងនោះទេ ។ ខ្ញុំមិនប្រញាប់ទៅផ្ទះវិញភ្លាមទេ ខ្ញុំក៏មិនបន្តទៅធ្វើសម្ភាសន៍នៅកន្លែងទីបីផ្សេងទៀតដែរ ព្រោះខ្ញុំបានសំរេចថា ធ្វើការនៅក្នុងក្រុមហ៊ុនហ្វារ៉ូសហ្វ្រង់នេះហើយ ខ្ញុំមិនត្រូវកែប្រែចិត្តខ្ញុំទៀតឡើយ ។ ដូច្នេះ ខ្ញុំក៏ដើរទៅក្នុងហាងលក់ស្រាបៀរ រួចបញ្ជាទិញស្រាបៀរ លាយនឹងទឹកលី

[51] នៅសម័យនោះ ១ ដុល្លារអាមេរិក មានតម្លៃប្រហែល ៣ ហ្វ្រង់ ក្រោយមក ១ ដុល្លារស្មើ ៧ ហ្វ្រង់។

ម៉ូណាតដែលពួកបារាំងតែងហៅថាប៉ាណាស្ហេ (Panachée) មួយកែវយ៉ាងត្រជាក់ និង នំសាំងវិចដាក់សាច់ក្រកមួយដុំផង ។ នោះគឺជាអាហារថ្ងៃត្រង់ ដ៏ឆ្ងាញ់ពិសាមួយរបស់ខ្ញុំនៅប្រទេសបារាំង មិនគិតពីម្ហូបអាហារថ្ងៃត្រង់ប្រចាំថ្ងៃ ដែលខ្ញុំបានទទួលពីគ្រួសារលោក ស៊ូ ណៃម ទេនោះ ។

នៅពេលត្រឡប់មកផ្ទះវិញ ថ្ងៃរសៀលណាស់ទៅហើយ ពុំមានមនុស្សម្នាច្រើនគ្នាទេ ។ អ្នកស្រី ស៊ូ ណៃម កំពុងតែធ្វើម្ហូបនៅឯផ្ទះបាយដូចធម្មតា ។ គាត់មិនដែលដឹងថា ខ្ញុំធ្វើអ្វីខ្លះទេនៅពេលខ្ញុំចេញទៅក្រៅផ្ទះរាល់ថ្ងៃ ហើយគាត់ក៏មិនដែលសួរនាំពីសកម្មភាពរបស់ខ្ញុំដែរទេ ។ គាត់មិនដែលនឹកគិតដល់ថា ខ្ញុំអាចរកការងារធ្វើបានយ៉ាងឆាប់រហ័សបែបនេះទេ និង ជាពិសេសការងារនៅក្នុងការិយាល័យនោះឡើយ ។ ជាទូទៅ និស្សិតខ្មែរភាគច្រើន ដែលមកស្នាក់នៅប្រទេសបារាំងដោយខ្លួនឯង ដោយគ្មានជំនួយពីរាជរដ្ឋាភិបាល ច្រើនតែនាំគ្នាទៅធ្វើការនៅក្នុងភោជនីយដ្ឋានចិន ។ ខ្លះជាអ្នករត់តុ ខ្លះជាអ្នកលាងចាន ។

នៅពេលខ្ញុំប្រាប់គាត់ថា ខ្ញុំទើបតែរកបានការងារធ្វើជាជំនួយការផ្នែកគណនេយ្យនៅក្នុងក្រុមហ៊ុនទេសចរណ៍មួយនៅសង្កាត់លេខមួយ ទីក្រុងប៉ារីស អ្នកស្រី ស៊ូ ណៃម មានសេចក្ដីត្រេតអរជាអតិបរមា គាត់ទះដៃ និង ទជាក់ជើងលោតឡើងទៅលើ ពោរពេញទៅដោយអំណរ ។ គាត់និយាយថា "មូលី បើខ្ញុំជាម្ដាយប្អូនឯង ខ្ញុំនឹងលើកប្អូនឯងទូលតែម្ដង" ។ តាំងពីថ្ងៃនោះមក ដើម្បីជួយសំរាលបន្ទុកចំណាយប្រចាំផ្ទះ ខ្ញុំបានសន្យាថានឹងជូនប្រាក់ទៅគាត់ចំនួន ២០០ ហ្វ្រង់ក្នុងមួយខែ ។ អ្នកស្រីយល់ព្រមភ្លាម ។

ព្រឹកស្អែកឡើង ខ្ញុំរៀបចំខ្លួនចេញទៅធ្វើការ ដោយស្លៀកពាក់អាវធំ និង ចងក្រវ៉ាត់កដែលធ្វើឲ្យអ្នកនៅក្នុងផ្ទះទាំងប៉ុន្មានមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រោះ

ពួកគេធ្លាប់តែឃើញខ្ញុំស្លៀកក្រមានៅផ្ទះ និង ជួយលាងចានតែប៉ុណ្ណោះ ។ មិត្តភក្តិរបស់លោកវេជ្ជបណ្ឌិត ស៊ូ ណែម មួយចំនួនដែលជាកូនមន្ត្រីធំៗ ដែលធ្លាប់រស់នៅលើគំនរទ្រព្យសម្បត្តិ ប្រហែលជាមិនដែលនឹកដល់ថា ខ្ញុំអាចកែប្រែរូបរាងយ៉ាងឆាប់រហ័សដូច្នេះទេ ព្រោះខ្ញុំជាកូនអ្នកក្រ ប្រហែលមិនអាចធ្វើអ្វីកើតក្រៅពីបោសសំអាត និង ជួយលាងចាននោះឡើយ ។ ឥឡូវពួកគេចាប់ផ្តើមយល់ថា ខ្ញុំជាយុវជនមួយរូប ដែលមានសមត្ថភាពគ្រប់គ្រាន់ ។

នៅការិយាល័យ ខ្ញុំបានត្រូវសហសេវិកទាំងឡាយទទួលរាប់រកយ៉ាងឆាប់រហ័ស ។ ពួកនារីចាស់ៗទាំងនោះ ស្រឡាញ់រាប់អានខ្ញុំ ដូចអ្នកស្រី ស្តាកឡូ នៅសមាគម អេស សេ អេហ្វ ដែរ ។ ពួកគេហៅខ្ញុំថា "អ្នកប្រុសតូច" ជាថ្មីម្តងទៀត ។ ខ្ញុំខិតខំធ្វើការងាររបស់ខ្ញុំណាស់ ដើម្បីចិញ្ចឹមជីវិតផង ដើម្បីឲ្យសមនឹងទំនុកចិត្ត និង ការរាប់អានរបស់មេកើយរបស់ខ្ញុំផង ។ ខ្ញុំធ្វើរាល់ការងារទាំងអស់ដែលអ្នកស្រី ដឺបែហ្ស ដាក់ឲ្យធ្វើ ។ ជួនកាលខ្ញុំធ្វើការ ជំនួសលោក ហ្សេសួអា ដោយទៅបំពេញការងារនៅឯធនាគារ ជាពិសេសធនាគារមួយដែលឋិតនៅជិតមហោស្រពអូប៉េរ៉ា (Opera) ។ ខ្ញុំបានសាងនូវទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមគណនេយ្យរបស់យើង ។

នៅពេលសំរាកបាយថ្ងៃត្រង់ ពួកនារីៗរៀបចំម្ហូបអាហាររបស់គាត់នៅក្នុងផ្ទះបាយដ៏តូចមួយជាប់នឹងកន្លែងធ្វើការ ។ ចំណែកខ្ញុំ ខ្ញុំចូលចិត្តដើរតាមវិថីនានាចូលទៅទទួលទានសាំងវិច និង ស្រាបៀរនៅកន្លែងលក់ស្រាបៀរមួយក្នុងតំបន់នោះ ។ ចាប់ពីខ្ញុំចូលធ្វើការមក ខ្ញុំចំណាយលុយកាក់យ៉ាងប្រយ័ត្នប្រយែងបំផុត ព្រោះខ្ញុំពុំមាននៅសល់ប្រាក់ច្រើនទៀតទេនៅដំណាច់ខែ កញ្ញា នោះ ។ ខ្ញុំចំណាយប្រាក់តែទៅលើអ្វីដែលចាំបាច់បំផុត ឬ ជៀសពុំរួចដូចជា ប័ណ្ណមេត្រូ និង ម្ហូបអាហារថ្ងៃត្រង់ ។ បន្ថែមលើនេះនៅពេលខ្ញុំចាប់ផ្តើមចូលធ្វើការ ខ្ញុំបានចំណាយប្រាក់ទិញអាវរងារមួយ ត្រៀមនឹងរដូវត្រជាក់ ដែលនឹងធ្លាក់មកដល់នាពេលខាងមុខ ។

នៅតែពីរថ្ងៃទៀតដល់ថ្ងៃដាច់ខែបើកលុយ ខ្ញុំក៏អស់លុយរលីងពីខ្លួន ។ ថ្ងៃនោះ ខ្ញុំមិនធ្វើដូចធម្មតាទេ គឺខ្ញុំមិនចូលក្នុងហាងដូចមុនៗឡើយ ផ្ទុយទៅវិញ ខ្ញុំទិញតែនំសាំងវិចមួយ ដែលគេដាក់លក់នៅតាមចិញ្ចើមផ្លូវនៅក្បែរហាងធំមួយឈ្មោះ លូវ្រ (Louvre) ។ ខ្ញុំញញឹមទៅរកអ្នកលក់ នៅពេលខ្ញុំបើកកាបូបប្រាក់ ដកយកកាក់មានតម្លៃ ៥ ហ្វ្រង់ដែលជាកាក់ចុងក្រោយរបស់ខ្ញុំ ។ អ្នកលក់ក៏ញញឹមមកខ្ញុំវិញ ទំនងដូចជាដឹងថា ខ្ញុំមានតែ ៥ ហ្វ្រង់នេះទេ ។ នៅពេលល្ងាចមុននឹងចេញពីធ្វើការ ខ្ញុំដាច់ចិត្តសុំការអនុញ្ញាតពីអ្នកស្រី ដឺបែហ្ស សុំបើកប្រាក់មុនចំនួន ២០០ ហ្វ្រង់ ។ អ្នកស្រីប្រធានហាក់ដូចជាមិនយល់ថា ហេតុអ្វីបានជាខ្ញុំសុំបើកប្រាក់មុនយ៉ាងនេះ បើនៅតែពីរថ្ងៃទៀតតែប៉ុណ្ណោះ យើងនឹងបើកប្រាក់ខែទៅហើយ ។

## បារាំងថាខ្ញុំធ្វើការខុសច្បាប់

ខ្ញុំសប្បាយចិត្តនឹងធ្វើការនៅក្រុមហ៊ុន ហ្វារ៉ូសហ្វ្រង់ (Pharos France) នេះណាស់ ។ ក៏ប៉ុន្តែ ក្តីសប្បាយរបស់ខ្ញុំនោះ មិនបានឋិតថេរយូរវែងឆ្ងាយឡើយ ។ បញ្ហាមិនមែនដោយសារខ្ញុំមានទំនាស់ជាមួយមេកើយរបស់ខ្ញុំ ឬ ជាមួយមិត្តរួមការងារនោះទេ ក៏ប៉ុន្តែបញ្ហាដ៏ធ្ងន់ធ្ងរដែលខ្ញុំត្រូវប្រឈមជាបន្ទាន់នោះគឺ បញ្ហាលក្ខណៈច្បាប់នៃការរស់នៅរបស់ខ្ញុំនៅប្រទេសបារាំង ។ តាមច្បាប់ ខ្ញុំគ្មានសិទ្ធិប្រកបការងារណាមួយនៅក្នុងប្រទេសបារាំងទេ ។ ខ្ញុំមិនមែនជាជនអន្តោប្រវេសន៍ស្របច្បាប់ ។ ខ្ញុំគ្មានប័ណ្ណសន្តិសុខសង្គម និង គ្មានទាំងលិខិតអនុញ្ញាតឲ្យធ្វើការផង ។ ដូច្នេះអ្នកស្រី ដឺបែហ្ស ទើបតែនឹងដឹងថា ខ្ញុំជាអ្នកធ្វើការខុសច្បាប់ ព្រោះគាត់ពុំអាចកសាងសំណុំលិខិតផ្ទាល់ខ្លួនរបស់ខ្ញុំឲ្យបានត្រឹមត្រូវ ។ តាមច្បាប់បារាំង និយោជកដែលរើសយកអ្នកធ្វើការខុសច្បាប់ នឹងត្រូវទទួលទោស ។ ប៉ុន្តែផ្ទុយទៅវិញ និយោជក

របស់ខ្ញុំ សុខចិត្តជួយរកវិធីដោះស្រាយ ដោយរក្សាទុកខ្ញុំឲ្យធ្វើការ និង ដោយលើកទឹកចិត្តឲ្យខ្ញុំខំរកវិធីរត់ការតាមផ្លូវច្បាប់ ដើម្បីឲ្យមានសិទ្ធិធ្វើការពេញទីនៅក្នុងប្រទេសបារាំង ។ ដូច្នេះអ្នកស្រីទទួលឲ្យខ្ញុំធ្វើការដោយលួចលាក់សិន ទម្រាំដល់ពេលដែលខ្ញុំអាចទទួលឯកសារផ្លូវការ និង មានច្បាប់ស្នាក់អាស្រ័យនៅត្រឹមត្រូវឡើងវិញ ។

នៅពេលនោះ ខ្ញុំធ្វើការដោយយកប្រាក់សុទ្ធ និង ដោយគ្មានឈ្មោះក្នុងបញ្ជីបុគ្គលិកស្របច្បាប់របស់ក្រុមហ៊ុនឡើយ ។ មានពេលមួយនោះ អ្នកស្រីឲ្យខ្ញុំចូលទៅលបសម្ងំពួននៅក្នុងផ្ទះបាយ ក្នុងរយៈពេលពេញមួយថ្ងៃ ដើម្បីលាក់ខ្លួនកុំឲ្យមន្ត្រីត្រួតពិនិត្យអធិការកិច្ចការងាររបស់រដ្ឋាភិបាលរកឃើញ នៅពេលមន្ត្រីនោះចុះមកឆែកឆេររកអ្នកធ្វើការខុសច្បាប់ នៅក្នុងក្រុមហ៊ុន ។ មិនតែប៉ុណ្ណោះ ដើម្បីជួយសំរួលការងាររបស់ខ្ញុំ ថៅកែរបស់ខ្ញុំ ជាពិសេសនារីចាស់ៗនៅក្នុងផ្នែកគណនេយ្យទាំងនោះ បានរៀបចំកិច្ចព្រមព្រៀងការងារមួយច្បាប់ ដែលខ្ញុំអាចយកទៅសុំច្បាប់ពីអាជ្ញាធរបារាំង ។ ពួកគាត់ទុកពេលឲ្យខ្ញុំគ្រប់គ្រាន់ ដើម្បីទៅរត់ការ ឬ បំពេញបែបបទនានា ក្នុងន័យកែសំរួលស្ថានភាពរបស់ខ្ញុំឲ្យត្រឹមត្រូវតាមច្បាប់ឡើងវិញ ។

តាមច្បាប់នៃប្រទេសបារាំង ជនបរទេសដែលមានបំណងចូលមកធ្វើការត្រូវមានកិច្ចព្រមព្រៀងការងារ និង ត្រូវសុំទិដ្ឋាការអន្តោប្រវេសន៍ពីស្ថានទូតបារាំងនៅក្នុងប្រទេសរបស់ខ្លួនជាមុនសិន មុននឹងមកជាន់លើទឹកដីបារាំង ។ នៅពេលមកដល់ប្រទេសបារាំង ជនបរទេសនោះ ត្រូវដាក់ពាក្យសុំប័ណ្ណអនុញ្ញាតឲ្យធ្វើការ និង ប័ណ្ណអនុញ្ញាតឲ្យស្នាក់នៅ ដែលចេញដោយមន្ទីរអន្តោប្រវេសន៍ និង ក្រសួងការងារបារាំង ។ ចំពោះករណីរបស់ខ្ញុំ ជាករណីដែលមានលក្ខណៈផ្ទុយស្រឡះពីច្បាប់ទាំងស្រុង ។ ខ្ញុំចូលមកក្នុងទឹកដីបារាំង ដោយគ្មានកិច្ចសន្យាការងារ និង ដោយមានទិដ្ឋាការមិនមែនជាទិដ្ឋាការអន្តោប្រវេសន៍ ។ ម្យ៉ាងទៀត ការងារដែលខ្ញុំកំពុង

ធ្វើនោះ គឺជាការងារមាននៅក្នុងបញ្ជីហាមឃាត់មិនឲ្យជនបរទេសធ្វើ ។ ដូច្នេះ ខ្ញុំមានលទ្ធភាពតិចតួចណាស់ក្នុងការកែប្រែស្ថានភាពរបស់ខ្ញុំពីខុសច្បាប់ឲ្យទៅស្របច្បាប់វិញ ។

នៅពេលនោះទើបខ្ញុំដឹងថា ហេតុអ្វីបានជាជនរួមជាតិខ្ញុំមួយចំនួនត្រូវបង្ខំចិត្តលបលួចធ្វើការជាអ្នកលាងចាននៅក្នុងភោជនីយដ្ឋានចិននានា ។ ដោយសារមានការលំបាកក្នុងការសុំប័ណ្ណការងារនេះហើយ ទើបខ្ញុំឃើញជនជាតិខ្មែរមួយចំនួន ដែលពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សុខចិត្តវិលត្រឡប់ទៅប្រទេសខ្មែរយើងវិញ ជាជាងរស់នៅដោយខុសច្បាប់ ដែលអាចឲ្យប៉ូលីសបារាំងចាប់ដាក់គុក ។ ចំពោះអ្នកទាំងនោះ គេស្ថិតនៅក្នុងរង្វង់និតិក្រមមួយដែលវិលនៅមួយកន្លែង ។ ក្រសួងអន្តោប្រវេសន៍អាចចេញប័ណ្ណស្នាក់នៅឲ្យខ្ញុំ ប្រសិនបើខ្ញុំអាចបង្ហាញពីធនធានរបស់ខ្ញុំក្នុងការស្នាក់អាស្រ័យនៅប្រទេសបារាំងនេះ ។ ខ្ញុំអាចបង្ហាញពីធនធានរបស់ខ្ញុំបាន ប្រសិនបើខ្ញុំអាចធ្វើការ ក្នុងករណីខ្ញុំអត់អាហារូបករណ៍ ។ បើខ្ញុំមិនអាចធ្វើការ ខ្ញុំក៏មិនអាចបង្ហាញពីធនធានរបស់ខ្ញុំបានដែរ ហើយខ្ញុំក៏មិនអាចធ្វើការបាន ប្រសិនបើគ្មានប័ណ្ណស្នាក់អាស្រ័យនៅ ។ ក៏ប៉ុន្តែចំពោះខ្ញុំៗបានសំរេចចិត្តថា ទោះបីជាមានហេតុការណ៍អ្វីកើតឡើងយ៉ាងណាក៏ដោយ ខ្ញុំមិនវិលត្រឡប់ទៅប្រទេសកម្ពុជាវិញទេ នៅពេលដែលសង្គ្រាមកំពុងតែឆេះសន្ធោសន្ធៅនៅឡើយនោះ ។ ប័ណ្ណការងារជាបញ្ហាស្លាប់រស់របស់ខ្ញុំ ។ ខ្ញុំប្តេជ្ញារកឲ្យបាននូវប័ណ្ណការងារនោះ ។

# សុំសិទ្ធិជ្រកកោននយោបាយ

ការិយាល័យប៉ូលីសអន្តោប្រវេសន៍របស់បារាំងបានត្រួតពិនិត្យករណីរបស់ខ្ញុំយ៉ាងហ្មត់ចត់ណាស់ តាំងពីពេលដែលខ្ញុំបានដាក់ពាក្យស្នើសុំការស្នាក់អាស្រ័យជាអចិន្ត្រៃយ៍នៅប្រទេសបារាំង ។ នៅពេលកន្លងមក ខ្ញុំបានទទួលការអនុញ្ញាតបណ្តោះអាសន្នឲ្យស្នាក់អាស្រ័យនៅតែមួយរយៈ មិនលើសពីប្រាំមួយខែឡើយ ទម្រាំមានសេចក្តីសំរេចជាចុងក្រោយរបស់អាជ្ញាធរបារាំង ។ បើគ្មានប័ណ្ណស្នាក់អាស្រ័យនៅជាអចិន្ត្រៃយ៍ទេ ខ្ញុំក៏ពុំមានសិទ្ធិធ្វើការ បានន័យថា ខ្ញុំក៏ពុំមានប្រភពធនធាន ឬ បានន័យថា ខ្ញុំនឹងត្រូវចាប់បញ្ជូនត្រឡប់ទៅប្រទេសខ្មែរវិញ ។ ជាច្រើនលើកច្រើនគ្រា ខ្ញុំមិនបានទទួលការសំរេចណាមួយពីអាជ្ញាធរបារាំងនៅឡើយទេ ។ លើកនេះ ខ្ញុំសំរេចធ្វើដំណើរទៅកាន់ការិយាល័យអន្តោប្រវេសន៍ជាថ្មីម្តងទៀត ដោយមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ជាទីបំផុត ។ នៅពេលខ្ញុំទៅដល់ការិយាល័យអន្តោប្រវេសន៍នោះ ខ្ញុំត្រូវបានទទួលលេខរៀងឲ្យរង់ចាំ ដែលគេនឹងប្រើដើម្បីហៅឈ្មោះខ្ញុំ តាមលំដាប់លេខជាបន្តបន្ទាប់ ។ ផ្ទុយពីអ្នកឯទៀត ដែលកំពុងអង្គុយរង់ចាំដោយស្ងៀមស្ងាត់ ខ្ញុំមានអារម្មណ៍ជ្រួលច្របល់ប្លែកពីសព្វៗដង ។ នៅទីបំផុតលើកនេះក៏ដូចជាលើកមុនដែរ នារីបារាំងមួយរូប ដែលជាមន្ត្រីទទួលពិនិត្យករណីរបស់ខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំគ្មានសិទ្ធិធ្វើការ និង គ្មានសិទ្ធិស្នាក់នៅក្នុងប្រទេសបារាំងនោះទេ ។ ក៏ប៉ុន្តែ ភ្លាមៗនោះ ខ្ញុំក៏ដាក់ជូននារីនោះ នូវលិខិតសរសេរដោយដៃដែលខ្ញុំសរសេរភ្លាមៗ នៅពេលរង់ចាំនោះគឺ ជាលិខិតស្នើសុំសិទ្ធិជ្រកកោនផ្នែកនយោបាយនៅប្រទេសបារាំង ។ ខ្ញុំជឿជាក់យ៉ាងច្បាស់ថា មានតែក្នុងឋានៈជាជនភៀសខ្លួនទេ ទើបខ្ញុំអាចមានសិទ្ធិធ្វើការផង និង ស្នាក់នៅផង ។ ខ្ញុំបានលើកឡើងនូវហេតុផលមួយចំនួនតូច ដើម្បីជាមូលដ្ឋាននៃពាក្យសុំសិទ្ធិជ្រកកោននោះ ។ ខ្ញុំ

សំអាងហេតុផលថា ខ្ញុំស្ថិតនៅក្នុងគណបក្សនយោបាយ ដែលប្រឆាំងនឹងរដ្ឋាភិបាល ។ ខ្ញុំប្រឆាំងរដ្ឋាភិបាល លន់ នល់ ដែលខ្ញុំមិនអាចទទួលបានថាជារដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់របស់ខ្ញុំឡើយ ហើយខ្ញុំក៏មិនព្រមចូលរួមជាមួយរដ្ឋាភិបាលក្រៅស្រុករបស់សម្តេច សីហនុ ដែលមានពួកខ្មែរក្រហមជាកំលាំងនោះឡើយ ។ នារីបារាំងដែលទទួលករណីរបស់ខ្ញុំនោះ បានប្រាប់ឲ្យខ្ញុំនៅចាំទៀត ដើម្បីគាត់មានឱកាសទៅស្នើសេចក្តីសំរេចពីថៅហ្វាយនាយរបស់គាត់ ។ មួយរយៈក្រោយមក គាត់ក៏ចេញសេចក្តីអនុញ្ញាតបណ្តោះអាសន្នឲ្យខ្ញុំស្នាក់នៅ ទម្រាំមានសេចក្តីសំរេចអំពីពាក្យសុំសិទ្ធិជ្រកកោនខាងផ្នែកនយោបាយរបស់ខ្ញុំនោះ ។

ខ្ញុំទទួលបៀមទុក្ខសោករបស់ខ្ញុំតែម្នាក់ឯង ។ ខ្ញុំមិនបានប្រាប់នរណាម្នាក់ឲ្យដឹងពីកង្វល់របស់ខ្ញុំនេះទេ ហើយខ្ញុំក៏មិនប្រាប់នរណាឲ្យដឹងអំពីការសុំសិទ្ធិជ្រកកោននយោបាយរបស់ខ្ញុំនេះដែរ ។ អ្នកដែលនៅជាមួយទាំងប៉ុន្មាន រាប់ទាំងលោកវេជ្ជបណ្ឌិត ស៊ូ ណែម និង ភរិយាគាត់ផង ក៏ពុំបានដឹងពីរឿងរ៉ាវរបស់ខ្ញុំដែរទេ ។ ពួកគេនៅតែបន្តយល់ឃើញថា ខ្ញុំជាយុវជនខ្មែរដ៏កម្រម្នាក់ដែលមានភ័ព្វសំណាងបានធ្វើការក្នុងការិយាល័យនៅក្នុងប្រទេសបារាំង ។ ខ្ញុំធ្លាប់បានសរសេរសំបុត្រទៅឪពុកម្តាយ បងប្អូនខ្ញុំនៅប្រទេសខ្មែរ និង ជាពិសេស ទៅបងប្រុសខ្ញុំទាំងពីរនាក់ ។ នៅក្នុងសំបុត្រទីមួយ បន្ទាប់ពីខ្ញុំមកដល់ប្រទេសបារាំង ខ្ញុំបានសរសេរសំបុត្ររៀបរាប់អំពីការធ្វើដំណើរតាមយន្តហោះរបស់ខ្ញុំ និង កិច្ចស្វាគមន៍ដ៏រាក់ទាក់ដែលគ្រួសារលោកវេជ្ជបណ្ឌិត ស៊ូ ណែម បានធ្វើចំពោះខ្ញុំ ។ តាមធម្មតា គេត្រូវចំណាយពេល ៥ ថ្ងៃ ដើម្បីផ្ញើសំបុត្រពីប្រទេសបារាំងទៅប្រទេសខ្មែរ និង ត្រូវចំណាយពេលមួយអាទិត្យដើម្បីផ្ញើសំបុត្រពីប្រទេសខ្មែរ ទៅប្រទេសបារាំងវិញ ។ ដូច្នេះ យើងប្តូរលិខិតឆ្លងឆ្លើយគ្នាមួយដងក្នុងពីរសប្តាហ៍ ដើម្បីរៀបរាប់ទៅវិញទៅមកនូវហេតុការណ៍រៀងៗខ្លួន ។ តាមរយៈការផ្លាស់ប្តូរលិខិតឆ្លងឆ្លើយនេះ ទោះជាខ្ញុំផ្ញើទៅបង

ប្រុសខ្ញុំក៏ដោយ ក៏នៅទីបញ្ចប់សំបុត្ររបស់ខ្ញុំនោះ នឹងត្រូវបញ្ជូនទៅដល់ផ្សារដើមគដែលនៅពេលនោះ ពួកគេអង្គុយជុំកង់ជុំវិញអ្នកអានសំបុត្រ ដែលគេជ្រើសរើសក្នុងចំណោមក្មេងៗដែលជាប្អូនៗរបស់ខ្ញុំនោះ ។ ពួកគេតែងហ៊ោរសប្បាយនៅពេលដែលពួកគេដឹងថា ខ្ញុំបានជួបនឹងជ័យជំនះអ្វីមួយ ដូចជានៅពេលដែលខ្ញុំសរសេរប្រាប់ពួកគេថាខ្ញុំរកការបានធ្វើនៅប្រទេសបារាំង ។ ពួកគេចាត់ទុករូបខ្ញុំជាក្តីសង្ឃឹមរបស់ពួកគេម្នាក់ៗ ។ សូមបញ្ជាក់ថា បន្ទាប់ពីខ្ញុំរកការបានធ្វើនោះមកខ្ញុំក៏ចាប់ផ្តើមផ្ញើប្រាក់កាសខ្លះទៅដល់ពួកគេ ។ នៅពេលដែលខ្ញុំនិយាយអំពីទុក្ខលំបាករបស់ខ្ញុំ ពួកគេក៏កើតទុក្ខគ្រប់គ្នាៗដែរ ។ ខ្ញុំដឹងថា ឪពុកម្តាយ បងប្អូនខ្ញុំទាំងអស់នោះ រស់នៅក្នុងលក្ខណៈលំបាកលំបិនជាងខ្ញុំទៅទៀត ព្រោះពួកគេរស់នៅក្នុងប្រទេសដែលកើតសង្គ្រាមប្រឈមមុខមហន្តរាយស្លាប់រស់ជារៀងរាល់ថ្ងៃ ។ ដូច្នេះ ខ្ញុំគិតថាខ្ញុំមិនគួរនាំព័ត៌មានដ៏អាក្រក់ណាមួយដល់ពួកគេឡើយ ។

ខ្ញុំបានប្រឹងប្រែងជាអតិបរមា ដើម្បីទាមទារលក្ខន្តិកៈជាជនភៀសខ្លួន ។ ខ្ញុំខិតខំទាក់ទងជាច្រើនដងជាមួយនឹងក្រសួងការបរទេសបារាំង ជាពិសេស ជាមួយនឹងការិយាល័យជនភៀសខ្លួន ដែលខ្ញុំបានដាក់ពាក្យជាផ្លូវការ ។ ខ្ញុំបានធ្វើសេចក្តីរាយការណ៍យ៉ាងលំអិតអំពីហេតុផលខាងនយោបាយ ដែលតម្រូវឲ្យខ្ញុំសុំសិទ្ធិជ្រកកោននយោបាយនេះ ។ ខ្ញុំប្រកាន់គោលជំហរថា ខ្ញុំជាបក្សពួកខាងលោក ថៅ សៅ ដែលបានបណ្តេញលោក អ៊ិន តាំ ពីគណបក្សប្រជាធិបតេយ្យ ឥឡូវលោក អ៊ិន តាំ បានក្លាយជានាយករដ្ឋមន្ត្រីនៃរបប លន់ នល់ ។ ដូច្នេះ ខ្ញុំបារម្ភខ្លាចលោក អ៊ិន តាំ ប្រើអំណាចគំរាមកំហែងដល់អាយុជីវិតរបស់ខ្ញុំ ។ ខ្ញុំស្រាវជ្រាវសុំឲ្យអ្នកតំណាងរាស្ត្របារាំងជួយគាំទ្រពាក្យសុំជាជនភៀសខ្លួនរបស់ខ្ញុំ ។ ខ្ញុំសរសេរសំបុត្រទៅលោកស្រី នីកូល ដឺ អូតក្លុក (Nicole de Hauteclocque) ដែលមានស្វាមីឈ្មោះលោកសេនាប្រមុខ ឡឺក្លែរ (Leclerc) ។ នៅពេលនោះ លោកស្រីជាស្ត្រីមេម៉ាយ

ដោយសារលោកសេនាប្រមុខ ឡឺក្លែរ បានទទួលមរណភាពទៅហើយ ។ លោកស្រីនីកូល ដឺ អូតក្លុក ជាអ្នកតំណាងរាស្ត្រសង្កាត់លេខ ១៤ ទីក្រុងប៉ារីស ។ លោកស្រីធ្លាប់បានសរសេរសំបុត្រលើកទឹកចិត្តមកខ្ញុំដែរ ។ នៅក្នុងរយៈពេលនោះ ខ្ញុំមិនសូវបានធ្វើការជាប់លាប់ទេ គឺអវត្តមានជាញឹកញាប់ ក៏ប៉ុន្តែចៅហ្វាយនាយរបស់ខ្ញុំ ជាពិសេស អ្នកស្រី ជឺបែហ្ស មានចិត្តសន្តោសយោគយល់ដល់ខ្ញុំជាខ្លាំង ។ ពួកគាត់តែងគាំទ្រពល់ការខំប្រឹងប្រែងរបស់ខ្ញុំ និង ជួយលើកទឹកចិត្តខ្ញុំជានិច្ច ។

## ជីវិតថ្មីជាអ្នកទីក្រុងប៉ារីស

ដោយសារការខំប្រឹងប្រែងឥតមានខ្លាចនឿយហត់ និង ដោយសារមានការគាំទ្រយ៉ាងខ្លាំងក្លាយ៉ាងនេះហើយ ទើបខ្ញុំចេះតែរុករុលទៅមុខបាន ។ នៅទីបញ្ចប់ខ្ញុំក៏ត្រូវបានក្រុមប៉ូលីសអន្តោប្រវេសន៍កោះហៅជាថ្មីម្តងទៀត ។ ម្តងនេះ មន្ត្រីដែលទទួលជួបខ្ញុំគឺ ជានាយប៉ូលីសភេទប្រុស ។ នៅពេលជួបភ្លាម លោកមេប៉ូលីសទារយកសំបុត្រឆ្លងដែនរបស់ខ្ញុំទៅទុកនៅក្នុងថតតុរបស់គាត់ ដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ នៅពេលនោះខ្ញុំក៏ដាក់ជូនគាត់នូវពាក្យសុំប័ណ្ណអនុញ្ញាតស្នាក់អាស្រ័យម្តងទៀត ។ លោកនាយអានយ៉ាងយកចិត្តទុកដាក់នូវពាក្យសុំរបស់ខ្ញុំនោះ ហើយមួយរំពេចនោះ គាត់យកប៊ិចឆូតលុបពាក្យថា "សញ្ជាតិខ្មែរ" ដោយគាត់សរសេរជំនួសវិញថា "ជនភៀសខ្លួនខ្មែរ" ។ ការលុបពាក្យសញ្ជាតិខ្មែរនេះ ធ្វើឲ្យខ្ញុំមានក្តីរន្ធត់ស្ទើរគាំងបេះដូង ព្រោះគ្រាន់តែមួយប៉ប្រិចភ្នែកប៉ុណ្ណោះខ្ញុំក៏បាត់បង់នូវសញ្ជាតិខ្មែរដ៏ជាទីស្នេហារបស់ខ្ញុំ ។ តាមពិត អាជ្ញាធរបារាំងបានសំរេចផ្តល់សិទ្ធិជ្រកកោនឲ្យខ្ញុំរួចទៅហើយ គ្រាន់តែខ្ញុំពុំទាន់ដឹង នៅពេលទៅសុំប័ណ្ណអនុញ្ញាតស្នាក់អាស្រ័យនោះ ។ ដូច្នេះនៅឆ្នាំ ១៩៧៤ នៅពេលដែលសង្គ្រាមកំពុងតែឆាបឆេះប្រទេស

ខ្មែរនៅឡើយ ខ្ញុំប្រហែលក្លាយខ្លួនជាជនភៀសខ្លួនមួយមុនគេនៅក្នុងប្រទេសបារាំង ។ អស់រយៈពេលមិនដល់មួយឆ្នាំផង ខ្ញុំក៏បានទទួលនូវអ្វីៗដែលខ្ញុំចាំបាច់ត្រូវមានគឺ លក្ខន្តិកៈជាជនភៀសខ្លួន លិខិតអនុញ្ញាតឲ្យធ្វើការ និង លិខិតអនុញ្ញាតឲ្យស្នាក់នៅជាអចិន្ត្រៃយ៍ ។

នៅខែ ឧសភា ១៩៧៤ ខ្ញុំក៏បានសំរេចចេញពីផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម មកជួលបន្ទប់មួយនៅក្នុងសង្កាត់លេខ ១៤ នៃទីក្រុងប៉ារីស ។ បន្ទប់នោះស្ថិតនៅក្នុងអាគារនៃតំបន់មួយឈ្មោះថា អាឡេស្យា (Alésia) ដែលមានអាសយដ្ឋានលេខ ២០ ផ្លូវមូឡាំងវែរ (Moulin Vert) ។ អាគារដែលខ្ញុំស្នាក់នៅនោះស្ថិតនៅក្នុងតំបន់ស្ងាត់ល្អ និង ស្អាតបាត ។ អាគារនេះ ប្រកបដោយផ្ទះល្វែងជាច្រើន ក៏ប៉ុន្តែនៅជាន់ខាងក្រោមពុំមានផ្ទះល្វែងទេមានតែបន្ទប់ជួលសំរាប់និស្សិត ។ ពេលចូលទៅក្នុងអាគារ គេមើលពុំឃើញបន្ទប់និស្សិតទាំងនោះទេ ព្រោះបាំងជញ្ជាំងនៃច្រកចូលទៅល្វែងខាងក្នុងបន្ទប់របស់ខ្ញុំ ដែលស្ថិតនៅខាងក្រោយគេបង្អស់គឺ ជាបន្ទប់ដែលមានគ្រែមួយ ទូរទឹកកកតូចមួយ ។ បន្ទប់ទឹក និង បង្គន់ស្ថិតនៅខាងក្រៅដែលអាចប្រើប្រាស់រួមជាមួយអ្នកឯទៀត ។ ជាមួយនឹងការរស់នៅដោយខ្លួនឯង ខ្ញុំសប្បាយចិត្តនឹងសេរីភាពនេះណាស់ ជាពិសេសខ្ញុំនឹកថាខ្ញុំនឹងមានលទ្ធភាពបន្តការសិក្សាតទៅទៀត ។ ខ្ញុំចំណាយប្រាក់មួយខែ ៣៩៩ ហ្វ្រង់ សំរាប់ថ្លៃឈ្នួលផ្ទះ ដែលមានតម្លៃជិតពីរដងនៃថ្លៃឈ្នួលផ្ទះ កាលខ្ញុំស្នាក់នៅជាមួយលោក ស៊ូ ណែម ។ ក៏ប៉ុន្តែ ផ្ទះថ្មីរបស់ខ្ញុំនោះ ក៏មានបញ្ហាដែរ ព្រោះគ្មានផ្ទះបាយ ។ ដូច្នេះខ្ញុំត្រូវទិញចង្ក្រានអគ្គិសនីដ៏តូចមួយ ដើម្បីដាំទឹក ឬ កំដៅទឹកដោះគោសំរាប់ការស្រស់ស្រូបអាហារពេលព្រឹក ។ តាមធម្មតា ខ្ញុំគ្មានសិទ្ធិដាំស្ល ឬ ធ្វើម្ហូបអាហារនៅក្នុងបន្ទប់នេះទេ ។

អាឡេស្យា ជាតំបន់មួយដែលមានសកម្មភាពដ៏រស់រវើក ។ ខ្ញុំ ប្រទះឃើញនូវអ្វីៗ ដែលខ្ញុំត្រូវការគឺ ខ្ញុំអាចទៅលេងសួនច្បារក៏បាន ទៅផ្សារមេឃក៏បាន ទៅទិញអីវ៉ាន់នៅតាមហាងក៏បាន ចូលមើលភាពយន្តក៏បាន ឬ ចូលតាមភៀមកាហ្វេ ភោជនីយដ្ឋាន ឱសថដ្ឋាន ធនាគារ បណ្ណាគារ ជាងកាត់សក់ជាដើម ។ល។ គេអាចដើរពី អាឡេស្យា ទៅ ប៉កដកឡេអង់ (Porte d'Orléans) ក៏បាន ឬក៏ដើរទៅ ម៉ុងប៉ាណាស់ (Montparnasse) ក៏បាន ។ បើនិយាយឲ្យខ្លី តំបន់នោះគឺ ជាតំបន់ស្រួលចាយលុយ ឬ ចាយលុយឆាប់អស់ ។ ខ្ញុំចូលចិត្តរស់នៅក្នុងតំបន់នោះណាស់ តែខ្ញុំក៏មិនដែលភ្លេចទៅលេងផ្ទះលោកវេជ្ជបណ្ឌិត ស៊ូ ណែម ដែរ ។ រស់នៅម្នាក់ឯងយ៉ាងនេះយូរៗទៅ ខ្ញុំក៏នឹកទៅដល់ម្ហូបខ្មែរ ដែលអ្នកស្រី ស៊ូ ណែម ធ្លាប់ធ្វើឲ្យខ្ញុំទទួលទាន ។ ចាប់តាំងពីខ្ញុំមកនៅ អាឡេស្យា ខ្ញុំទទួលទានម្ហូបបារាំងនៅពេលថ្ងៃត្រង់ ហើយនៅពេលល្ងាចខ្ញុំទទួលទានម្ហូបអាហារចំអិនរួចស្រេច ដែលមានដាក់លក់នៅតាមហាងនានា ។ នៅពេលដំបូង ខ្ញុំមិនសូវស្គាល់ម្ហូប និងភេសជ្ជៈបារាំងប៉ុន្មានឡើយ ។ ចាប់តាំងពីពេលដែលខ្ញុំមានឋានៈជាអ្នកធ្វើការពេញសិទ្ធិ និង ជាអ្នកទីក្រុងប៉ារីសម្នាក់មក ខ្ញុំមិនទទួលទានសាំងវិចដូចពីមុនទៀតទេ ។ ឥឡូវអស់រយៈពេលមួយឆ្នាំមកហើយ ខ្ញុំទទួលទានតែសាច់គោ និង ដំឡូងចៀនស្តេកហ្វ្រីត (Steak Frite) នៅក្នុងភោជនីយដ្ឋានមួយនៅទល់មុខកន្លែងខ្ញុំធ្វើការ ។ នៅក្នុងភោជនីយដ្ឋាននេះ យើងដើរទៅជ្រើសរើសម្ហូបដោយខ្លួនយើង គ្មានអ្នកបំរើទេ ។ រាល់ៗដង ខ្ញុំមិនផ្លាស់ប្តូរមុខម្ហូបរបស់ខ្ញុំឡើយគឺ ស្តេកហ្វ្រីត ជាប់ជានិច្ចរហូតដល់ស្ត្រីអ្នកធ្វើម្ហូប លើកស្តេកហ្វ្រីត ហុចមកឲ្យខ្ញុំ ដោយមិនចាំបាច់សួរនាំដូចអ្នកឯទៀតនោះឡើយ ។ ចំពោះភេសជ្ជៈវិញ ខ្ញុំចាប់ផ្តើមទទួលទានទឹកដោះគោជំនួសទឹកសុទ្ធ ព្រោះខ្ញុំកម្រមានឱកាសទទួលទានទឹកដោះគោនៅប្រទេសខ្មែរណាស់ ។ មួយឆ្នាំក្រោយមក ខ្ញុំទទួលទានស្រាបៀរជំនួសទឹកដោះគោ ហើយ

បន្ទាប់មកទៀត ស្រាសទំពាំងបាយជូ ដែលមានពពុះជំនួសស្រាបៀរ ហើយនៅចុងបញ្ចប់ ខ្ញុំច្រើនទទួលទានស្រាក្រហមទំពាំងបាយជូរហូតរៀងមក ។

នៅឆ្នាំទីមួយនៃជីវិតជាអ្នកទីក្រុងប៉ារីសរបស់ខ្ញុំៗប្រើពេលជាច្រើន ដើម្បីស្វែងរកសិទ្ធិរស់នៅតាមច្បាប់ ឬ ស្របច្បាស់នៅប្រទេសបារាំង និង ដើម្បីខឹតខំធ្វើសមាហរណកម្មជីវភាពថ្មីរបស់ខ្ញុំក្នុងសង្គមបារាំង ។ តែឆ្នាំទីមួយនោះ ក៏ជាឆ្នាំដែលខ្ញុំនឹកស្រុកយ៉ាងខ្លាំងណាស់ដែរ ។ ខ្ញុំសរសេរសំបុត្រទៅឪពុកម្ដាយខ្ញុំថា ខ្ញុំរង់ចាំសំបុត្រពីស្រុកខ្មែរ ដូចក្មេងដែលរង់ចាំម្ដាយមកពីផ្សារយ៉ាងនោះដែរ ។ ខ្ញុំសរសេរយ៉ាងនេះ ដោយនឹកដល់ការរស់នៅឯស្រុកខ្មែរ ដែលស្ត្រីជាម្ដាយទាំងឡាយតែងទៅផ្សាររាល់ព្រឹក នៅពេលដែលក្មេងៗជាកូនតែងទន្ទឹងរង់ចាំងផ្ទះមើលផ្លូវម្ដាយត្រឡប់មកវិញ ក្រែងនឹងបាននំចំណីដ៏ផ្អែមពិសា ឬ ឈុយឆ្ងាញ់ ។ ចំពោះខ្ញុំ នៅពេលបានទទួលសំបុត្រពីស្រុកខ្មែរម្ដងៗ ខ្ញុំក៏មានភាពរីករាយក្នុងចិត្តដូចក្មេងៗទាំងនោះដែរ ។ ក៏ប៉ុន្តែ ជាបន្តបន្ទាប់ ដំណឹងដែលមកពីប្រទេសខ្មែរទាំងប៉ុន្មាន សុទ្ធតែជាដំណឹងមិនល្អទាំងអស់ ព្រោះសភាពការណ៍នៃសង្គ្រាមនៅកម្ពុជាកាន់តែធ្ងន់ធ្ងរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំក៏នៅតែមានការរីករាយនឹងទទួលដំណឹងពីឪពុកម្ដាយ បងប្អូនរបស់ខ្ញុំជានិច្ច ។

ចំពោះការងាររបស់ខ្ញុំវិញ ថៅកែ និង ចៅហ្វាយនាយរបស់ខ្ញុំ ពេញចិត្តការងារខ្ញុំណាស់ ចំណែកប្រាក់ខែរបស់ខ្ញុំ ក៏ចេះតែឡើងជាលំដាប់គឺពី ១៤០០ ហ្វ្រង់ ទៅ ១៦០០ ហ្វ្រង់ រហូតដល់ ២០០០ ហ្វ្រង់ នៅដើមឆ្នាំ ១៩៧៥ ។ ឯមុខងាររបស់ខ្ញុំក៏ឡើងឋានៈដែរ ។ នៅដើមឆ្នាំ ១៩៧៥ នោះខ្ញុំក៏ឡើងឋានៈជាគណនេយ្យករពេញសិទ្ធិ ។ ខ្ញុំមានទំនាក់ទំនងល្អជាមួយអ្នកស្រី ដឺបែហ្ស ដែលធ្វើឲ្យមិត្តភាពរវាងយើងទាំងពីរកាន់តែរឹងមាំឡើង ។ ខ្ញុំអាចហៅឈ្មោះផ្ទាល់របស់គាត់គឺ គ្រីស្យាន (Christiane) បាន ។ គ្រីស្យាន ជាមិត្តដ៏កម្រ ដែលខ្ញុំស្រឡាញ់រាប់អានរហូតមក

ដល់សព្វថ្ងៃនេះ អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ។ ទោះជាប់បំពេញការងារក៏ដោយ ក៏ខ្ញុំខិតខំឆ្លៀតរកសាលារៀនបន្ថែមទៀតដែរ ជាពិសេសនៅវិទ្យាស្ថានជាតិបច្ចេកទេសសេដ្ឋកិច្ច និង គណនេយ្យ ។ យើងសិក្សារៀងៗខ្លួន តែក្នុងមួយអាទិត្យម្តង យើងជួបជុំគ្នាជាក្រុម ជាមួយសាស្ត្រាចារ្យជំនាញរបស់យើង ។ គឺតាមរយៈការសិក្សាជាក្រុមនេះហើយ ទើបខ្ញុំមានមិត្តម្នាក់ទៀតឈ្មោះ គ្រីស្យង់ ឡឺដេ (Christian Leday) ។ គ្រីស្យង់ ឡឺដេ ជាគណនេយ្យករមួយរូបធ្វើការនៅក្នុងរោងចក្រមួយនៅតំបន់ ន័រម៉ង់ឌី (Normandie) ។ គ្រីស្យង់ និង ភរិយាមានកូនពីរនាក់ ។ ខ្ញុំឧស្សាហ៍ទៅលេងស្រុករបស់គ្រីស្យង់នោះណាស់ ។ ស្រុកនោះនៅក្បែរទីក្រុងមួយឈ្មោះ ឡែគ្ល (L'aigle) ។ ពួកយើងឧស្សាហ៍ប្តូរវត្ថុអនុស្សាវរីយ៍គ្នាទៅវិញទៅមក នៅពេលបុណ្យណូអែល ឬ ចូលឆ្នាំថ្មី ។ មានពេលខ្លះគ្រីស្យង់ និង ភរិយា បបួលខ្ញុំទៅសំរាកដើរលេងកំសាន្ត ឬ បោះតង់ នៅតំបន់ប្រឺតាញ (Bretagne) គ្រីស្យង់ តែងនិយាយចំអន់លេងឲ្យខ្ញុំថា "មូលីឯងសមជារដ្ឋមន្ត្រីក្រសួងការបរទេសដ៏ល្អម្នាក់ នៅពេលណាមួយមិនខាន" ។

ដោយសារខ្ញុំមានការងារច្រើន និង ដោយសារខ្ញុំចេះតែខ្វល់ខ្វាយចំពោះសុខទុក្ខរបស់បងប្អូន ឪពុកម្តាយខ្ញុំឯស្រុកខ្មែរ ខ្ញុំក៏រៀនមិនបានខ្ជាប់ខ្ជួនឡើយ ។ នៅចុងឆ្នាំ ១៩៧៤ ខ្ញុំប្រឡងប្រចាំឆ្នាំធ្លាក់ ។ ក្នុងពេលជាមួយគ្នានោះដែរ និស្សិតខ្មែរមួយចំនួន ត្រូវបង្ខំចិត្តវិលត្រឡប់ទៅប្រទេសខ្មែរវិញ ដោយសារអ្នកខ្លះបានបញ្ចប់ការសិក្សា ឬ ត្រូវអស់អាហាររូបករណ៍ ឬ គ្មានលទ្ធភាពបន្តការសិក្សា ដោយគ្មានសិទ្ធិធ្វើការយកប្រាក់ចិញ្ចឹមជីវិត ។ និស្សិតដែលត្រូវត្រឡប់មកស្រុកខ្មែរវិញនោះ ត្រូវបាត់បង់ជីវិតស្ទើរតែទាំងអស់នៅក្នុងរបបខ្មែរក្រហម ។ ផ្ទុយពីនេះទៅវិញ មានបងប្អូនជនជាតិខ្មែរមួយចំនួនបានគេចចេញពីស្រុកខ្មែរ ហើយបានមកដល់ប្រទេសបារាំង តែប៉ុន្មានខែប៉ុណ្ណោះមុនរបបសាធារណរដ្ឋខ្មែរដួលរលំ ។ ក្នុង

ចំណោមនោះ មានសហសេវិករបស់ខ្ញុំម្នាក់នៅកូមិន្ទខ្មែរឈ្មោះ ផាន់ សូរិយាសុី ផងដែរ ។ សូរិយាសុី បាននាំប្រពន្ធ និង កូនចំនួនពីរនាក់មកជាមួយ ។ ក្រោយមក សូរិយាសុី បានបញ្ជូនកូនទាំងពីរនាក់នោះត្រឡប់ទៅស្រុកខ្មែរវិញជាមួយជីតារបស់គេ ដែលមានលទ្ធភាពមកប្រទេសបារាំងក្នុងរយៈពេលដ៏ខ្លី តែប៉ុន្មានថ្ងៃមុនខ្មែរក្រហម ចូលភ្នំពេញតែប៉ុណ្ណោះ ។ សូរិយាសុី បានក្លាយទៅជាមិត្តជិតស្និទ្ធរបស់ខ្ញុំ ហើយរាល់ពេលឈប់សំរាក យើងតែងចំណាយពេលវេលាជាមួយគ្នាមិនដែលដាច់ ។

## សប្បាយលាយទឹកភ្នែក នៅថ្ងៃ ១៧ មេសា ១៩៧៥

នៅដើមឆ្នាំ ១៩៧៥ នោះ លោក ស៊ូ ណែម ទាំងប្រពន្ធទាំងកូនបានត្រឡប់មកប្រទេសកម្ពុជាវិញ ។ ខ្ញុំពុំបានជូនដំណើរពួកគាត់ទៅព្រលានយន្តហោះទេ ។ ក៏ប៉ុន្តែ ប៉ុន្មានថ្ងៃមុនពេលគាត់ចេញដំណើរ ខ្ញុំបានជួបលោកស្រី ស៊ូ ណែម ដែរ ហើយខ្ញុំបានផ្ញើសំបុត្រ និង ប្រាក់កាសខ្លះទៅឪពុកម្តាយខ្ញុំនៅភ្នំពេញទៀតផង ។ តាំងពីពេលនោះមក ខ្ញុំពុំដែលបានជួបគាត់ទៀតឡើយ ។ ដោយសារលោក ស៊ូ ណែម ជាមនុស្សសំខាន់ម្នាក់នៃរបបសាធារណរដ្ឋ គាត់ប្រហែលជាត្រូវខ្មែរក្រហមសម្លាប់បាត់ទៅហើយ ។

នៅថ្ងៃទី ១៧ មេសា ១៩៧៥ ក៏ដូចជាថ្ងៃឯទៀតដែរ នៅពេលឈប់សំរាកទទួលទានអាហារថ្ងៃត្រង់ ខ្ញុំតែងធ្វើដំណើរទៅធនាគារនៅក្បែរសាលមហោស្រពអូប៉េរ៉ា (Opera) ដូចធម្មតា ដើម្បីយកមូលប្បទានប័ត្រនានារបស់ក្រុមហ៊ុនទៅបញ្ចូលក្នុងគណនី ។ បន្ទាប់ពីធ្វើការនេះនៅឯធនាគាររួចហើយ ខ្ញុំតែងតែត្រឡប់មកតាមវិថី ដឺ ឡេស្សែល (de l'Echelle) ដើម្បីទទួលទានអាហារថ្ងៃត្រង់នៅក្នុង

ភោជនីយដ្ឋានគ្មានអ្នកបំរើ (Self Service Restaurant) ដែលស្ថិតនៅចំពីមុខកន្លែងធ្វើការរបស់ខ្ញុំ ។ នៅថ្ងៃទី ១៧ ខែ មេសានោះ ខ្ញុំដើរតាមវិថីនានា ដើម្បីទៅទទួលទានអាហារថ្ងៃត្រង់ ក៏ប៉ុន្តែ ផ្ទុយពីសព្វៗដង ខ្ញុំមិនប្រញាប់ត្រឡប់ទៅធ្វើការវិញទេ ខ្ញុំដើរតាមវិថី ដេ ពៀរ៉ាមីដ (Des Pyramides) រហូតទៅដល់វុក្ខវិថី ដឺឡូប៉េរ៉ា (De l'Opera) ។ នៅត្រង់កាច់ជ្រុងនោះ នៅត្រង់ច្រកចូលស្ថានីយម៉េត្រូ ដេ ពៀរ៉ាមីដ មានតូបលក់កាសែតមួយ ដែលនៅទីនោះ ខ្ញុំក៏ទិញកាសែត ឡឺម៉ុង (Le Monde) មួយច្បាប់ ។ នៅទំព័រទីមួយ ខ្ញុំឃើញគេសរសេរអក្សរធំៗថា ទីក្រុងភ្នំពេញ បានត្រូវធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហមទៅហើយ ។ តាមពិតដំណឹងស្តីពីការដួលរលំនៃរបប លន់ នល់ មិនធ្វើឲ្យខ្ញុំមានការសង្ស័យអ្វីប៉ុន្មានទេ ព្រោះខ្ញុំមានជំនឿថារបបនេះ រង់ចាំតែថ្ងៃខែនៃសេចក្តីស្លាប់តែប៉ុណ្ណោះ ។ ប្រតិកម្មរបស់ខ្ញុំភ្លាមៗ ក្នុងពេលនោះគឺ បង្ហូរទឹកភ្នែកមកដោយឯកឯង ទាំងមិនដឹងខ្លួន ។ នោះគឺ ទឹកភ្នែកនៃអំណរ ។ ខ្ញុំអរ ព្រោះភ្លើងសង្គ្រាមត្រូវរលត់ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ខ្ញុំរក្សាបាននូវភាពរឹងមាំ ទឹកចិត្តខ្លាំងក្លា ព្រោះខ្ញុំមិនងាយបង្ហូរទឹកភ្នែកដោយស្រួលៗឡើយ ។ ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំទប់ទឹកភ្នែកលែងបានដោយសារតែខ្ញុំមានសេចក្តីរំភើប និង ត្រេកអរខ្លាំងពេក ។ ខ្ញុំងើបមុខ សម្លឹងមើលមេឃនៃទីក្រុងប៉ារីស ហើយលាន់មាត់ទាំងទឹកភ្នែកថា "ព្រះអើយ នៅទីបំផុតសង្គ្រាមបានត្រូវបញ្ចប់" ។ គឺទីបញ្ចប់នៃសង្គ្រាមដ៏សាហាវ និង ទីបញ្ចប់នៃទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរនេះហើយ ដែលធ្វើឲ្យខ្ញុំត្រេកអររកទីបំផុតគ្មាន ។ ក្តីអំណររបស់ខ្ញុំមានទំហំធំធេងណាស់ ដែលធ្វើឲ្យខ្ញុំមានសុភមង្គលមិនអាចរកពាក្យអ្វីមកថ្លែងបានឡើយ ។ ដោយកាន់កាសែត ឡឺម៉ុង ជាប់នៅដៃផង ខ្ញុំមិនដើរដូចធម្មតាទេម្តងនេះគឺ ខ្ញុំរត់យ៉ាងលឿនដើម្បីនាំដំណឹងដ៏ល្អនោះ ទៅប្រាប់មិត្តភក្តិនៅកន្លែងធ្វើការ ។ នៅពេលទៅដល់ ពួកយើងជំនុំគ្នាអំពីសភាពការណ៍នៅកម្ពុជា ។

ពួកយើងមិនបានធ្វើការទៀតទេ ។ យើងជជែកគ្នារហូតដល់ម៉ោងចេញពីធ្វើការតែម្តង ។ មិត្តភក្តិជាច្រើន បានចូលរួមសប្បាយរីករាយជាមួយខ្ញុំ ។ ក៏ប៉ុន្តែបន្តិចម្តងៗ សេចក្តីត្រេកអររបស់យើង ក៏បានរសាត់ចេញទៅ ដោយយើងចាប់ផ្តើមទទួលបាននូវដំណឹងស្តីអំពីអំពើសាហាវយង់ឃ្នងរបស់ពួកខ្មែរក្រហម ។ ខ្ញុំចាប់ឆ្ងល់យ៉ាងខ្លាំង ចំពោះអ្វីៗដែលពួកខ្មែរក្រហមចាប់ធ្វើ ហើយខ្ញុំក៏ចាប់ផ្តើមមានការសង្ស័យ ចំពោះជោគជ័យរបស់ពួកខ្មែរក្រហមនេះដែរ ។ ពិភពលោកមានការភ្ញាក់ផ្អើលចំពោះវិធានការណ៍បណ្តេញប្រជាពលរដ្ឋចេញពីរាជធានីភ្នំពេញ ដែលពួកខ្មែរក្រហមចាត់ឡើងយ៉ាងព្រៃផ្សៃ ។ ខ្ញុំចាប់កើតមានអារម្មណ៍ច្របូកច្របល់គឺ ម្យ៉ាងអបអរសាទរ ចំពោះការបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃ ម្យ៉ាងភ្លាមៗនោះ ខ្ញុំក៏ចាប់ផ្តើមព្រួយបារម្ភ ចំពោះវាសនារបស់ឪពុកម្តាយ និង បងប្អូនជាទីស្រឡាញ់របស់ខ្ញុំនៅឯស្រុកខ្មែរដែរ ។

តាំងពីថ្ងៃនោះមក ខ្ញុំតែងទទួលនូវដំណឹងអាក្រក់ស្តីពីចំនួនកើនឡើងឥតឈប់ឈរនៃជនភៀសខ្លួនដែលបង្ខំចិត្តរត់ចូលស្ថានទូតបារាំង ព្រមទាំងការកាប់សម្លាប់ទាហាន និង មន្ត្រីនៃរបបសាធារណរដ្ឋ ការកាប់សម្លាប់សកម្មជននៃគណបក្សឯទៀត រួមផ្សំជាមួយនឹងការជន្លៀសប្រជាពលរដ្ឋចេញពីទីក្រុងដែលគ្មាននរណានឹកដល់ ។ ដំណឹងដែលយើងបានទទួលមួយទៀតគឺ ការបិទស្ថានទូតបរទេសលោកខាងលិចទាំងអស់នៅភ្នំពេញ ។ ក្រោយមក យើងលែងបានទទួលដំណឹងអ្វីច្រើនដូចមុនៗទៀតទាំងអស់ ក្រៅពីព័ត៌មានស្តីពីជនភៀសខ្លួនដែលរត់ទៅសុំសិទ្ធិជ្រកកោននៅស្ថានទូតបារាំង និង ការចរចារវាងមន្ត្រីស្ថានទូតបារាំងជាមួយខ្មែរក្រហមដើម្បីរំដោះជនភៀសខ្លួនទាំងនោះតែប៉ុណ្ណោះ ។

មិនយូរប៉ុន្មាន ពួកខ្មែរក្រហមបានសំរេចជោគជ័យ ទាំងស្រុងក្នុងការកាត់ផ្តាច់ប្រទេសកម្ពុជាពីពិភពលោកទាំងមូល ។ គ្មានអ្នកយកព័ត៌មានណាម្នាក់ អាចធ្វើដំណើរបានដោយសេរីនៅក្នុងប្រទេសនេះបានទៀតឡើយ ។ ជាមួយគ្នានោះ ម៉ា

ស៊ីនឃោសនារបស់ខ្មែរក្រហម នៅតែបន្តធ្វើការឃោសនាអំពីមហាជោគជ័យរបស់ពួកគេយ៉ាងខ្លាំងក្លាដដែល ។ ពួកគេបដិសេធព័ត៌មានស្ដីពីអំពើព្រៃផ្សៃរបស់ពួកគេដែលលេចឮចេញមកក្រៅប្រទេសទាំងអស់ថា គ្រាន់តែជាការឃោសនាបោកកុហករបស់ចក្រពត្តិអាមេរិក ប្រឆាំងបដិវត្តន៍កម្ពុជាតែប៉ុណ្ណោះ ។

ប៉ុន្មានខែមុនជ័យជំនះរបស់ខ្មែរក្រហម និស្សិតខ្មែរស្ទើរតែទាំងអស់នៅទីក្រុងប៉ារីស បានប្ដេជ្ញាគាំទ្ររណសិរ្សរបស់សម្ដេច នរោត្តម សីហនុ ដែលមានខ្មែរក្រហមជាឆ្អឹងខ្នងហើយដែលមានឈ្មោះថា រណសិរ្សរួបរួមជាតិកម្ពុជា (FUNK) ។ ចលនាគាំទ្ររបស់និស្សិតទាំងនេះ កាន់តែធំជាត់ និង សកម្មឡើង ដោយសារនៅទីបំផុត រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំងរបស់លោកប្រធានាធិបតី ហ្ស៊ីស្កា ដេស្តាំង (Giscard d'Estaing) ប្រកាសទទួលស្គាល់រដ្ឋាភិបាលក្រៅប្រទេសរបស់សម្ដេច នរោត្តម សីហនុ នៅខែ មេសា ១៩៧៥ គឺនៅមួយសប្ដាហ៍មុនថ្ងៃដួលរលំនៃរបប លន់ នល់ ។ គេអាចហៅថា ការទទួលស្គាល់នេះ ជាការទទួលស្គាល់នៅនាទីចុងក្រោយបង្អស់ ។

ក្នុងពេលកន្លងមក ខ្ញុំធ្លាប់បានត្រូវគេអញ្ជើញចំនួនបី ឬ បួនដងដែរឲ្យចូលរួមប្រជុំជាមួយពួកខ្មែរក្រហម ។ ខ្ញុំមិនសូវបានទៅចូលរួមប្រជុំទេ ដោយហេតុថា ខ្ញុំមិនចូលចិត្តច្រៀងបទទង់ក្រហមរបស់ពួកខ្មែរក្រហមទាល់តែសោះ ។ ចម្រៀងបទទង់ក្រហមនោះ ជាចម្រៀង ដែលគេត្រូវច្រៀងនៅពេលបញ្ចប់អង្គប្រជុំម្ដងៗ ដោយថែមទាំងត្រូវលើកដៃស្ដាំឡើងជាសញ្ញាប្ដេជ្ញាចិត្តទៀតផង ។ បទចម្រៀងនោះ ចាប់ផ្ដើមដូចជា "ឈាមក្រហមឆ្អៅក្រាលនៅលើប្រឹថពី ឈាមដែលពលីគឺឈាមប្រជាជន...." ។ នៅលើកនេះ ខ្មែរក្រហមបានរៀបចំអង្គប្រជុំធំមួយដើម្បីអបអរសាទរនូវជ័យជំនះរបស់ពួកគេ ។ ខ្ញុំគិតថា ខ្ញុំគួរតែចូលរួមប្រជុំក្រែងបានទទួលដំណឹងថ្មីៗពីប្រទេសកម្ពុជា ។ ដូច្នេះ ខ្ញុំក៏ទៅចូលរួមអបអរសាទរជ័យ

ជំនះរបស់ខ្មែរក្រហមដែរ ។ នៅពេលនោះ ខ្ញុំសង្កេតឃើញអ្នកគាំទ្រ និង អ្នកជិតស្និទ្ធជាមួយរបប លន់ នល់ ភាគច្រើន បាននាំគ្នាទៅគាំទ្រខ្មែរក្រហមវិញម្តង ។ នេះជាការបត់បែននយោបាយ ឲ្យទាន់ពេលវេលារបស់ពួកគេ ។ គួរឲ្យស្តាយ នៅទីបញ្ចប់នៃអង្គប្រជុំដ៏ធំនោះ ខ្ញុំមិនបានទទួលដំណឹងអ្វីទាំងអស់ពីស្រុកខ្មែរទេ ផ្ទុយទៅវិញខ្ញុំគ្រាន់តែបានទទួលការឃោសនាលើកសរសើរអង្គការ និង ថ្នាក់ដឹកនាំខ្មែរក្រហមតែប៉ុណ្ណោះ ។

## មិនចូលបដិវត្តន៍ព្រោះជាប់កំអែលមូលធននិយម

ជាច្រើនខែបន្ទាប់ពីជ័យជំនះរបស់ពួកគេ ពួកខ្មែរក្រហមនៅតែបន្តធ្វើការបញ្ចុះបញ្ចូលនិស្សិត ឬ ជនរួមជាតិដែលរស់នៅប្រទេសបារាំងឲ្យត្រឡប់ទៅប្រទេសកម្ពុជាវិញ ។ ពួកគេចាត់តាំងក្រុមកម្មាភិបាល និង សកម្មជនឲ្យដើរគោះទ្វារតាមផ្ទះ ដើម្បីធ្វើការបញ្ចុះបញ្ចូលនោះ ។ ក្រុមមួយ ដែលដឹកនាំដោយលោកស្រី ហ៊ីង អ៊ុន តែងតែមកគោះទ្វារផ្ទះខ្ញុំរាល់ល្ងាច ដើម្បីអូសទាញខ្ញុំឲ្យគាំទ្រអង្គការរបស់គេ និង បបួលខ្ញុំឲ្យវិលត្រឡប់ទៅប្រទេសខ្មែរវិញ ។ ពួកគេតែងតែឃោសនាថា កម្ពុជាថ្មីគឺ ជាសង្គមយុត្តិធម៌ និង មានជីវភាពថ្មីល្អប្រសើរ ។ នៅពេលដែលខ្ញុំសាកសួរពួកគេថា ហេតុអ្វីបានប្រជាជននៃកម្ពុជាថ្មី មិនអាចផ្លាស់ប្តូរលិខិតឆ្លើយឆ្លង ឬ ទាក់ទងជាមួយនឹងឪពុកម្តាយបងប្អូនបាន ពួកគេឆ្លើយថា ប្រជាជនថ្មីនៅក្នុងកម្ពុជាថ្មីរវល់ជាប់ដៃកសាងប្រទេសជាតិ គ្មានពេលឯណាមកសរសេរកំណាព្យកាព្យឃ្លោង ឬ សំបុត្រឆ្លងឆ្លើយទាក់ទងគ្នាលេងនោះទេ ។ ដើម្បីឈប់ឲ្យពួកក្រុមនោះមកទាក់ទងខ្ញុំទៀត ខ្ញុំបានប្រាប់ពួកក្រុមខ្មែរក្រហមនោះថាខ្ញុំនៅជាប់កំអែលមូលធននិយមក្រាស់ណាស់ ខ្ញុំមិនទាន់អាចចូលទៅបំរើបដិវត្តន៍បាននៅឡើយទេ ។

បន្ទាប់ពីខ្មែរក្រហមផ្តួលរលំរបប លន់ នល់ ភ្លាម ខ្ញុំធ្លាប់បានធ្វើពាក្យសុំទៅពួកខ្មែរក្រហមឲ្យទទួលស្គាល់នូវសញ្ជាតិខ្មែររបស់ខ្ញុំឡើងវិញ ក៏ប៉ុន្តែពួកគេមិនដែលឆ្លើយតបមកវិញម្តងណាឡើយ ។ តាមពិតទៅ ខ្ញុំមានសំណាងណាស់ ដែលបានកាត់ចំណងជាមួយពួកខ្មែរក្រហមទាន់ពេលវេលា ។ ជនរួមជាតិមួយចំនួនបានសុខចិត្តវិលត្រឡប់ទៅប្រទេសខ្មែរវិញ ហើយក៏ត្រូវបាត់ខ្លួន ឬ ក៏ដាច់ការទាក់ទងគ្នាជារៀងរហូត នៅពេលជាន់ទឹកដីខ្មែរភ្លាម ។ ចំពោះជនរួមជាតិមួយចំនួនដែលត្រូវបង្ខំចិត្តបន្តរស់នៅប្រទេសបារាំង ពួកគេទទួលរងទុក្ខវេទនា ដោយសារការព្រាត់ប្រាសបងប្អូនញាតិមិត្តជាទីស្រឡាញ់ ។ ពួកគេត្រូវបន្តធ្វើការប្រយុទ្ធ ដើម្បីជីវភាពប្រចាំថ្ងៃ ជាពិសេសស្វែងរកលក្ខន្តិកៈជាជនភៀសខ្លួន និង ខិតខំរកការងារធ្វើឲ្យបាន ។ បើប្រៀបធៀបជាមួយជនរួមជាតិទាំងនោះ ខ្ញុំហាក់ដូចជាមានសំណាងជាងពួកគេទាំងនោះណាស់ ។

## ស្ថានភាពជនភៀសខ្លួនខ្មែរនៅទីក្រុងប៉ារីស

មុនពេលទីក្រុងភ្នំពេញធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហម មិត្តភក្តិរបស់ខ្ញុំមួយចំនួនដែលធ្វើការក្នុងក្រុមហ៊ុនកូមិន្ទខ្មែរ តែងផ្ញើសំបុត្រមកខ្ញុំយ៉ាងទៀងទាត់ ដើម្បីឲ្យខ្ញុំដឹងពីសភាពការណ៍ទាំងឡាយដែលកើតនៅក្នុងប្រទេសកម្ពុជា ។ ក្នុងចំណោមអ្នកទាំងនោះ មាននារីចំណាស់ម្នាក់ឈ្មោះ ម៉ារី ហ៊ុម បានជូនដំណឹងមកខ្ញុំថា គាត់មានក្មួយស្រីម្នាក់ និង ប្តីរបស់ក្មួយស្រីនោះ កំពុងរស់នៅក្នុងប្រទេសបារាំងនេះដែរ ។ អ្នកស្រី ម៉ារី ហ៊ុម បានផ្តាំឲ្យខ្ញុំជួយមើលក្មួយគាត់ទាំងពីរនាក់នេះផង ក្នុងករណីដែលអ្នកទាំងពីរត្រូវការឲ្យខ្ញុំជួយ ។ ប្តីប្រពន្ធទាំងពីរនាក់នោះ រស់នៅដោយមធ្យោបាយផ្ទាល់ខ្លួន និង ដោយបានទទួលប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល លន់ នល់

រហូតដល់ថ្ងៃទី ១៧ មេសា ១៩៧៥ ។ រហូតមកដល់ពេលនោះ ប្តីប្រពន្ធទាំងពីរនាក់ មិនដែលមានការទាក់ទងជាមួយខ្ញុំឡើយ ។ ជាមួយនឹងការដួលរលំនៃរបបសាធារណរដ្ឋ អ្នកទាំងពីរក៏ពុំមានធនធានគ្រប់គ្រាន់សំរាប់រស់នៅតទៅទៀត ។ ពួកគេត្រូវការរកការងារធ្វើ ។ នៅពេលនោះ ទើបពួកគេសុំឲ្យខ្ញុំជួយ ។ ក្មួយស្រីរបស់អ្នកស្រី ម៉ារី ហ៊ុម នោះ ឈ្មោះ សូនី ឯប្តីនាងឈ្មោះ ឃឹម ខាន់កែវ ។ អ្នកទាំងពីរសុទ្ធតែចេញមកអំពីគ្រួសារអ្នកធំនៅប្រទេសខ្មែរ ។ ឃឹម ខាន់កែវ ជាចៅរបស់លោកអតីតនាយករដ្ឋមន្ត្រី ឃឹម ទិត ។ ឃឹម ខាន់កែវ ជាអ្នកជិតស្និទ្ធនឹងលោក លន់ ណុន ដែលត្រូវជាប្អូនលោក លន់ នល់ ។ ឯចំណែក សូនី ជាកូនរបស់លោក សារ៉ាត ហ៊ុម ដែលជារដ្ឋលេខាធិការម្នាក់នៃរបប លន់ នល់ ។ លោក សារ៉ាត ហ៊ុម ធ្លាប់ធ្វើជាចៅហ្វាយខេត្តនៅខេត្តកំពង់ធំផង ។ ចាប់តាំងពីថ្ងៃជ័យជំនះរបស់ពួកខ្មែរក្រហមមក អ្នកទាំងពីរខិតខំស្វះស្វែងរកការងារធ្វើដែរ តែរកពុំបាន ។ ថ្ងៃមួយ ឃឹម ខាន់កែវ ស្នើសុំជួបខ្ញុំ ។ គេមានលក្ខណៈខ្មែរសុទ្ធ សម្បុរស្រអែម ប្រកបដោយសក់រួញអង្គាជីដ៏ក្រាស់ ។ ឃឹម ខាន់កែវ ជាមនុស្សចូលចិត្តនិយាយច្រើនគឺ និយាយមិនចេះឈប់ ។ គាត់មានអាយុច្រើនជាងខ្ញុំតែជាការគួរសម គាត់ហៅខ្ញុំបងទៅវិញ ។ គាត់និយាយសរសើរលើកជើងខ្ញុំថា ខ្ញុំជាមនុស្សមានសំណាង ចេះកសាងជីវិតបានល្អ និង ប្រកបដោយជោគជ័យនៅប្រទេសបារាំង ។ មួយរំពេចនោះ ខ្ញុំក៏រាប់អានគាត់ភ្លាម ។ គាប់ជួនក៏ជាសំណាងល្អរបស់គាត់ដែរ ព្រោះនៅពេលដែលគាត់បង្ហាញខ្លួន ចំពោះមុខខ្ញុំនោះ ខ្ញុំកំពុងត្រូវការរកជំនួយការម្នាក់ ។ ព្រោះថាអស់រយៈច្រើនខែមកហើយ ដែលខ្ញុំត្រូវបានតម្លើងឋានៈ ជាប្រធានក្រុមគណនេយ្យជំនួសអ្នកស្រី ដឺបែហ្ស ដែលចេញទៅធ្វើការជានាយកក្រុមគណនេយ្យនៃក្រុមហ៊ុនលក់ពេជ្រមួយ នៅទីក្រុងប៉ារីស ។ ដូច្នេះកន្លែងចាស់របស់ខ្ញុំក៏

នៅទំនេរដែរ ។ ភ្លាមៗនោះខ្ញុំក៏ទទួលជ្រើសរើសយក ឃឹម ខាន់កែវ ជាជំនួយការរបស់ខ្ញុំតាំងពីថ្ងៃនោះរៀងមក ។

នៅក្នុងប្រទេសបារាំង ខ្ញុំពុំសូវមានមិត្តភក្តិច្រើនទេ ក៏ប៉ុន្តែមិត្តភក្តិដែលខ្ញុំមានទាំងប៉ុន្មាននោះ សុទ្ធតែជាមិត្តភក្តិដ៏ជិតស្និទ្ធ ដែលមានភក្តីភាពយ៉ាងស្មោះសរវាងគ្នា និង គ្នា ហើយដែលអាចពឹងពាក់គ្នាបាន ។ គ្រីស្យាន ដឺបែហ្ស (Christiane Debaize) និង ប្តីរបស់គាត់ឈ្មោះ រ៉ូឡង់ រូស្សូ (Roland Rousseau) ជាមិត្តភក្តិនៅក្នុងប្រភេទមិត្តដ៏ល្អកម្ររកបាន ។ នៅគ្រាដំបូង ដែលខ្ញុំបានជួបពួកគេទាំងពីរនាក់ អ្នកទាំងពីរមិនបានរស់នៅជាមួយគ្នាទេគឺ គ្រីស្យាន រស់នៅក្នុងទីក្រុងម៉ុងត្រើយ (Montreuil) ឯរ៉ូឡង់ រស់នៅទីក្រុងព្យែរហ្វិត (Pierrefitte) ជាយក្រុងខាងជើងទីក្រុងប៉ារីស ។ អ្នកទាំងពីរស្រឡាញ់គ្នាយ៉ាងខ្លាំង ទោះបីជាមានការប៉ះទង្គិចពាក្យសំដីរវាងគ្នាជាញឹកញាប់យ៉ាងណាក៏ដោយ ក៏មិនអាចបំបែកបំបាក់សេចក្តីស្នេហារបស់គេទាំងពីរបានឡើយ ។ ជារឿយៗ នៅពេលគេដើរកំសាន្តនៅស្រុកស្រែនាចុងសប្តាហ៍ ឬ ចេញទៅទទួលទានអាហារពេលល្ងាចតាមភោជនីយដ្ឋានធំៗ ពួកគេទាំងពីរតែងនាំខ្ញុំទៅជាមួយ ។ កាលសម័យនោះ រ៉ូឡង់ ជាអធិការនៃក្រុមហ៊ុនធានារ៉ាប់រងលើអាយុជីវិត ។ មិត្តភក្តិខ្ញុំជាច្រើនតែងនិយាយចំអន់ឲ្យគាត់ថា "ជាមនុស្សលក់ខ្យល់" ។ រ៉ូឡង់ ធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងការិយាល័យមេធាវី និង ការិយាល័យជំនាញគណនេយ្យ ។ សូមរំលឹកថា មុនពេលដែល គ្រីស្យាន ចេញទៅធ្វើការនៅកន្លែងផ្សេង គាត់បានសំរួលជាមួយថៅកែធំនៅក្រុមហ៊ុនទេសចរណ៍ ឲ្យខ្ញុំទៅកាន់តំណែងជំនួសគាត់ដែលជាប្រធានក្រុមគណនេយ្យ ។ ដូច្នេះហើយ បានជានៅខែ កក្កដា ១៩៧៥ ខ្ញុំត្រូវបានឡើងឋានៈជាគណនេយ្យករថ្នាក់ទី២ (Comptable 2$^{em}$ Echelon) ។ តាមរបៀបរបបនៅប្រទេសបារាំង ឋានៈវិជ្ជាជីវៈនេះសមរម្យចំពោះខ្ញុំណាស់ ក៏ប៉ុន្តែប្រាក់ខែ ២៣០០ ហ្វ្រង់

ក្នុងមួយខែមិនសមស្របនឹងលក្ខន្តិកៈវិជ្ជាជីវៈឡើយ ។ ថៅកែរបស់ខ្ញុំដឹងច្បាស់ថា ខ្ញុំពិតជាមានគុណសម្បត្តិ ដើម្បីបំពេញមុខងារនេះ ក៏ប៉ុន្តែគាត់ក៏ដឹងដែរថា ប្រសិនបើប្រៀបធៀបទៅនឹងអ្នកឯទៀត ដែលបំពេញមុខនាទីដូចគ្នានេះ ប្រាក់ខែខ្ញុំប្រាកដជាទាបជាងគេ ។ រ៉ូឡង់ សប្បាយចិត្តនឹងការឡើងឋានៈរបស់ខ្ញុំ ក៏ប៉ុន្តែគាត់ក៏មានការអាក់អន់ចិត្តចំពោះប្រាក់ខែដ៏តូចទាបរបស់ខ្ញុំ ។

ទោះបីជាគាត់លែងធ្វើការនៅក្រុមហ៊ុនទេសចរណ៍នេះយ៉ាងណា ក៏ដោយក៏គ្រីស្យាន តែងមកលេងខ្ញុំជាញឹកញាប់ ។ ចំណែកខ្ញុំវិញ ខ្ញុំក៏ខិតខំពង្រឹងនូវមិត្តភាពរបស់យើងគឺរវាងគាត់ និង ខ្ញុំក៏ដូចជាជាមួយ រ៉ូឡង់ ស្វាមីគាត់ដែរ ។ យើងបន្តដើរលេងជាមួយគ្នា ទូរស័ព្ទឆ្លងឆ្លើយគ្នាជាញឹកញាប់រហូតដល់ក្លាយជាមនុស្សជិតស្និទ្ធ ដូចជារស់នៅក្នុងរង្វង់គ្រួសារតែមួយយ៉ាងដូច្នោះដែរ ។ ក្នុងល្ងាចមួយនាខែកញ្ញា ១៩៧៥ រ៉ូឡង់ និង គ្រីស្យាន បានបបួលខ្ញុំជិះរថយន្តទៅទទួលទានអាហារពេលល្ងាចនៅទីក្រុងប៉ារីស ។ នៅពេលនោះ រ៉ូឡង់ និយាយប្រាប់ខ្ញុំថាគាត់រកការងារថ្មីឲ្យខ្ញុំធ្វើ គឺជាការងារដែលល្អប្រសើរសំរាប់ខ្ញុំនៅទីក្រុងព្យែរហ្វិតជាទីក្រុងដែលគាត់ស្នាក់អាស្រ័យនៅ ។ គាត់បានរៀបចំឲ្យខ្ញុំទៅជួបប្រធានក្រុមហ៊ុនថ្មីនៅរសៀលថ្ងៃបន្ទាប់ ។ នៅពេលទទួលទានអាហារពេលល្ងាចនោះ រ៉ូឡង់ មិនបាននិយាយអ្វីច្រើនអំពីក្រុមហ៊ុនថ្មី និង ការងារថ្មីដែលខ្ញុំត្រូវធ្វើនោះទេ ។

## ឡើងឋានៈដោយមិនដឹងខ្លួន

ដូចបានគ្រោងទុកស្អែកឡើង រ៉ូឡង់ បានទៅទទួលខ្ញុំពីក្រុមហ៊ុនទេសចរណ៍ហ្វារ៉ូសហ្វ្រង់ (Pharos France) ។ គាត់បររថយន្តនាំខ្ញុំពីទីក្រុងប៉ារីស មកទីក្រុង

ដ៏តូចមួយនោះ ដែលមានប្រជាពលរដ្ឋភាគច្រើនជាកម្មករ ឬ ជាអ្នកធ្វើការថ្នាក់កណ្តាល ។ ពេលនោះគឺជាលើកទីមួយហើយដែលខ្ញុំបានធ្វើដំណើរ ឆ្លងកាត់ជាយក្រុងផ្នែកខាងជើងនៃទីក្រុងប៉ារីស ។ នៅក្នុងរថយន្ត រ៉ូឡង់ ព្យាយាមណែនាំពន្យល់ខ្ញុំឲ្យស្គាល់ពីភូមិសាស្ត្រនៃតំបន់នោះ គាត់ប្រាប់ឈ្មោះ និង សកម្មភាពរបស់ទីក្រុងនានាដែលយើងឆ្លងកាត់ ។ ក៏ប៉ុន្តែនៅពេលនោះ ខ្ញុំមិនបានចាប់អារម្មណ៍អ្វីធំដុំឡើយ ព្រោះខ្ញុំកំពុងខ្វល់ខ្វាយត្រៀមខ្លួនទៅធ្វើសម្ភាសន៍ជាមួយថៅកែថ្មី ។ តាមពិតខ្ញុំត្រូវសម្ភាសន៍ជាមួយប្រធានក្រុមហ៊ុនម្នាក់ ដែលគ្រប់គ្រងក្រុមហ៊ុនពីរ មួយឈ្មោះក្រុមហ៊ុន ម៉ុត្តុង (Motton) និង មួយទៀតឈ្មោះក្រុមហ៊ុន តេប៉េប៉េ (TPP) ។ ខ្ញុំត្រូវប្រុងប្រៀបខ្លួនទៅធ្វើការនៅក្នុងក្រុមហ៊ុនទាំងពីរនេះ ដែលមានការិយាល័យជាប់គ្នានៅដើមផ្លូវតែមួយ ។ មុននឹងទៅជួបថៅកែធំថ្មី រ៉ូឡង់ បានផ្តល់យោបល់ដ៏សំខាន់មួយដល់ខ្ញុំគឺ កុំឲ្យប្រាប់គេតាមត្រង់ថា ខ្ញុំបានទទួលប្រាក់ខែប៉ុន្មាននៅក្នុងក្រុមហ៊ុនទេសចរណ៍ ហ្វារ៉ូសហ្វ្រង់ ។ រ៉ូឡង់ ចតរថយន្តតាមផ្លូវដ៏ចង្អៀតមួយឈ្មោះ ផ្លូវ ដឺ ប៉ារីស (de Paris) នៅចំពីមុខអាគាររបស់ក្រុមហ៊ុនដែលមានដាក់សញ្ញាថា អង់ ដ្រេ ម៉ុត្តុង (André Motton SA) ។ ពួកយើងនាំគ្នាឡើងជណ្តើរឆ្ពោះទៅជាន់ទីមួយដែលនៅពេលនោះ យើងបានទទួលស្វាគមន៍ពីលោកប្រធានធំ អង់ដ្រេ ម៉ុត្តុង (André Motton) ពីភរិយារបស់គាត់ឈ្មោះ អាន្នី ម៉ុត្តុង (Annie Motton) និង ពីគណនេយ្យករចាស់ដែលខ្ញុំត្រូវជំនួសឈ្មោះ ដានីញ៉ែល ឡាហ្សា (Daniel Lazard) ។ រ៉ូឡង់ ហាក់ដូចជាស្គាល់អ្នកទាំងនោះយ៉ាងជិតស្និទ្ធ ។ បន្ទាប់ពីបង្ហាញរូបខ្ញុំដល់អ្នកទាំងនោះ និង បន្ទាប់ពីបាននិយាយពាក្យកំប្លុកកំប្លែងពីរបីម៉ាត់រួចហើយ រ៉ូឡង់ ក៏ចេញទៅក្រៅ ដើម្បីទុកឱកាសឲ្យអ្នកទាំងនោះ ធ្វើសម្ភាសន៍ខ្ញុំ ។

យើងជួបជុំគ្នានៅក្នុងបន្ទប់ការិយាល័យរបស់លោក ម៉ុត្តុង ។ បន្ទប់នោះមានទំហំមធ្យម ហើយតាំងនៅចន្លោះការិយាល័យលេខាធិការ និង ការិយាល័យ

គណនេយ្យ ។ នៅក្នុងបន្ទប់នោះ ពុំមានកន្លែងអង្គុយរង់ចាំ ឬ សាឡុងទទួលភ្ញៀវទេ ។ ខ្ញុំអង្គុយលើកៅអីមួយដែលអ្នកស្រី ម៉ុត្តុង បានទាញយកមកបន្ថែមនៅខាងក្រោយលោកប្រធាន ។ លោក ម៉ុត្តុង បានពន្យល់ថា គាត់កំពុងត្រូវការរកមនុស្សម្នាក់មកធ្វើជាគណនេយ្យករជំនួសលោក ឡាហ្សា (Lazard) ដែលបានសំរេចលាចេញ និង រើទៅរស់នៅឯខេត្តខាងត្បូងនៃប្រទេសបារាំង ។ គាត់បានរ៉ាយរ៉ាប់ប្រាប់ខ្ញុំពីសកម្មភាពការងាររបស់ក្រុមហ៊ុនរបស់គាត់ទាំងពីរ ដែលមានបុគ្គលិកទាំងអស់ចំនួនជិត ២០០ នាក់ ។

បន្ទាប់មក លោក ឡាហ្សា ដែលជាគណនេយ្យករចាស់ បានបង្ហាញខ្ញុំនូវការងាររបស់គាត់ និង សួរខ្ញុំពីរបីម៉ាត់អំពីញ្ហាពន្ធដារ បញ្ហាសង្គមកិច្ច និង ច្បាប់ការងារ ។ នៅទីបញ្ចប់នៃកិច្ចសន្ទនា លោក ម៉ុត្តុង បានសំរេចផ្តល់ការងារឲ្យខ្ញុំធ្វើក្នុងឋានៈជាគណនេយ្យករដើមខ្សែ (Comptable Principal) ក្នុងរយៈពេលសាកល្បងបីខែ និង ស្នើឲ្យប្រាក់បៀវត្សដំបូងប្រចាំខែចំនួន ៤៥០០ ហ្វ្រង់គឺស្មើពីរដងនឹងប្រាក់ខែដែលខ្ញុំទទួលនៅក្រុមហ៊ុន ហ្វារ៉ូសហ្វ្រង់ ។ គាត់សន្យាថានៅពេលចប់ការសាកល្បង ខ្ញុំនឹងត្រូវតម្លើងឋានៈជាប្រធានគណនេយ្យករសំរាប់ក្រុមហ៊ុនទាំងពីរ ដែលមានប្រាក់បៀវត្សប្រចាំខែ ៥០០០ ហ្វ្រង់ ។ ខ្ញុំយល់ថា នេះជាសំណាងដ៏ល្អឥតខ្ចោះ ដែលខ្ញុំមិនដែលនឹកដល់ទាល់តែសោះ ។ ពេលនោះ ខ្ញុំមិនបានបណ្តោយឲ្យឱកាសកន្លងផុតទៅដោយទទេៗនោះទេ ។ ខ្ញុំយល់ព្រមទទួលតាមភ្លាម ។ យើងបានព្រមព្រៀងថា ខ្ញុំត្រូវចូលមកធ្វើការនៅថ្ងៃទី ៣ វិច្ឆិកា ១៩៧៥ ដើម្បីឲ្យខ្ញុំមានឱកាសគ្រប់គ្រាន់សំរាប់លាឈប់ពីការងារក្រុមហ៊ុនទេសចរណ៍ ហ្វារ៉ូសហ្វ្រង់ ។ បន្ទាប់មក យើងទាំងអស់គ្នា ក៏នាំគ្នាដើរទៅមើលអាគារផ្សេងៗ និង ការិយាល័យនានា ។ ពួកយើងចុះទៅកាន់ទីធ្លា ដែលព័ទ្ធជុំវិញទៅដោយសំណង់ឃ្លាំង សំណង់ជម្រកកម្មករ រួចដើរទៅផ្នែកខាងក្រោយទៀត ដែល

នៅទីនោះ មានរោងជាងជួសជុលរថយន្ត និង សម្ភារៈបច្ចេកទេសនានា ។ នៅជាន់ខាងក្រោម ជាប់នឹងមាត់ផ្លូវ ក្រុមហ៊ុនមានបន្ទប់តាំងលក់សម្ភារៈថ្មីៗដូចជាគ្រឿងប្រដាប់បន្ទប់ទឹក និង ប្រដាប់ផ្ទះបាយជាច្រើន ដែលគេអាចមើលពីក្រៅតាមជញ្ជាំងកញ្ចក់ ។ នៅចុងបញ្ចប់ យើងនាំគ្នាទៅទទួលទានកាហ្វេនៅហាងមួយ ដែលកាន់កាប់ដោយជនជាតិអាល់ហ្សេរី ឬ ទុយណេស៊ី ដែលយើងតែងហៅថាមីៗ ។ ទីបំផុត រ៉ូឡង់ ក៏មករួមទទួលទានកាហ្វេជាមួយយើង ដើម្បីអបអរសាទរដល់កិច្ចព្រមព្រៀងការងារថ្មីរបស់ខ្ញុំ ។

អង់ដ្រេ ម៉ុត្តុង ជាមនុស្សដែលកសាងជីវិតដោយខ្លួនឯង ។ នៅពេលដែលខ្ញុំទៅជួបគាត់ដំបូងនោះ គាត់ស្ថិតនៅក្នុងវ័យ ៤០ ឆ្នាំ គាត់រៀបការតាំងពីអាយុ ១៨ ឆ្នាំ ជាមួយនឹងប្រពន្ធគាត់ ដែលកាលនោះមានអាយុតែ ១៦ ឆ្នាំប៉ុណ្ណោះ ។ អ្នកទាំងពីរមានកូនស្រីពីរនាក់ ។ អ្នកស្រី ម៉ុត្តុង តែងតែធ្វើការជាជំនួយការ ឬ ជាលេខាធិការរបស់ប្តីគាត់ ។ លោក ម៉ុត្តុង រៀនមិនចប់វិទ្យាល័យទេ គាត់ចេញមកធ្វើការតាំងពីក្មេង ធ្វើជាជាងធ្វើបន្ទប់ទឹក ជាងធ្វើផ្ទះបាយ និង ជាជាងប្រក់ផ្ទះ ។ គាត់ចាប់ផ្តើមជាអ្នកស៊ីឈ្នួលគេ ប៉ុន្តែក្រោយមក គាត់ក៏បើកក្រុមហ៊ុនធ្វើម្ចាស់ការខ្លួនឯងតែម្តង ។ កាលពីពីរឆ្នាំមុន គាត់ក៏បានជួបដៃគូពីរនាក់ ម្នាក់ឈ្មោះ មីស្ហែល កាមុស (Michel Camus) ជាវិស្វករខាងសំណង់ និង ម្នាក់ទៀតឈ្មោះ ហ្សាក់ ហ្វុងតែន (Jacque Fontaine) ជាអ្នកជំនាញខាងសូរិយោដី ។ ពួកគេបានស្រុះស្រួលគ្នាបង្កើតជាក្រុមហ៊ុនថ្មីមួយទៀតឈ្មោះ តេប៉េប៉េ (TPP) ដែលនៅក្នុងនោះគ្រួសារ ម៉ុត្តុង មានភាគហ៊ុនចំនួន ៨០ ភាគរយ ។ ចំណែកឯដៃគូពីរនាក់នោះ គឺ កាមុស និង ហ្វុងតែន ជាអ្នកគ្រប់គ្រងការងារប្រចាំថ្ងៃ ព្រោះម្យ៉ាងពួកគេមានជំនាញផង និង ម្យ៉ាងទៀតពួកគេបាននាំនូវអតិថិជនពីក្រុមហ៊ុនចាស់របស់ពួកគេ

ផង ។ កាមុស និង ហ្មុងតែន ជាមិត្តជិតស្និទ្ធគ្នា ដែលធ្លាប់ធ្វើការជាមួយគ្នាអស់រយៈពេលយ៉ាងយូរ នៅក្នុងក្រុមហ៊ុនសាធារណការមួយដែលត្រូវក្ស័យធន ។

នៅពេលនោះ លោក ម៉ុត្តុង ក៏បានកែប្រែក្រុមហ៊ុនរបស់គាត់ ឲ្យក្លាយទៅជាក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានឈ្មោះថា ក្រុមហ៊ុនអនាមិក ម៉ុត្តុង (Motton SA) ដោយមានភរិយាគាត់ និង ញាតិមិត្តគាត់ជាសមាជិកភាគហ៊ុន ។ ក្រុមហ៊ុនទាំងពីរ ធ្វើការបំរើអតិថិជនដ៏ធំមួយគឺ ក្រុមហ៊ុនរដ្ឋឈ្មោះស៊ីក (SCIC) ។ ក្រុមហ៊ុនលោក ម៉ុត្តុង ទទួលការផ្នែកទុយោហ្គាស ម៉ាស៊ីនកំដៅ និង ប្រក់ដំបូល ចំណែកឯក្រុមហ៊ុន តេប៉េប៉េ ធ្វើការផ្នែកសាធារណការ ជាពិសេសផ្លូវតូចៗ និង កន្លែងចតរថយន្ត ។

ថៅកែចាស់របស់ខ្ញុំលោក អាមីញ៉េល ខឹងសម្បារនឹងខ្ញុំយ៉ាងខ្លាំងចំពោះសេចក្ដីសំរេចចិត្តរបស់ខ្ញុំឈប់ធ្វើការជាមួយគាត់ ។ ក៏ប៉ុន្តែតាមពិតទៅ នោះជាសិទ្ធិរបស់ខ្ញុំ ព្រោះពួកយើងរស់នៅក្នុងសង្គម និង ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ជាទីដែលយើងធ្វើអ្វីៗទៅតាមកំលាំងនៃទីផ្សារគឺ ទីណាគេឲ្យប្រាក់ច្រើន យើងនឹងទៅធ្វើការនៅទីនោះ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនភ្លេចគុណក្រុមហ៊ុនទេសចរណ៍ហ្វ្រាំសហ្វ្រង់ ដែលបានរើសខ្ញុំយកមកធ្វើការនៅលើកដំបូង ទោះជាខ្ញុំមិនទាន់មានសិទ្ធិធ្វើការក៏ដោយ ។ នៅទីបំផុត ការចាកចេញរបស់ខ្ញុំក៏ត្រូវបានស្រុះស្រួលគ្នា ពុំមានបញ្ហាអ្វីឡើយ ព្រោះខ្ញុំបានដាក់ពាក្យសុំលាឈប់ក្នុងរយៈពេលដ៏សមគួរត្រឹមត្រូវតាមច្បាប់អស់ហើយ ។

នៅថ្ងៃទី ៣ វិច្ឆិកា ១៩៧៥ ខ្ញុំក៏ចាប់ផ្ដើមទៅធ្វើការ នៅក្រុមហ៊ុន ម៉ុត្តុង នៅទីក្រុងព្យែរហ្វិត ។ ខ្ញុំចេញដំណើរពីព្រឹក ដោយជិះម៉េត្រូនៅស្ថានីយ អាឡេស្យា (Alésia) ទៅស្ថានីយដីឡូហ្គាឌុយណ័រ (La Gare du Nord) ដើម្បីបន្តជិះ

រទេះភ្លើងពីក្រុងប៉ារីស ទៅទីក្រុងព្រៃហ្វឺត ។ បើមិននិយាយពីពេលវេលារង់ចាំ យើងធ្វើដំណើរពីប៉ារីស ទៅព្រៃហ្វឺត តែដប់ប្រាំនាទីតែប៉ុណ្ណោះ ។ ពីស្ថានីយរថភ្លើងខ្ញុំដើរតាមផ្លូវអស់រយៈពេលដប់នាទីទៀត ទើបដល់កន្លែងធ្វើការ ។ នៅពេលខ្ញុំទៅដល់ ថៅកែធំ និង ភរិយាគាត់ បានចាប់ផ្តើមធ្វើការជាស្រេច ។ គាត់កំពុងមើលការបែងចែកភារកិច្ចដល់កម្មករទាំងអស់ និង ត្រួតពិនិត្យការចេញដំណើររបស់ពួកគេ ឆ្ពោះទៅកាន់ការដ្ឋាននីមួយៗនៅក្នុងក្រុង និង ជាយក្រុង ។

មុននឹងចាប់ផ្តើមការងារដំបូងរបស់ខ្ញុំ អ្វីដែលថៅកែឲ្យខ្ញុំធ្វើនោះគឺ គាត់នាំខ្ញុំទៅទទួលទានកាហ្វេនៅតៀមកាហ្វេមីៗជាថ្មីម្តងទៀត ។ ការងារនៅថ្ងៃទីមួយរបស់ខ្ញុំនោះ បានត្រូវសំរួលយ៉ាងខ្លាំង ព្រោះលោក ឡាហ្វ្រា ប្រញាប់ប្រញាល់ប្រគល់ការងារឲ្យខ្ញុំ ដើម្បីគាត់បានចេញដំណើរយ៉ាងឆាប់រហ័សទៅកន្លែងថ្មីរបស់គាត់ ។ ខ្ញុំចំណាយពេលពេញមួយថ្ងៃជាមួយគាត់រៀនសូត្រពីគាត់នូវការងារជំនាញមួយចំនួន ។ ឡាហ្វ្រា មានអាយុច្រើនជាងខ្ញុំ តែគាត់ពុំទាន់មានភរិយាទេ នៅពេលនោះ ។ ខ្ញុំមិនបានដឹងចំណេះវិជ្ជារបស់គាត់ដល់កំរិតណាទេ ប៉ុន្តែគាត់ហាក់បីដូចជាមានការឈ្លាសវៃក្នុងល្បិចកលមួយចំនួន ក្នុងការបង់ពន្ធដារឲ្យបានតិច ។ បន្ទាប់ពីចប់ការងារហើយ យើងទាំងអស់គ្នាក៏ចាកចេញទៅទទួលទានអាហារពេលល្ងាច ។ យើងទទួលទានស្រា និង ស្តាប់ភ្លេងជាច្រើនកន្លែង នៅទីក្រុងព្រៃហ្វឺតផង នៅទីក្រុងប៉ារីសផង ។ ឡាហ្វ្រា ទទួលទានស្រា រីកា (Ricard) ស្រាបៀរ ស្រាក្រហម និង ស្រាគោញាក់យ៉ាងច្រើន ។ ឡាហ្វ្រា ហាក់ដូចជាមានកំលាំងមាំមួន ហើយគាត់អាចផឹកស្រាពេញមួយយប់ក៏បាន ។ ខ្ញុំខំព្យាយាមធ្វើដូចគាត់ដែរ ក៏ប៉ុន្តែខ្ញុំមិនមានបទពិសោធន៍ដូចគាត់ឡើយ ដូច្នេះខ្ញុំក៏ស្រវឹងស្រាយ៉ាងត្រឡប់ត្រឡិនមិនដឹងខ្លួន ហើយមិនអាចត្រឡប់ទៅផ្ទះ នៅឯ អាឡេស្យា បានឡើយ ។

ស្អែកឡើង យើងក៏បែកគ្នា ហើយតាំងពីពេលនោះមក ខ្ញុំក៏ពុំដែលឮឈ្មោះឡាហ្សា រហូតរៀងមក ។ ក្នុងឋានៈជាគណនេយ្យករប្រចាំក្រុមហ៊ុន ក្រៅពីការងារប្រចាំថ្ងៃផ្នែកគណនេយ្យ ខ្ញុំមានការទទួលខុសត្រូវមួយទៀតគឺ ផ្តល់មតិណែនាំឲ្យថៅកែខ្ញុំបំពេញភារកិច្ចរបស់គាត់ឲ្យបានត្រឹមត្រូវតាមច្បាប់ និង បទដ្ឋាននានា ជាពិសេសឲ្យត្រឹមត្រូវតាមច្បាប់ពាណិជ្ជកម្ម និង ច្បាប់ការងាររបស់បារាំង ។ លោក ម៉ុត្តុង និង ភរិយាតែងចាត់ទុកខ្ញុំជាទីប្រឹក្សាផ្ទាល់ផ្នែកច្បាប់ និង ពន្ធដារ ។ នៅពេលនោះ ខ្ញុំប្រហែលជាបញ្ញវន្តតែម្នាក់គត់ នៅក្នុងក្រុមហ៊ុនដែលធ្វើឲ្យមុខនាទីរបស់ខ្ញុំ បានទទួលការគោរព និង លើកកំពស់ជាពិសេស ។ ដើម្បីជួយគណនេយ្យករឲ្យបំពេញភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវហ្មត់ចត់នោះ ក្រុមហ៊ុនបានជួលមេធាវីម្នាក់ និង អ្នកជំនាញការគណនេយ្យម្នាក់ទៀត ដើម្បីឲ្យខ្ញុំពិគ្រោះយោបល់តាមត្រូវការ ។ បន្ថែមលើនេះ អ្នកជំនាញការគណនេយ្យនោះជួយពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ខ្ញុំ នៅរាល់ដំណាច់ឆ្នាំសារពើពន្ធនានា មុននឹងបញ្ជូនទៅ ក្រសួងពន្ធដារ ។

ក្រោយពីខ្ញុំបានធ្វើការសាកល្បងគ្រប់បីខែហើយលោក ម៉ុត្តុង ក៏បានបញ្ចូលឈ្មោះខ្ញុំជាម្ចាស់ភាគហ៊ុនមួយ នៅក្នុងក្រុមហ៊ុនរបស់គាត់ ក៏ប៉ុន្តែតាមពិតទៅ ខ្ញុំគ្រាន់តែប្រគល់ឈ្មោះឲ្យគាត់តែប៉ុណ្ណោះ ដោយខ្ញុំពុំបានបង់ប្រាក់កាសអ្វីឡើយ ។ ប្តូរនឹងភាគហ៊ុននោះ ខ្ញុំក៏បានចុះហត្ថលេខាលើក្រដាស "ស" មួយសន្លឹក ដែលលោក ម៉ុត្តុង រក្សាទុកក្នុងទូដែករបស់គាត់យ៉ាងប្រយ័ត្នប្រយែងជាទីបំផុត ។ ដោយសារទំនាក់ទំនងការងារល្អ ខ្ញុំក៏បានក្លាយជាមិត្តជិតស្និទ្ធជាមួយលោក ដែលម៉ាន់ (Delman) មេធាវី និង លោក ហុឡង់ដែរ (Hollander) អ្នកជំនាញការគណនេយ្យផងដែរ ។ ខ្ញុំក៏ក្លាយជាដៃគូដ៏ជិតស្និទ្ធ ច្បាស់លាស់របស់អ្នកទាំងពីរ ដោយហេតុថាលោក ម៉ុត្តុង បានផ្តល់សិទ្ធិពេញទីដល់ខ្ញុំចំពោះរាល់ករណីដែលទាក់ទងនឹងច្បាប់ទម្លាប់គណនេយ្យ និង បញ្ហាពន្ធដារ ។

នៅក្នុងក្រុមហ៊ុនរបស់គាត់ លោក ម៉ុត្តុង ធ្វើការជាមួយនឹងញាតិមិត្តរបស់គាត់ ។ គាត់ប្រើឪពុកក្មេកគាត់ ដែលគេហៅថា "ណូណូ" (No No) ជាអ្នកបើកបររថយន្ត ឯប្អូនថ្លៃរបស់គាត់ឈ្មោះ ហ្សង់ ប៉ូល (Jean Paul) ជាអ្នកកាន់កាប់ឃ្លាំង ។ ប្អូនថ្លៃគាត់ម្នាក់ទៀតគឺ ប្តីរបស់ប្អូនស្រីគាត់ឈ្មោះ ដានីញ៉ែល (Daniel) ជាជាងជួសជុលរថយន្តរបស់ក្រុមហ៊ុន ។ ជារៀងរាល់ថ្ងៃ នៅពេលចប់ការងារ ឲ្យតែមានឱកាស ដានីញ៉ែល តែងតែរកវិធីជួបជុំគ្នាអបអរសាទរអ្វីមួយ ដើម្បីនាំគ្នាផឹកស្រា ។ ញាតិមិត្តទាំងអស់នោះមិនយូរប៉ុន្មានបានក្លាយជាមិត្តជិតស្និទ្ធរបស់ខ្ញុំ ។ អ្នកទាំងនោះធ្វើអំពើល្អជាច្រើនចំពោះខ្ញុំ ។ ជាច្រើនដងក្នុងមួយអាទិត្យៗ អ្នកទាំងនោះច្រើនស្រវឹងស្រា ជាពិសេស ដានីញ៉ែល ។ លោក ម៉ុត្តុង មិនដែលចាត់ទុកអ្នកទាំងនោះថាជា ឪពុកក្មេក ឬ ប្អូនថ្លៃទេ គាត់ចាត់ទុកអ្នកទាំងនោះជាកម្មករ ឬ អ្នកធ្វើការដូចគេដូចឯងដែរ មិនតែប៉ុណ្ណោះ គាត់មានភាពហ្មត់ចត់ ម៉ិតប្រៃជាងកម្មករ ឬ អ្នកធ្វើការឯទៀតផង ។ ជាញឹកញាប់ ខ្ញុំតែងឮសម្លេងស្រែកជេរ ឬ ស្តីបន្ទោសខ្លាំងៗ ដែលថៅកែខ្ញុំស្រែកដាក់អ្នកទាំងនោះ ដែលគេអាចស្តាប់ឮពីចម្ងាយរាប់រយម៉ែត្រ ។ អ្នកទាំងនោះ ទោះជាយ៉ាងណាក៏ដោយ ក៏ហាក់ដូចជាស្រឡាញ់រាប់អានថៅកែខ្ញុំខ្លាំងណាស់ ពួកគេតែងហៅឈ្មោះគាត់បែបស្រឡាញ់ថា "ដេដេ"(DéDé) ។

អស់រយៈពេលបីសប្តាហ៍ បន្ទាប់ពីខ្ញុំចូលធ្វើការក្រុមហ៊ុនរបស់គាត់មក លោក ម៉ុត្តុង បានរកឲ្យខ្ញុំនូវផ្ទះមួយដែលមានមួយបន្ទប់ មានតម្លៃឈ្នួលថោកជាងបន្ទប់ខ្ញុំជួលនៅឯទីក្រុងប៉ារីសទៅទៀត ។ ផ្ទះនោះ ស្ថិតនៅទីក្រុង ជិតខាងមួយឈ្មោះថាទីក្រុង ស្តាំង (Stains) នៅលេខ ៦ ផ្លូវ ប៉ូល ឡង់ហ្សឺវ៉ាំង (Paul Langevin) ។ ផ្ទះនេះស្ថិតនៅក្នុងតំបន់ជាប់គ្នារវាងទីក្រុងសាកសែល (Sarcelles) ស្តាំង និង ព្យែរហ្វិត ។ ផ្ទះនោះស្ថិតនៅ ជាន់ទី ៣ ដែលជាជាន់ខ្ពស់ផុតពីគេ នៅក្នុងអាគារមួយដែលមានភាពស្ងប់ស្ងាត់ និង សួនច្បារជាលំអផង ។ ផ្ទះនេះ មិន

មានគ្រឿងសង្ហារឹមអ្វីទេគឺ ជាតួផ្ទះទទេ ក៏ប៉ុន្តែខ្ញុំចំណាយប្រាក់ឈ្នួលតែ ៣០០ ហ្វ្រង់ ប៉ុណ្ណោះក្នុងមួយខែ ។ មុននឹងចូលនៅ លោក ម៉ុត្តុង បានបញ្ជាកម្មកររបស់គាត់ឲ្យជួយសំអាត និង លាបពណ៌បន្ទប់ឲ្យថ្មីឡើងវិញ ។ គាត់ប្រើឪពុកក្មេកគាត់ ណូ ណូ ឲ្យយករថយន្តរបស់ក្រុមហ៊ុនទៅដឹកអីវ៉ែអីវ៉ាន់របស់ខ្ញុំនៅទីក្រុងប៉ារីសមកផ្ទះថ្មីនោះ ។ តាមខ្ញុំស្មាន ណូ ណូ ប្រហែលជាមានការខកចិត្តជាខ្លាំងនៅពេលដែលគាត់ឃើញថាខ្ញុំគ្មានអីវ៉ែអីវ៉ាន់អ្វីធំដុំច្រើនទេ មានតែសំលៀកបំពាក់សៀវភៅ និង ប្រដាប់ប្រដាបន្តិចបន្តួចតែប៉ុណ្ណោះ ។ នៅថ្ងៃជាមួយនោះ លោក ម៉ុត្តុង បានអនុញ្ញាតឲ្យខ្ញុំឈប់សំរាកពេញមួយថ្ងៃ ដើម្បីរកទិញតុ ទូ គ្រែ ពូក ខ្នើយ និង អ្វីៗ ដែលខ្ញុំត្រូវការសំរាប់ប្រើប្រាស់នៅក្នុងផ្ទះ ។ គាត់ចាត់ឲ្យបុគ្គលិកម្នាក់ដែលស្គាល់កន្លុកកន្លៀត ដែលអាចរករបស់របរតម្លៃថោកសមរម្យ ឲ្យជួយនាំខ្ញុំទៅទិញរបស់ទាំងនោះ ។ ថ្ងៃនោះ យើងទៅទិញរបស់របរនោះនៅទីក្រុង សាំង ដឺនី (Saint-Denis) ដែលជាទីក្រុងធំជាងគេនៅតំបន់នោះ ។ មិនតែប៉ុណ្ណោះថៅកែរបស់ខ្ញុំបានប្រើប្អូនថ្លៃគាត់ ដានីញ៉ែល ឲ្យមកជួយក្រាលកំរាលព្រំឲ្យខ្ញុំផង ។ ដូច្នេះមិនយូរប៉ុន្មាន ខ្ញុំក៏បានរស់នៅក្នុងផ្ទះមួយ ដែលពោរពេញទៅដោយគ្រឿងប្រណិត ។

បន្ទាប់ពីបានធ្វើការសាកល្បងអស់រយៈពេលបីខែមក ខ្ញុំក៏ត្រូវបានទទួលការតែងតាំងជាប្រធានគណនេយ្យពេញសិទ្ធិ ដោយបានទទួលប្រាក់ខែចំនួន ៥០០០ ហ្វ្រង់ ក្នុងមួយខែ ។ ការឡើងកាន់ឋានៈពីបុគ្គលិកធម្មតា ទៅជាអ្នកមានក្របខ័ណ្ឌខ្ពស់នេះ ជាករណីពិសេស សំរាប់ខ្ញុំដែលជាជនភៀសខ្លួនម្នាក់ក្នុងយុវវ័យនាសម័យនោះ ។ ម្យ៉ាងទៀតខ្ញុំក៏បានទទួលការទុកចិត្ត និង ការស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅ ពីថៅកែព្រមទាំងដៃគូរបស់គាត់ពីរនាក់ទៀត នៅក្នុងក្រុមហ៊ុនតេប៉េប៉េ ផងដែរ ។ នៅក្នុងការគ្រប់គ្រងក្រុមហ៊ុន ខ្ញុំបានក្លាយទៅជាមនុស្សម្នាក់

ដែលមិនអាចបាត់មុខបាន ។ ថៅកែរបស់ខ្ញុំធ្វើការពិគ្រោះជាមួយខ្ញុំរាល់ពេលវេលាដែលគាត់រើសបុគ្គលិកថ្មី ឬ បណ្ដេញបុគ្គលិកណាចោល ឬ នៅពេលដែល គាត់ដាក់ទណ្ឌកម្ម ឬ តម្លើងឋានៈដល់បុគ្គលិកទាំងអស់ ។

ខ្ញុំតែងផ្ដល់យោបល់ថា តើនៅពេលណាត្រូវតម្លើងឋានៈ និង ថានៅពេលណាត្រូវតម្លើងប្រាក់ខែឲ្យបុគ្គលិក ។ ខ្ញុំជាអ្នកចុះហត្ថលេខាលើឯកសារជាច្រើនក្នុងនាមជានិយោជកសំរាប់បុគ្គលិក ឬ កម្មករដែលត្រូវការឯកសារ ដើម្បីយកទៅបើកប្រាក់សន្តិសុខសង្គម ឬ ប្រាក់សំណងគ្រោះថ្នាក់ការងារ ឬ ឯកសារចូលនិវត្តន៍ និង ឈប់សំរាកប្រចាំឆ្នាំជាដើម ។ ក្នុងឋានៈជាប្រធានគណនេយ្យ ខ្ញុំចូលរួមក្នុងការចរចាជាមួយអ្នកតំណាងធនាគារក្នុងការខ្ចីប្រាក់ ឬ ឥណទានឯទៀតៗ ។ ជួនកាល ខ្ញុំក៏ចូលរួមចុះពិនិត្យដល់ទីកន្លែងដែលកម្មករធ្វើការ ។ ជាញឹកញយខ្ញុំចូលរួមទទួលទានបាយថ្ងៃត្រង់ ឬ បាយល្ងាចជាមួយថៅកែរបស់ខ្ញុំ ដែលគាត់រៀបចំទទួលអតិថិជនរបស់គាត់ ជាការទទួលទានអាហារបែបធុរកិច្ច ។

ជាមួយនឹងការសិក្សាផ្នែកគណនេយ្យរបស់ខ្ញុំ ខ្ញុំក៏ឆ្លៀតទៅរៀនបើកបររថយន្តនៅក្រៅពេលម៉ោងធ្វើការ ។ ប្រហែលបី ឬ បួនអាទិត្យក្រោយមក ខ្ញុំក៏បានទទួលប័ណ្ណបើកបររថយន្តនៅពេលចូលប្រឡងលើកទីមួយ ។ គ្រាន់តែឃើញប័ណ្ណបើកបររបស់ខ្ញុំ លោក ម៉ុត្តុង សប្បាយចិត្តណាស់ ។ គាត់ផ្ដល់រថយន្តរបស់ក្រុមហ៊ុនឲ្យខ្ញុំបើកបរភ្លាម ។ រថយន្តនោះ មានពណ៌លឿង ខៀវ និង ផ្លាកសញ្ញារបស់ក្រុមហ៊ុនត្រូវបានខ្ញុំប្រើរហូតដល់ពេលខ្ញុំមានរថយន្តផ្ទាល់ខ្លួន ដែលខ្ញុំបានត្រៀមទិញនៅពេលខាងមុខ ។ ដើម្បីទិញរថយន្តនេះ ថៅកែបានចាត់ឲ្យ ដានីញ៉ែល នាំខ្ញុំដើរទៅរកមើលក្នុងចំណោមរថយន្តចាស់ៗដែលគេដាក់លក់នៅតាមហាងជួសជុលរថយន្តនានា ។ ពេលខ្ញុំជួប ដានីញ៉ែល ភ្លាម គាត់និយាយថា បើសិនជាខ្ញុំសុខចិត្តចំណាយប្រាក់តែ ២៥០០ ហ្វ្រង់ គាត់អាចជួយកែកុនរថយន្ត

នោះឲ្យល្អដូចរថយន្តថ្មីសន្លាងបាន ។ ឮដូច្នេះខ្ញុំក៏យល់ព្រម ។ ព្រឹកឡើងនៅថ្ងៃបន្ទាប់ ដានីញ៉ែល បានចូលមកក្នុងការិយាល័យខ្ញុំ ដើម្បីបបួលខ្ញុំទៅទីក្រុងសាំងដឺនី ដោយប្រាប់ខ្ញុំថា ឲ្យយកមូលប្បទានប័ត្រទៅជាមួយផង ។ បន្ទាប់មក ដានីញ៉ែល ក៏បររថយន្តរបស់គាត់ ដែលជារថយន្តសណ្តោងទៅហាងជួសជុលរថយន្តមួយដែលមានដាក់លក់រថយន្តថ្មី និង ចាស់មួយចំនួន ។ នៅពេលទៅដល់ទីនោះ ដានីញ៉ែល នាំខ្ញុំទៅផ្នែកខាងក្រោយនៃហាងជួសជុល ហើយចង្អុលទៅរថយន្តមួយដែលគ្របដណ្តប់ដោយធូលី និង សម្រាមយ៉ាងក្រាស់មើលស្ទើរមិនយល់ ។ រថយន្តនោះជារថយន្ត ម៉ាក ប៉ឺហ្សូ ២០៤ (Peugeot 204) បែបរថយន្តសំរាប់គ្រួសារ ។ ដានីញ៉ែល ចង្អុលប្រាប់ខ្ញុំថានេះហើយជារថយន្តរបស់អ្នកឯង ។ ខ្ញុំធ្លាក់ថ្លើមក្តុកនឹកអន់ចិត្តថាម្តេចក៏មកទិញរថយន្តប្រភេទនេះទៅវិញ ។ ខ្ញុំមានការស្ទាក់ស្ទើរមិនចង់ប្រគល់មូលប្បទានប័ត្រចំនួន ២៥០០ ហ្វ្រង់នោះទេ ។ ម្យ៉ាងទៀត រថយន្តនោះ មានគ្រឿងម៉ាស៊ីនខូច និង គ្មានធុងអាគុយផង ។ ក៏ប៉ុន្តែ ដោយមានការធានាពី ដានីញ៉ែល ថារថយន្តនេះសមរម្យហើយ ខ្ញុំក៏សុខចិត្តបង់ប្រាក់គ្រប់ចំនួននោះទៅ ។ នៅទីបញ្ចប់ ពួកយើងសណ្តោងអូសរថយន្តដែលយើងទើបតែទិញរួចនោះមករោងជាងនៃក្រុមហ៊ុនរបស់យើងវិញដើម្បីធ្វើការជួសជុល និង កែលំអ ។

ដានីញ៉ែល ជាមនុស្សមានការងាររវល់យ៉ាងមមាញឹក ។ នៅខាងក្រៅរោងជាង គាត់មានរថយន្តពីរ ឬ បីគ្រឿងជានិច្ច ដែលត្រូវចតរង់ចាំការជួសជុល ។ រថយន្តភាគច្រើនជារបស់មន្ត្រីនៃក្រុមហ៊ុន ដែលជាអតិថិជនរបស់យើង ។ តាមពិតរោងជួសជុលនេះ បំពេញការងារមួយផ្នែកដែរ ក្នុងទំនាក់ទំនងសាធារណៈរបស់ក្រុមហ៊ុន ។ លោក ម៉ុត្តុង តែងយកចិត្តទុកដាក់ចំពោះអតិថិជនធំៗរបស់គាត់ ដោយជួសជុលរថយន្តរបស់អ្នកទាំងនោះ ដោយឥតគិតថ្លៃ ។ ធ្វើបែបនេះ ទើបគាត់

ទទួលបាននូវកិច្ចសន្យាការងាររបស់គាត់ជាច្រើន ។ ដូច្នេះការជួសជុលរថយន្ត របស់ខ្ញុំ មិនមានអាទិភាពខ្ពស់សំរាប់ ដានីញ៉ែល ទេ ។ អស់រយៈពេលមួយខែ ក្រោយមក ដានីញ៉ែល ក៏ចាប់ផ្តើមជួសជុល និង កែលំអរថយន្តរបស់ខ្ញុំ ឲ្យមាន សភាពដូចរថយន្តថ្មីដូច្នោះមែន ។ ដានីញ៉ែល បានដូរម៉ាស៊ីន និង បាញ់ថ្នាំថ្មី ធ្វើឲ្យ រថយន្តចាស់ក្លាយជារថយន្តមួយថ្មី ដូចទើបចេញពីហាងយ៉ាងដូច្នោះដែរ ។ ខ្ញុំមាន សេចក្តីត្រេកអរជាអនេកចំពោះរថយន្តថ្មី ដែលខ្ញុំមិនធ្លាប់មានទាល់តែសោះ ។ ដោយសាររថយន្តនោះ មានសភាពស្អាតល្អពេក សហការីម្នាក់បានសុំប្តូររថយន្ត នោះជាមួយនឹងរថយន្ត 2CW ដ៏ថ្មី ដែលគាត់ទើបតែទិញចេញពីរោងចក្រ ។ ប៉ុន្តែ ខ្ញុំស្រឡាញ់រថយន្ត ប៉ឺហ្សូ ២០៤ (Peugeot 204) នោះខ្លាំងពេក ខ្ញុំក៏ប្រកែក មិនព្រមដូរ ។ ជារៀងរាល់ថ្ងៃ នៅពេលមកដល់កន្លែងធ្វើការ ខ្ញុំតែងចតរថយន្តនៅ ទីកន្លែងណា ដែលខ្ញុំអាចមើលឃើញ តាមបង្អួចកញ្ចក់ពីការិយាល័យខ្ញុំជានិច្ច ។

ក្នុងរយៈពេលជាច្រើនឆ្នាំ ដែលខ្ញុំធ្វើការក្នុងក្រុមហ៊ុនម៉ុត្តុង ខ្ញុំតែងបាន ទទួលការស្រឡាញ់រាប់អានពីគ្រប់មជ្ឈដ្ឋានរាប់ទាំងថៅកែខ្ញុំ និង ដៃគូរបស់គាត់ពីរ នាក់ទៀតផង ។ តាមធម្មតានៅរៀងរាល់ពេលដែលខ្ញុំមកដល់កន្លែងធ្វើការ បន្ទាប់ ពីខ្ញុំបានទទួលទានអាហារពេលព្រឹករួចហើយ ដែលមានដូចជាកាហ្វេខ្មៅក្តៅ និង នំខ្លះៗ ខ្ញុំបើកបររថយន្តយ៉ាងប្រញាប់មកការិយាល័យរបស់ខ្ញុំ ។ ខ្ញុំមកដល់នៅ ចន្លោះម៉ោង ៨ម៣០ និង ៨ម៣៥ ព្រឹក ។ ជាញឹកញាប់លោក ម៉ុត្តុង តែងមកដល់ ការិយាល័យមុនខ្ញុំ ឯភរិយាគាត់មកតាមក្រោយ ។ ពេលអ្នកស្រីមកដល់ ទាំងប្តី ទាំងប្រពន្ធតែងនាំខ្ញុំទៅទទួលទានកាហ្វេម្តងទៀតនៅហាងមីៗ ។ នៅពេលនោះ ដៃគូរបស់គាត់គឺ លោក កាមុស និង ហ្វុងតែន បានមករួមទទួលទានកាហ្វេជាមួយ យើង ឬ ជួនកាលនៅពេលខ្លះ ខ្ញុំទៅទទួលទានការហ្វេជាមួយអ្នកទាំងពីរនាក់នោះ ដោយគ្មានវត្តមានរបស់ថៅកែ ។ ការទទួលទានកាហ្វេពេលព្រឹកនេះ ជាឱកាសឲ្យ

យើងនិយាយពីការងាររបស់ក្រុមហ៊ុនខ្លះ ឬ និយាយលេងពីនេះពីនោះក៏មាន ។ ដូច្នេះ ក្នុងមួយថ្ងៃៗ ខ្ញុំក៏ទទួលទានកាហ្វេជាច្រើនពែង ព្រោះនោះជាពិធីការទូតតាមការអញ្ជើញជាញឹកញាប់ក្នុងមួយថ្ងៃៗ ។ ការទទួលទានកាហ្វេនៅហាងមីៗមុននឹងចាប់ផ្តើមការងារ ក៏បានក្លាយទៅជាកិច្ចប្រតិបត្តិប្រចាំថ្ងៃរបស់ខ្ញុំអស់ពេលជាច្រើនឆ្នាំ ។

# បែកឲ្យដាច់មនោសញ្ចេតនា និង ការងារ

នៅពេលបាយថ្ងៃត្រង់ ខ្ញុំតែងទៅចូលរួមទទួលទានអាហារជាមួយគ្រួសារលោក ម៉ុត្តុង នៅក្នុងភោជនីយដ្ឋានក្បែរនោះ ឬ បើពុំនោះទេ ខ្ញុំទៅជាមួយលោក កាមុស និង ហ្វុងតែន ដែលនាំខ្ញុំទៅភោជនីយដ្ឋានគ្មានអ្នកបំរើ (Self Service Restaurant) នៅក្បែរនោះ ឯក្រុងសាក សែល (Sarcelles) ។ គ្រួសារ ម៉ុត្តុង ទទួលទានបាយនៅវេលាម៉ោងមួយរសៀល ព្រោះគាត់ត្រូវរង់ចាំកូនស្រីគាត់ពីរនាក់ គឺ ប៉ាទ្រីស្យា (Patricia) និង សេលីន (Céline) ចេញពីសាលា ។ ដូច្នេះជាញឹកញាប់ ខ្ញុំទទួលទានបាយរួមជាមួយអ្នកទាំងនោះ ដែលមានម្ហូបអាហារដូចៗគ្នា ។ នៅភោជនីយដ្ឋាននេះ ខ្ញុំមិនបង់ប្រាក់ភ្លាមទេ គ្រាន់តែឲ្យគេកត់ត្រាទុក រួចបូកសរុបទើបខ្ញុំទូទាត់បង់ប្រាក់មួយខែម្តង ។ ក៏ប៉ុន្តែនៅភោជនីយដ្ឋានគ្មានអ្នកបំរើ ខ្ញុំត្រូវចេញប្រាក់ភ្លាមៗ ។ នៅទីនោះ ពួកយើងមានការរីករាយច្រើន ព្រោះស្ថិតនៅ ក្នុងបរិយាកាសប្រជាប្រិយ និង មានម្ហូបក្តៅៗ ដែលមាននារីម្នាក់រាងធាត់បន្តិច ឈ្មោះអ្នកស្រី ហ្គូហ្សុង (Goujon) ជាអ្នកលើកម្ហូបឲ្យយើង ។

បន្តិចម្តងៗ ពួកយើងក៏កាន់តែជិតស្និទ្ធគ្នាឡើង ពួកយើងកាន់តែស្រឡាញ់រាប់អានគ្នាឡើង ។ ក៏ប៉ុន្តែ នៅពេលបាយម្តងៗ ខ្ញុំមានការពិបាកក្នុងចិត្តថា តើគួរចេញទៅទទួលទានអាហារជាមួយក្រុមណា? ជាមួយថៅកែធំ ជាមួយគ្រួសារថៅ

កែធំ ឬ ទៅជាមួយអ្នកដៃគូរបស់គាត់ទាំងពីរនាក់នោះ? ប្រសិនបើអ្នកទាំងនោះមិនមានទំនាស់ផលប្រយោជន៍រវាងគ្នា និង គ្នាទេនោះ ខ្ញុំក៏គ្មានអ្វីគួរឲ្យព្រួយបារម្ភដែរ ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកទាំងនោះ មានទំនាស់ជាមួយគ្នា ខ្ញុំត្រូវតែប្រុងប្រយ័ត្នជានិច្ច គឺមិនត្រូវបង្ហាញរូបភាពថា ខ្ញុំចូលចិត្តក្រុមម្ខាងជាងក្រុមម្ខាងទៀតឡើយ ។ ខ្ញុំត្រូវថែរក្សាអព្យាក្រឹតភាពរបស់ខ្ញុំ ។ តាមធម្មតានៅពេលណាដែលក្រុមទាំងពីរមានមតិខ្វែងគ្នា ពួកគេតែងសុំឲ្យខ្ញុំផ្តល់មតិជាចុងក្រោយ ។ តាមរូបភាពជាក់ស្តែង ខ្ញុំទោរទន់ទៅខាងក្រុមលោកថៅកែធំ ខាងផ្នែកមនោសញ្ចេតនាយ៉ាងច្រើន ព្រោះពួកគេរាប់អានខ្ញុំដូចជាសមាជិកក្រុមគ្រួសាររួចទៅហើយ ។ ក៏ប៉ុន្តែ ចំពោះការងារវិញ ខ្ញុំមានទំនោរទៅរកអ្នកដៃគូទាំងពីរនាក់នោះ ព្រោះអ្នកទាំងនោះបានរៀនសូត្រច្រើន ចេះដឹងច្រើន ធ្វើអ្វីៗច្រើនធ្វើតាមច្បាប់ មិនសូវចេះកេងប្រវ័ញ្ចអ្វីប៉ុន្មានឡើយ ។ ផ្ទុយទៅវិញ ថៅកែធំចូលចិត្តអួតអាងខាងផ្លូវសម្ភារៈដូចជា៖ ឡានល្អ សំលៀកបំពាក់ល្អ ម្ហូបអាហារថ្លៃៗ ដើរលេងសប្បាយច្រើន និង ប្រើល្បិចកលជាច្រើន ដើម្បីរកប្រាក់ចំណេញសំរាប់ក្រុមហ៊ុនគាត់ ។ ជាញឹកញាប់នៅវេលាចេញទៅទទួលទានអាហារថ្ងៃត្រង់ អ្នកដៃគូរបស់ថៅកែធំគឺ លោក កាមុស និង លោក ហ្វុងតែន តែងនាំគ្នាមកស្រែកហៅ នៅមុខការិយាល័យរបស់ខ្ញុំថា "មូលី ដល់ម៉ោងបាយហើយ" ។ ជាពិសេស នៅរាល់ថ្ងៃសៅរ៍ នៅពេលដែលយើងផ្អាកការងារនៅក្នុងការិយាល័យ អ្នកទាំងពីរតែងបើករថយន្តនាំខ្ញុំទៅមើលការដ្ឋាននានា ដើម្បីត្រួតពិនិត្យការងាររបស់កម្មករ ដែលនៅទីបញ្ចប់ម្តងៗពួកយើងតែងទៅទទួលទានអាហារថ្ងៃត្រង់ទាំងអស់គ្នា ។ នៅពេលនោះ យើងចាប់ផ្តើមទទួលទានអាហារ តាំងពីថ្ងៃត្រង់រហូតដល់ម៉ោងបី ឬ បួនរសៀលទើបចប់ ។ គឺនៅពេលនោះហើយ ដែលយើងជជែកគ្នាលេងផង យើងនិយាយពីការងារផង ជាពិសេស ជាឱកាសឲ្យខ្ញុំបានស្គាល់នូវទឹកដៃនៃម្ហូបអាហារដ៏មានរសជាតិរបស់បារាំង រួមផ្សំនឹងស្រាដ៏ល្អៗ និង

ដ៏មានតម្លៃ ។ តាំងពីពេលនោះមក ខ្ញុំជាប់ចិត្តនឹងម្ហូបអាហារ និង ភេសជ្ជៈបារាំងយ៉ាងខ្លាំង ។

ទំនាក់ទំនងរវាងថៅកែធំជាមួយដៃគូរបស់គាត់ទាំងពីរនាក់នោះ មិនយូរប៉ុន្មានក៏មានការល្អក់កករវាងគ្នា ដោយហេតុថាថៅកែធំអាងលើអំណាចជាប្រធានក្រុមហ៊ុន ចាត់ការដោយអត្តនោម័តតែម្នាក់ឯង ។ អ្នកដៃគូទាំងពីរនាក់យល់ថាពួកគេជាអ្នកធ្វើការសំខាន់ៗ ដូចជាផ្នែកទំនាក់ទំនងសាធារណៈទាក់ទាញអតិថិជន ស្វែងរកទីផ្សារ និង ការងារបច្ចេកទេសទាំងអស់ ។ លោក កាមុស ដែលមានតំណែងជានាយកបច្ចេកទេស និង លោក ហ្មុងតែន ជានាយកនៃកិច្ចប្រតិបត្តិការយល់ថា ពួកគេពុំសូវបានទទួលផលប្រយោជន៍ឲ្យសមស្របទៅតាមទំហំការងាររបស់គេឡើយ ឯចំណែកថៅកែធំគឺ លោកម៉ុត្តុង គាត់ជាអ្នកកាន់មូលប្បទានប័ត្រអាចចាយវាយស្រេចតែចិត្ត ។

តាមពិតទៅ គ្រួសាររបស់លោក ម៉ុត្តុង មានចិត្តសប្បុរសល្អជាមួយខ្ញុំណាស់ ពួកគេតែងហៅរកខ្ញុំឲ្យចូលរួមបាយល្ងាចនៅផ្ទះរបស់គេនៅទីក្រុងសាកសែល ហើយបន្ទាប់មក នៅទីក្រុងព្យែរហ្វឺត ។ នៅពេលមានបុណ្យទានសំខាន់ៗដូចជា បុណ្យខួបកំណើត បុណ្យណូអែល ឬ បុណ្យចូលឆ្នាំថ្មីជាដើម ពួកគេមិនដែលភ្លេចហៅខ្ញុំឡើយ ។ លោកស្រី ម៉ុត្តុង ចូលចិត្តនិយាយរឿងពីកូនស្រីគាត់ប្រាប់ខ្ញុំមិនដែលដាច់ ។ កូនស្រីនោះឈ្មោះនាង ប៉ាទ្រីស្យា មានអាយុ ១០ ឆ្នាំតិចជាងខ្ញុំ ។ នាងកំពុងរៀនវិជ្ជាផ្នែកគណនេយ្យដែរ ។ ជាញឹកញយ នៅពេលយើងទទួលទានកាហ្វេនៅតៀមកាហ្វេមីៗ លោកស្រី ម៉ុត្តុង តែងនិយាយពីសកម្មភាពរបស់ប៉ាទ្រីស្យាប្រាប់ខ្ញុំ មិនតែប៉ុណ្ណោះ លោកស្រីបានសុំឲ្យខ្ញុំជួយបង្រៀនគណនេយ្យ និង ធ្វើលំហាត់ឲ្យប៉ាទ្រីស្យាផង ។ ដូច្នេះ ជាញឹកញាប់ ប៉ាទ្រីស្យា តែងមកជួបខ្ញុំនៅកន្លែងធ្វើការ ។ នៅពេលខ្លះទៀត ខ្ញុំទៅជួយបង្រៀននាងដល់ផ្ទះ ។ នៅចុងសប្តាហ៍មួយនោះ ខ្ញុំ

បានបើករថយន្តជូន ប៉ាទ្រីស្យា ទៅលេងផ្ទះជីដូនជីតានាងនៅឯទីក្រុងសេដង់ (Sédan) ដែលនៅទល់ដែនជាប់ ប្រទេសប៊ែលហ្សិក ។

ខ្ញុំចាំបានថា នៅពេលឈប់សំរាកនារដូវក្តៅមួយនោះ អ្នកស្រី ម៉ុត្តុង បាន ទូរស័ព្ទពីផ្ទះសំរាករបស់គាត់នៅទីក្រុងសាំងរ៉ាហ្វាអែល (Saint-Raphael) ដែល ស្ថិតនៅភាគខាងត្បូងនៃប្រទេសបារាំងក្បែរទីក្រុងនីស (Nice) ដើម្បីឲ្យខ្ញុំទៅសំរាក វិស្សមកាលជាមួយពួកគាត់ ។ នៅថ្ងៃនោះ ក្រោយដែលគាត់និយាយរួច គាត់ហុច ទូរស័ព្ទទៅឲ្យ ប៉ាទ្រីស្យា ដើម្បីនិយាយហៅខ្ញុំដោយផ្ទាល់មាត់ឲ្យទៅឈប់សំរាក រួមគ្នា ។ នៅទីបំផុតខ្ញុំក៏យល់ព្រមតាមសំណើ ។ ខ្ញុំបើកបររថយន្តតែម្នាក់ឯងឆ្លង កាត់ផ្លូវប្រវែង ១០០០ គ.ម.។ ក្នុងដំណើរនេះ ខ្ញុំក៏ឆ្លៀតចូលទៅលេងលោកស្រី ម៉េឡាតូ ដែលធ្លាប់ធ្វើការជាមួយខ្ញុំ នៅក្នុងក្រុមហ៊ុនទេសចរណ៍ ហ្វារ៉ូសហ្វ្រង់ ព្រោះអ្នកស្រីចូលនិវត្ត ហើយបានមករស់នៅក្នុងតំបន់ឡាប្រ៉ូវ៉ង់ (La Provence) អស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ទំនាក់ទំនងរវាងខ្ញុំ និង គ្រួសារលោក ម៉ុត្តុង មានសភាពជិតស្និទ្ធពេក រហូតខ្ញុំហ៊ាននិយាយលេងជាមួយមិត្តភក្តិខ្មែរៗថា លោកស្រី ម៉ុត្តុង ជាម្តាយក្មេករបស់ខ្ញុំយ៉ាងដូច្នោះដែរ ។

ទោះបីជាខ្ញុំរៀនធ្លាក់នៅឆ្នាំ ១៩៧៤ ក៏ដោយ ក៏ខ្ញុំបានបន្តការសិក្សារបស់ ខ្ញុំតទៅទៀតនៅវិទ្យាស្ថានជាតិបច្ចេកទេសសេដ្ឋកិច្ច និង គណនេយ្យ ។ នៅឆ្នាំ ១៩៧៦ ខ្ញុំបានប្រឡងជាប់ដោយជោគជ័យ ។ តាំងពីខ្ញុំបានចូលធ្វើការជាមួយក្រុម ហ៊ុន ម៉ុត្តុង មកកំរិតជីវភាពរបស់ខ្ញុំ បានឡើងខ្ពស់ជាលំដាប់ ។ ឥឡូវនេះ ខ្ញុំជួល នារីជនជាតិបារាំងចំណាស់បន្តិចម្នាក់ មួយថ្ងៃពីរ ឬ បីម៉ោងឲ្យមកបោសសំអាតផ្ទះ និង បោកអ៊ុតខោអាវឲ្យខ្ញុំ ។ ជួនកាលនារីនោះ ចំអិនម្ហូបអាហារទុកឲ្យខ្ញុំផង ។ ជាទម្លាប់ប្រសិនបើខ្ញុំចូលដល់ក្នុងផ្ទះ ខ្ញុំឃើញមានការតុបតែងផ្ទះដោយផ្កាស្រស់ៗ នោះ ខ្ញុំត្រូវដឹងថា នារីអ្នកបំរើនោះនឹងសុំឲ្យខ្ញុំតម្លើងប្រាក់ម៉ោងរបស់គាត់មិនខាន

ឡើយ ។ និយាយរួមមក ខ្ញុំមានការងារធ្វើក៏ល្អ មានប្រាក់ខែសមរម្យ ។ ខ្ញុំ រស់នៅក្នុងផ្ទះដែលមានសម្ភារៈតុទូជារបស់ខ្ញុំ និង មានរថយន្តដ៏ថ្មីសន្លាងមួយ ដែលខ្ញុំបានបញ្ជាទិញពីរោងចក្រ ។ រថយន្តម៉ាក រ៉ឺណូ ៥ ឡឺ កា (Renault 5 le Car)នោះមានវាយតួលេខរៀង ដែលកំណត់ឲ្យដឹងពីចំនួនរថយន្តផលិតចេញពីរោងចក្រផង ។ រថយន្តបែបនេះ គេមិនផលិតច្រើនទេគឺ តែមួយចំនួនតូចប៉ុណ្ណោះ ។

បើក្រឡេកមើលខ្លួនឯងដែលជាជនភៀសខ្លួនម្នាក់នោះ និង បើប្រៀបធៀបជាមួយជនរួមជាតិជាជនភៀសខ្លួនខ្មែរឯទៀតផង ខ្ញុំគិតថាខ្ញុំមានភ័ព្វសំណាង និង បុព្វសិទ្ធិជាងអ្នកទាំងនោះឆ្ងាយណាស់ ។ ក៏ប៉ុន្តែ នៅពេលខ្ញុំកាន់តែមានភាពធូរធារ និង ភាពសម្បូរសប្បាយខាងផ្លូវសម្ភារៈឡើងកាលណា កាលនោះខ្ញុំហាក់ដូចជាកាន់តែទទួលរងនូវសម្ពាធខាងផ្លូវសតិអារម្មណ៍មួយយ៉ាងខ្លាំងដែរ ។ គឺខ្ញុំកើតមានក្តីកង្វល់ក្នុងចិត្ត ចំពោះទុក្ខវេទនាដែលប្រជាពលរដ្ឋខ្មែរទាំងមូលកំពុងជួបប្រទះ នៅក្រោមរបប ប៉ុល ពត ។ ម្យ៉ាងទៀត ខ្ញុំមានអារម្មណ៍មិនស្រួលក្នុងចិត្តឥតឧបមា ព្រោះតែខ្ញុំដាច់ទំនាក់ទំនងជាមួយឪពុកម្តាយ បងប្អូនខ្ញុំ ដែលរស់នៅឯប្រទេសកម្ពុជាទាំងស្រុង ។ ខ្ញុំមានចិត្តចង់ចែករំលែកនូវភាពធូរធារសម្បូណ៌សប្បាយរបស់ខ្ញុំដល់មនុស្សជាទីស្រឡាញ់ទាំងឡាយរបស់ខ្ញុំទាំងនោះ ។ ទុក្ខលំបាកខាងផ្លូវចិត្តនោះកាន់តែមានទម្ងន់ធ្ងន់ឡើងៗ នៅពេលដែលប្រព័ន្ធផ្សព្វផ្សាយពិភពលោកបានចាប់ផ្តើមធ្វើឲ្យយើងកាន់តែដឹងច្បាស់ នូវអំពើសាហាវយង់ឃ្នងរបស់ខ្មែរក្រហមចំពោះប្រជាពលរដ្ឋខ្មែរ ។ នៅពេលដែលខ្ញុំកាន់តែចូលជ្រៅទៅៗក្នុងសង្គមរបស់បារាំងគឺ បន្ទាប់ពីបានធ្វើសមាហរណកម្មប្រកបដោយជោគជ័យ និង នៅពេលដែលខ្ញុំយល់ថា ខ្ញុំត្រូវបានទទួលការរាប់អានដោយស្មើមុខពីសំណាក់មិត្តភក្តិ ឬ អ្នកដែលនៅជុំវិញខ្ញុំ ជាពិសេស ពីជនជាតិបារាំងនោះ ខ្ញុំក៏កាន់តែត្រូវការឲ្យខ្ញុំខំការពារប្រភពដើមកំណើតឈាមជ័រខ្មែររបស់ខ្ញុំដែរ ។ ខ្ញុំគឹតថាខ្ញុំមិនអាចផ្តាច់

ឫសគល់របស់ខ្ញុំបាននោះទេ ។ ដូច្នេះ ដើម្បីឲ្យមានតុល្យភាពក្នុងជីវិត ជាពិសេសក្នុងផ្លូវសតិអារម្មណ៍ ខ្ញុំបានសំរេចចិត្តថា ខ្ញុំត្រូវតែចាប់ផ្តើមធ្វើទំនាក់ទំនងជាមួយសហគមន៍ខ្មែរនៅប្រទេសបារាំងឡើងវិញ ។

# វិលមកជួបសហគមន៍ខ្មែរវិញ

ចាប់តាំងពីពេលដែលខ្មែរក្រហមបានទទួលជ័យជំនះមក ខ្ញុំមិនដែលទាក់ទងជាមួយខ្មែរណាម្នាក់សោះក្រៅពីមិត្តភក្តិខ្មែរបី ឬ បួននាក់ ព្រោះខ្ញុំហាក់ដូចជាមានការជិនឆ្អន់ចំពោះអ្នកដឹកនាំខ្មែរសម័យនោះ ដែលធ្វើឲ្យកម្ពុជារលំរលាយ ។ ដើម្បីធ្វើឲ្យមានទំនាក់ទំនងជាមួយសហគមន៍ខ្មែរឡើងវិញ ខ្ញុំក៏ពឹងពាក់មិត្តភក្តិជិតស្និទ្ធដូចជា ផាន់ សូរិយាស៊ី និង យឹម ខាន់កែវ ដែលឥឡូវនេះប្រពន្ធគាត់ឈ្មោះនាង សូនី បានក្លាយមកជាជំនួយការផ្ទាល់ម្នាក់របស់ខ្ញុំនៅឯក្រុមហ៊ុន តេប៉េប៉េ ។ មិនយូរប៉ុន្មាន យឹម ខាន់កែវ ក៏នាំឲ្យស្គាល់មិត្តភក្តិរបស់គេម្នាក់ឈ្មោះ អ៊ឹង យូតឹកលីន ។ អ៊ឹង យូតឹកលីន ក៏បានក្លាយជាមិត្តជិតស្និទ្ធដែលខ្ញុំតែងតែជួបជាញឹកញាប់មិនសូវខាន ។ នៅពេលដែលនាង សូនី លាឈប់ពីក្រុមហ៊ុន តេប៉េប៉េ ខ្ញុំក៏ជ្រើសរើសស្ត្រីខ្មែរម្នាក់ទៀតជាជំនួយការ ឈ្មោះអ្នកស្រី ឱម វឌ្ឍនា ដែលមិនគ្រាន់តែជាជំនួយការរបស់ខ្ញុំប៉ុណ្ណោះទេ តែក៏ជាមនុស្សដែលខ្ញុំទុកចិត្តអាច និយាយរឿងអាថ៌កំបាំង ឬ ការសម្ងាត់ជាមួយបាន។

ជីវិតជាអ្នកទីក្រុងប៉ារីសរបស់ខ្ញុំ បានគ្របដណ្តប់ដោយការតស៊ូគឺ ការតស៊ូដើម្បីឲ្យមានជីវភាពសមរម្យផង ដើម្បីធ្វើសមាហរណកម្មនៅក្នុងសង្គមលោកខាងលិចឲ្យបានជោគជ័យផង ដែលជាកត្តាមួយធំចម្បងក្នុងការជួយពង្រឹងបុគ្គលិក

លក្ខណៈរបស់ខ្ញុំ និង ពង្រឹងអត្តចរិតរបស់ខ្ញុំឲ្យក្លាយជាមនុស្សមានការទទួល ខុសត្រូវ និង ជាមនុស្សសេរីពិតប្រាកដផង ។ ម្យ៉ាងទៀត ជីវិតខ្ញុំសម័យនោះក៏បានទទួលរងនូវការគាបសង្កត់ពីព្រឹត្តិការណ៍ដ៏ខ្លោចផ្សាដែលកំពុងកើតមាននៅប្រទេសកម្ពុជា និង ដែលបានចងភ្ជាប់តួអង្គខ្ញុំ ទៅជាមួយវាសនាប្រជាជាតិ និង ប្រជាពលរដ្ឋកម្ពុជារបស់ខ្ញុំដែរ ។ ក្នុងឋានៈជាកូនខ្មែរម្នាក់ ខ្ញុំពុំអាចរស់នៅយកសុខតែម្នាក់ឯង ដោយមិនឈឺឆ្អាល ឬ មិនញាប់ញ័រ ចំពោះអ្វីៗដែលកើតមាននៅប្រទេសខ្ញុំ ចំពោះមាតុភូមិខ្ញុំ និង ចំពោះប្រជារាស្ត្រខ្ញុំនោះឡើយ ។ ជាញឹកញាប់ ខ្ញុំតែងប្រឈមមុខចំពោះជំរើសពីរគឺ ទីមួយ តើខ្ញុំត្រូវបន្តរស់នៅយ៉ាងសង្ហារសមសួនសប្បាយរីករាយនៅក្នុងប្រទេសបារាំង ដោយរៀបការជាមួយនារីបារាំង និង បង្កបង្កើតជាក្រុមគ្រួសារនៅប្រទេសបារាំង ព្រមទាំងសុខចិត្តបំភ្លេចឈាមជ័រជាខ្មែរ ឬ ទីពីរ តើខ្ញុំសុខចិត្តធ្វើពលីកម្មនូវអ្វីៗទាំងអស់រួមទាំងអាយុជីវិត ដោយសុខចិត្តចូលរួមដៃជាមួយអ្នកស្នេហាជាតិខ្មែរ ធ្វើការស្តារ និង កសាងប្រជាជាតិខ្មែរឡើងវិញ ។ ប្រសិនបើខ្ញុំរៀបការជាមួយនារីបារាំង ខ្ញុំប្រហែលជានឹងឧទ្ទិស ឬ ចំណាយនូវថាមពលរបស់ខ្ញុំសំរាប់គ្រួសារបារាំងរបស់ខ្ញុំ ដោយបោះបង់ឫសគល់ និង ប្រភពដើមខ្មែរផង ។ បើខ្ញុំធ្វើយ៉ាងនេះ ខ្ញុំប្រហែលជាលាដាច់អាល័យពីកម្ពុជា ព្រោះបើខ្ញុំមានគ្រួសារ ខ្ញុំត្រូវទទួលខុសត្រូវទាំងស្រុងចំពោះគ្រួសារខ្ញុំ ដោយខ្ញុំមិនអាចបែកពីគ្រួសារនោះ និង មិនអាចទៅបំរើបុព្វហេតុខ្មែរណាមួយបានឡើយ ។ នៅទីបំផុត ខ្ញុំបានធ្វើការជ្រើសរើសមួយយ៉ាងច្បាស់លាស់ណាស់គឺ ខ្ញុំប្តេជ្ញាថែរក្សាអត្តសញ្ញាណរបស់ខ្ញុំ និង ផ្សារភ្ជាប់អនាគតរបស់ខ្ញុំជាមួយភ័ព្វព្រេងសំណាងរបស់កម្ពុជាទាំងមូល ។ ដោយសារការជ្រើសរើសយ៉ាងច្បាស់នេះហើយ ទើបខ្ញុំព្យាយាមពន្យល់មិត្តភក្តិបារាំងដែលមានការជិតស្និទ្ធជាមួយខ្ញុំទាំងឡាយឲ្យដឹងពីឆន្ទៈ និង សេចក្តីប្តេជ្ញាចិត្តរបស់ខ្ញុំថា ខ្ញុំត្រូវតែត្រឡប់ទៅកម្ពុជាវិញនៅថ្ងៃណាមួយមិនខាន ។ យ៉ាងនេះ

ហើយ ទើបខ្ញុំចាប់ផ្តើមចូលរួមធ្វើសកម្មភាពបំរើសង្គមជាគុណប្រយោជន៍ដល់សហគមន៍ខ្មែរនៅប្រទេសបារាំងជាមុនសិន ។

បន្ថែមលើការងារទទួលខុសត្រូវផ្នែកវិជ្ជាជីវៈរបស់ខ្ញុំ ខ្ញុំក៏ចំណាយពេលវេលាក្រៅម៉ោងធ្វើការស្ម័គ្រចិត្តបំរើសកម្មភាពសង្គមកិច្ច សម្រាប់សហគមន៍ខ្មែរនៅប្រទេសបារាំងជាបន្តរៀងមក ។ បើនិយាយឲ្យខ្លី ជីវិតជាអ្នកទីក្រុងប៉ារីសរបស់ខ្ញុំនោះ មិនមានសភាពហ៊ឺហាហ៊ឹកហ៊ាក់ ឬ មានលក្ខណៈជាអ្នកដើរលេងឡូយថូយដូចអ្នកខ្លះអាចគិតឃើញនោះឡើយ ។